**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ដំណោះស្រាយ និងវិធានការណ៍នៃការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ឌីម ប៉ាច**

**អ៊ុន ខេមវីរៈ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **អ៊ុន សកក្កដា**

ឆ្នាំចូលរៀន ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ចឹម ចាន់** និង**អ៊ុន ខេមធីរៈ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៦-២០២០៖

ជាបឋមយើងខ្ញុំទាំងពីរនាក់សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះលោកអ្នកមានគុណទាំងទ្វេរ ពោល គឺលោកឪពុក និងអ្នកម្តាយដែលបានចិញ្ចឹមបីបាច់កូនដោយក្តីសណ្តោសប្រណីប្រកបដោយព្រហ្មវិហារធម៌ ការលះបង់ កម្លាំងកាយចិត្ត រួមទាំងទឹកចិត្តស្រលាញ់ឥតប្រួលប្រែប្រកបដោយភក្តីភាព និងបានផ្តល់ឲ្យកូននូវធនធានចំនេះដឹងដ៏ល្អប្រពៃ ដើម្បីឲ្យកូនក្លាយទៅជាសរសរទ្រូងនៃប្រទេសជាតិ ពោល គឺទំពាំងស្នងឬស្សី ដើម្បីបម្រើជាតិមាតុភូមិដែលជាគុណបំណាច់មិនអាចកាត់ថ្លៃបានដែលលោកទាំងទ្វេរមានចំពោះពួកកូន។

សូមអរគុណយ៉ាងជ្រាលជ្រៅទៅដល់ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រមទាំងគណៈគ្រប់គ្រង រួមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំអស់ពីសមត្ថភាពនូវក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួលក៏ដូចជាបង្ហាត់បង្រៀនក្នុងគោលបំណង ដើម្បីបណ្តុះបណ្តាលនូវធនធានមនុស្សដ៏ល្អប្រពៃដែលជាទំពាំងស្នងឬស្សីជម្រុញឲ្យមាតុភូមិកម្ពុជាមានការអភិវឌ្ឍន៍ទៅថ្ងៃមុខ។

ជាពិសេសសម្តែងនូវការអរគុណជូនទៅដល់ លោកសាស្ត្រាចារ្យ បណ្ឌិត **អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យណែនាំ ដែលលោកបានលះបង់កម្លាំងកាយចិត្ត រួមទាំងពេលវេលាដ៏មានតម្លៃនៅក្នុងការបង្ហាត់បង្ហាញផ្លូវ តម្រង់ទិស ព្រមទាំងបំភ្លឺអំពីវិធីសាស្ត្រល្អៗ ដែលជម្រុញឲ្យកិច្ចការសារណានេះប្រព្រឹត្តទៅដោយរលូនចាប់តាំងពីពេលចាប់ផ្តើមរហូតដល់កិច្ចការសារណានេះត្រូវបានបញ្ចប់។

ឆ្លៀតពេលនេះដែរខ្ញុំបាទទាំងពីរនាក់សូមគោរពបួងសួងទៅដល់ទេវត្តា រួមទាំងវត្ថុស័ក្តសិទ្ធទាំងអស់តាមជួយថែរក្សាដល់អ្នកមានគុណទាំងទ្វេរឲ្យជួបតែ សេចក្តីសុខចម្រើន សំណាងល្អ សុខភាពល្អ អាយុយឺនយូរ ដើម្បីជាម្លប់ដល់កូនៗរស់នៅប្រកបដោយភាពត្រជាក់ ត្រជុំ សុខដុមរមនា។ សូមអ្នកមានគុណទាំងទ្វេរទទួលយកនូវការគោរពដឹងគុណនេះដោយក្តីអនុគ្រោះ និងដោយក្តីស្រលាញ់ប្រកបដោយភក្តីភាពដ៏ឧត្តុងឧត្តមជ្រាលជ្រៅជាទីបំផុត។

# អារម្ភកថា

បន្ទាប់ពី ខ្ញុំបាទទាំងពីរបានឆ្លងកាត់នូវការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងទៅនេះ គឺបានធ្វើឲ្យខ្ញុំបាទទាំងពីរទទួលបាននូវចំណេះដឹងជាច្រើនដែលមានគុណតម្លៃឥតគណនាបាន ដែលជាសក្ខីភាពនាំឲ្យខ្ញុំបានឈានមកដល់ការសរសេរសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។ គតិដែលនាំឲ្យខ្ញុំបាទសម្រេចចិត្តសរសេរសារណា គឺក្នុងបំណងចងក្រងក៏ដូចជាបង្កើតនូវស្នាដៃ ឬឯកសារទុកសម្រាប់បងប្អូននិស្សិតបញ្ញវ័ន្តជំនាន់ក្រោយជាជំនួយក្នុងការសិក្សាស្រាវជ្រាវ ដើម្បីជាធនធានចំណេះដឹង។

ដែលសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះប្រព្រឹត្តទៅក្រោមប្រធានបទ "ដំណោះស្រាយ និងវិធានការណ៍នៃការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ"។ គោលបំណងដែលខ្ញុំបាទទាំងពីរសម្រេចជ្រើសរើសនូវប្រធានបទដែលពាក់ព័ន្ធទៅនឹងបញ្ហាចរាចរណ៍នៅក្នុងរាជាធានីភ្នំពេញ ពីព្រោះខ្ញុំបាទទាំងពីរនាក់គិតថាបញ្ហានេះ គឺជាបញ្ហាដ៏ចម្បងដែលកំពុងនឹងកើតមានជារឿយៗនៅក្នុងសង្គមជាតិយើងសព្វថ្ងៃ បញ្ហានេះថែមទាំងបានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងក្លាទៅដល់សេដ្ឋកិច្ចជាតិ ហើយថែមទាំងបានរារាំងទៅដល់ការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូល។ នៅក្នុងខ្លឹមសារនៃប្រធានបទនេះ ខ្ញុំបាទទាំងពីរនាក់នឹងបង្ហាញអំពីមូលហេតុ និងដំណោះស្រាយពាក់ព័ន្ធទៅនឹងបញ្ហាកកចរាចរណ៍ដែលជាចំណុចគោលនៃសុវត្ថិភាពនៅលើដងផ្លូវក្នុងរាជធានីភ្នំពេញ ដែលទាំងនេះ គឺជាសុខសវត្ថិភាព និងអាយុជីវិតប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញក៏ដូចជាប្រជាពលរដ្ឋដែលបានឆ្លងកាត់ពីគ្រប់ទិសទីមកកាន់ភូមិសាស្ត្ររាជធានីភ្នំពេញផងដែរ។

ខ្ញុំបានសង្ឃឹមថាឯកសារមួយនេះអាចចាត់ទុកថាជាឯកសារជំនួយស្មារតីសម្រាប់អ្នកសិក្សាក្រោយៗទៀត តែទោះបីជាការខិតខំស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតដែលកើតមានឡើងជាមិនខាន ដូច្នេះខ្ញុំបាទទាំងពីរសូមស្វាគមន៍រាល់មតិយោបល់រិះគន់ស្ថាបនា ដើម្បីឲ្យសារណាមួយនេះមានភាពកាន់តែសុក្រឹត្តឡើង ដើម្បីក្លាយទៅជាឯកសារដ៏មានសារៈប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១ ស្ថានភាពចរាចរណ៍ក្នុងរាជធានីភ្នំពេញ

**១.១. បរិបទទូទៅនៃរាជធានីភ្នំពេញ** ........ ៤

**១.១.១. ប្រវត្តិនៃរាជធានីភ្នំពេញ** ........ ៤

**១.១.២. ស្ថានភាពនៃរាជធានីភ្នំពេញ** ........ ៥

**១.១.២.១. ទីតាំងភូមិសាស្ត្ររាជធានីភ្នំពេញ** ........ ៥

**១.១.២.២. ស្ថានភាពសេដ្ឋកិច្ចរាជធានីភ្នំពេញ** ........ ៦

**១.១.២.៣. បច្ចុប្បន្នភាពយានយន្ត និងកំណើនប្រជាជន** ........ ៦

**១.១.២.៤. ទិដ្ឋភាពគតិយុត្តពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍** ........ ៧

**១.២. កត្តាសំខាន់ៗដែលនាំឲ្យមានការកកស្ទះចរាចរណ៍** ........ ៨

**១.២.១. កត្តាយានយន្ត** ........ ៨

**១.២.២. កត្តាផ្លូវថ្នល់** ........ ៩

**១.២.៣. កត្តាមនុស្ស** ........ ១០

**១.២.៣.១. ការមិនគោរពភ្លើងសញ្ញាចរាចរណ៍** ........ ១០

**១.២.៣.២. ការមិនគោរពផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍** ........ ១០

**១.២.៣.៣. ការជិះបញ្ច្រាសរបស់អ្នកបើកបរ** ........ ១១

**១.២.៣.៤. ការប្រើប្រាស់ទូរសព្ទក្នុងពេលបើកបរ** ........ ១២

**១.២.៣.៥. ការមិនគោរពសិទ្ធិអាទិភាព** ........ ១២

**១.២.៣.៦. ការមិនចេះអធ្យាស្រ័យឱ្យគ្នា** ........ ១៣

**១.២.៣.៧. ការចិតផ្លូវ** ........ ១៣

**១.២.៣.៨. ការរំលោភលើចិញ្ចើមផ្លូវ** ........ ១៣

**១.២.៣.៩. កំណើន នៃការតម្រូវការយានយន្តរបស់ប្រជាពលរដ្ឋ** ........ ១៤

១.២.៣.១០. ការមិនចូលរួមប្រើប្រាស់សេវាសាធារណ: ..... ១៤
១.៣. គុណវិបត្តិនៃការកកស្ទះចរាចរណ៍ ..... ១៤
១.៣.១. ខាតពេលវេលា ..... ១៥
១.៣.២. បញ្ហាសតិអារម្មណ៍ ..... ១៥
១.៣.៣. ខាតសេដ្ឋកិច្ចជាតិ ..... ១៥


## ជំពូកទី ២

## ដំណោះស្រាយ និងវិធានការនៃការកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញ


២.១. ទីតាំង និងពេលវេលាកកស្ទះចរាចរណ៍ ..... ១៦
២.១.១. ចំណុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវ ..... ១៦
២.១.២. ចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារ ..... ១៧
២.១.៣. ពេលវេលានៃការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ ..... ១៨
២.២. ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ ..... ១៨
២.២.១. ការអប់រំ និងផ្សព្វផ្សាយ ..... ១៨
២.២.២. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ..... ១៩
២.២.២.១. ការរៀបចំផ្លូវថ្នល់ និងស្ពានអាកាស ..... ១៩
២.២.២.២. ការរៀបចំណាតរថយន្តក្រោមដី ..... ២១
២.២.៣. ការរៀបចំមធ្យោបាយធ្វើដំណើរសាធារណ: ..... ២២
២.២.៣.១ .រថយន្តក្រុង ..... ២២
២.២.៣.២ រថភ្លើងអាកាស ..... ២៤
២.២.៣.៣. ស្ពានអាកាសថ្មើរជើង ..... ២៤
២.២.៣.៤. ការដឹកជញ្ជូនតាមផ្លូវទឹក ..... ២៥
២.២.៤. ការកាត់បន្ថយការប្រើប្រាស់យានយន្ត ..... ២៦
២.២.៥. ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវ ..... ២៦
២.២.៦ ការចូលរួមរបស់ប្រជាពលរដ្ឋ ..... ២៧

២.២.៧. ការចូលរួមរបស់យុវជនស្ម័គ្រចិត្ត ..................... ៣០
២.២.៨. ការចូលរួមពីអង្គការដែលពាក់ព័ន្ធ ..................... ៣១
២.២.៩. ការអនុវត្តច្បាប់ ..................... ៣២
២.៣. វិធានការអនុវត្តចំពោះបញ្ហាកកស្ទះចរាចរណ៍ ..................... ៣៧
២.៣.១. ការណែនាំ និងចាត់វិធានការចំពោះបញ្ហាសណ្តាប់ធ្នាប់តាមដងផ្លូវ ..................... ៣៧
២.៣.២. ការប្រើប្រាស់កម្លាំងជាក់ស្តែង ..................... ៣៩
២.៣.៣. អំពីភារកិច្ចរបស់នគរបាលចរាចរណ៍ ..................... ៤០
២.៣.៤. បញ្ហាប្រឈមមួយចំនួនរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ..................... ៤២
២.៣.៥. ការហាមឃាត់ចំពោះរថយន្តធុនធ្ងន់ចេញ-ចូលរាជធានីភ្នំពេញពេលថ្ងៃ ..................... ៤៣
**សេចក្តីសន្និដ្ឋាន** ..................... ៤៥
**អនុសាសន៍** ..................... ៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

រាជធានីភ្នំពេញ គឺទីក្រុងដ៏ធំនៃព្រះរាជណាចក្រកម្ពុជា ដែលជាបេះដូងនៃសេដ្ឋកិច្ចជាតិទាំងមូល រាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហ៍កម្ម និងសិប្បកម្មដែលសុទ្ធសឹងតែជាវិស័យដែលទ្រទ្រង់នៅសេដ្ឋកិច្ចជាតិសំខាន់ៗ កត្តាចម្បងៗទាំងអស់នេះហើយបានធ្វើឲ្យប្រជាជននៅតាមបណ្តាខេត្តក្រុងនានាបានធ្វើចំណាកស្រុកមករស់នៅ ធ្វើការ ក៏ដូចជាប្រកបរបររកស៊ីសព្វគ្រប់បែបយ៉ាងនៅក្នុងរាជធានីភ្នំពេញ។ ជាពិសេសជាងនេះទៅទៀត ដោយផ្អែកទៅលើកត្តាភូមិសាស្ត្រអំណោយផលល្អ ធ្វើឲ្យរាជធានីភ្នំពេញក្លាយជាទីកន្លែងមួយដែលទាក់ទាញ អ្នកវិនិយោគិនមកពីបរទេសយ៉ាងច្រើនកុះករ ដែលកំណើននៃវិនិយោគទុនបរទេសច្រើននេះឯងជាសញ្ញាវិជ្ជមានមួយដល់សង្គមជាតិកម្ពុជាទាំងមូល ពោល គឺជាកត្តាលីករដែលជម្រុញឲ្យមាននូវកំណើនសេដ្ឋកិច្ចជាតិផ្តល់ឲ្យដល់ប្រជាពលរដ្ឋជាច្រើនមានការងារធ្វើ មានប្រាក់ចំណូលសមរម្យ ក៏ដូចជាមាននូវធនធានគ្រប់គ្រាន់សម្រាប់ចំណាយចាយវាយទៅលើរបស់របរប្រើប្រាស់ផ្សេងៗ រួមមានគ្រឿងអេឡិចត្រូនិច និងសម្លៀកបំពាក់ ជាពិសេស គឺមធ្យោបាយធ្វើដំណើររួមមានទោចក្រយាន្ត ក៏ដូចជារថយន្តជាដើម ដែលជាហេតុធ្វើឲ្យមានការកើនឡើងនូវយានយន្តឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំនៅក្នុងរាជធានីភ្នំពេញ។ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចជាតិមានការកើនឡើងឥតឈប់ឈរនេះផងដែរ វាក៏បានជះផលអវិជ្ជមានមួយចំនួនធំផងដែរ តួយ៉ាងដូចជាបញ្ហាកើនឡើងនូវចំនួនយានយន្តឥតគណនា ដើម្បីបំពេញនូវតម្រូវការជាមធ្យោបាយធ្វើដំណើររបស់ប្រជាជនដែលរស់នៅរាជធានីភ្នំពេញផ្ទាល់ក៏ដូចជាប្រជាពលរដ្ឋដែលផ្លាស់ទីលំនៅចូលមកកាន់ភូមិសាស្ត្ររាជធានីភ្នំពេញផ្ទាល់ ដែលកត្តាទាំងអម្បាលម៉ាណនេះបានបង្ករជាបញ្ហាដ៏ចម្បងមួយដល់រាជរដ្ឋាភិបាល ក៏ដូចជាសេដ្ឋកិច្ចជាតិនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល តួយ៉ាងបញ្ហាចរាចរណ៍ គឺជាបញ្ហាដ៏ធំមួយដែលរាជរដ្ឋាភិបាលបានដាក់ជាបញ្ហាអាទិភាពក្នុងការដោះស្រាយ។ ដូច្នេះហើយនៅក្នុងខ្លឹមសារនៃអត្ថបទសារណាបញ្ចប់ការសិក្សាមួយនេះនឹងបង្ហាញដល់ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បងប្អូននិស្សិតបញ្ញវ័ន្ត រួមទាំងមិត្តអ្នកអានទាំងអស់អំពីអត្ថន័យគោលធំៗចំនួនពីដែលបែងចែកតាមជំពូក ពោល គឺ “ **កត្តាដែលនាំឲ្យមាននូវការកកស្ទះចរាចរណ៍ និងដំណោះស្រាយវិធានការនៃបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ**” ។

**ក. គោលបំណងនៃការស្រាវជ្រាវ**

ចំពោះខ្លឹមសារប្រធានបទមួយនេះ គឺមានគោលបំណងសំខាន់ជាការពញ្ញាក់អារម្មណ៍ដល់បងប្អូនប្រជាពលរដ្ឋកម្ពុជាទាំងអស់ឱ្យមកចាប់អារម្មណ៍ទៅលើបញ្ហាកកស្ទះចរាចរណ៍ដែលកំពុងតែញាំញីមកលើសង្គមជាតិក៏ដូចជាប្រជាពលរដ្ឋកម្ពុជាស្ទើរគ្រប់មជ្ឈដ្ឋាន តួយ៉ាងការកកស្ទះចរាចរណ៍វាបានធ្វើឲ្យប្រជាពលរដ្ឋយើងមានការខាតបង់យ៉ាងច្រើនទៅលើពេលវេលា ថវិការ និងបញ្ហាសតិអារម្មណ៍ដែលជាបញ្ហាដ៏ខ្លាំងក្លាមួយដែលប្រជាជនទាំងអស់មិនគួរគប្បីមើលរំលងឡើយ ជាពិសេសជាងនឹងទៅទៀតវាកំពុងក្លាយទៅជាបញ្ហាដ៏ធំធេងមួយរារាំងទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិទាំងមូល។

**ខ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ**

ចំពោះទិដ្ឋភាពជាក់ស្តែងនៃប្រធានបទខាងលើនេះ ការស្រាវជ្រាវនឹងលើកយកមកបង្ហាញពីទិដ្ឋភាពនានាដែលពាក់ព័ន្ធនឹងបញ្ហាកកស្ទះចរាចរណ៍ ការអនុវត្តតាមផែនការដំណោះស្រាយរបស់អាជ្ញាធរនៅក្នុងរាជធានីភ្នំពេញ និងដំណោះស្រាយទូទៅដ៏សមស្របមួយដែលយើងទទួលបានបន្ទាប់ពីការសិក្សាផ្សេងៗ ក៏ដូចជាការចូលរួមពីប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធ ការអនុវត្តរបស់អ្នកអនុវត្តច្បាប់ចរាចរណ៍។

**គ. សារៈសំខាន់នៃការស្រាវជ្រាវ**

កិច្ចការស្រាវជ្រាវមួយនេះ ទុកជាឯកសារជំនួយស្មារតីដល់បងប្អូននិស្សិតបញ្ញាវន្តក៏ដូចជាមិត្តអ្នកអានសិក្សាស្វែងយល់អំពីបញ្ហាកកស្ទះចរាចរណ៍ ស្វែងយល់ពីទិដ្ឋភាពជាក់ស្តែងអំពីស្ថានភាពចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ កត្តាដែលនាំឲ្យមានការកកស្ទះចរាចរណ៍ ផលវិបាកដែលបង្កឡើងដោយការកកស្ទះចរាចរណ៍ រួមទាំងដំណោះស្រាយ និងវិធានការនៃការកកស្ទះចរាចរណ៍។ ជាពិសេសជាងនេះ តាមរយៈខ្លឹមសារអត្ថបទនេះទៀតសោតក៏បានដាស់តឿន និងពញ្ញាក់អារម្មណ៍ដល់អ្នកដែលបានអានអត្ថបទនេះ ឲ្យងាកមកចាប់អារម្មណ៍អំពីបញ្ហានេះហើយចូលរួមសហការជាមួយអាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ច ដើម្បីរួមគ្នាកាត់បន្ថយបញ្ហានៃការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ ក៏ដូចជាធ្វើឱ្យស្ថានភាពចរាចរណ៍នៅក្នុងភូមិសាស្ត្រនៃរាជធានីភ្នំពេញមានភាពល្អប្រសើរឡើង។ ក្នុងខ្លឹមសារនៃអត្ថបទស្រាវជ្រាវនេះ គឺធ្វើឡើងដោយការសិក្សាស្រាវជ្រាវស្វែងរកឯកសារពីស្ថាប័នពាក់ព័ន្ធរួមទាំងសាលាក្រុងភ្នំពេញ ក៏ដូចជាការិយាល័យរបស់នគរបាលចរាចរណ៍ផ្លូវគោកជាដើម គួបផ្សំជាមួយសម្រង់នូវអត្ថបទដែលចេញពីគេហទំព័រផ្លូវការរបស់ស្ថាប័នទាំងឡាយដែលពាក់ព័ន្ធ។

**ឃ. វិធីសាស្ត្រក្នុងការស្រាវជ្រាវ**

ដោយសារតែប្រធានបទមួយនេះ ជាប្រធានបទដ៏មានប្រជាប្រិយភាពហើយក៏ជាប្រធានបទដែលមានការឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងដែលបង្ហាញអំពីបញ្ហារកកស្ទះចរាចរណ៍ និងដំណោះស្រាយផ្សេងៗផងនោះ

ដូច្នេះការស្រាវជ្រាវអំពីប្រធានបទមួយនេះឡើង គឺឆ្លងកាត់នូវការសម្រិតសម្រាងយ៉ាងហ្មត់ចត់តាមរយៈការស្វែងរកឯកសារ ទៅតាមគ្រប់មធ្យោបាយដូចជា ការស្វែងរកឯកសារពីបណ្ណាល័យ ក៏ដូចជាការចុះទៅស្នើរសុំឯកសារផ្ទាល់ពីស្ថាប័នពាក់ព័ន្ធ រួមទាំងការដកស្រង់ខ្លឹមសារពីសៀវភៅដែលបង្ហាញពីទ្រឹស្តីដែលពាក់ព័ន្ធ។ ក្រៅពីនេះខ្ញុំបាទទាំងពីរនាក់ក៏បានសិក្សាស្រាវជ្រាវឯកសារពីគេហទំព័រផ្លូវការរបស់ក្រសួង ស្ថាប័ននានាដែលពាក់ព័ន្ធតាមរយៈបណ្តាញអ៊ីនធើណេតផងដែរ។

**ង. រចនាសម្ព័ន្ធនៃប្រធានបទ**

ដោយសមស្របទៅតាមគោលការណ៍ ក្បួនច្បាប់ ក៏ដូចជាទម្រង់នៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ គឺតម្រូវមកឲ្យមាននូវការបង្ហាញឲ្យបានច្បាស់អំពីរចនាសម្ព័ន្ធនៃប្រធានបទ ដូច្នេះហើយខ្ញុំបាទទាំងពីនាក់ ដែលជាអ្នករៀបរៀងនូវកិច្ចការសារណាមួយច្បាប់នេះឡើងបានធ្វើការបែងចែកនូវរចនាសម្ព័ន្ធនៃប្រធានបទនេះជាពីរជំពូកធំៗ គឺ៖

- **ជំពូកទី១ បញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ៖** ក្នុងជំពូកនេះនឹងលើកឡើងអំពីស្ថានភាពទូទៅនៃរាជធានីភ្នំពេញ កត្តាសំខាន់ៗដែលនាំឲ្យមានការកកស្ទះចរាចរណ៍ និងគុណវិបត្តិនៃការកកស្ទះចរាចរណ៍។
- **ជំពូកទី២ ដំណោះស្រាយ និងវិធានការនៃការកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ៖** ក្នុងជំពូកនេះលើកឡើងអំពីទីតាំងកកស្ទះចរាចរណ៍ ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ និងវិធានការអនុវត្តចំពោះបញ្ហាកកស្ទះចរាចរណ៍។

# ជំពូកទី១
# ស្ថានភាពចរាចរណ៍ក្នុងរាជធានីភ្នំពេញ

# ជំពូកទី១ ស្ថានភាពចរាចរណ៍ក្នុងរាជធានីភ្នំពេញ

## ១.១. បរិបទទូទៅនៃរាជធានីភ្នំពេញ

### ១.១.១. ប្រវត្តិនៃរាជធានីភ្នំពេញ

ដើម្បីជាស្ពានឈានទៅរកការសិក្សាស្វែងយល់អំពីគោលគំនិតនៃប្រធានបទសារណាដែលពាក់ព័ន្ធទៅនឹងបញ្ហាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញនេះ យើងខ្ញុំសូមបង្ហាញក៏ដូចជារៀបរាប់នូវប្រវត្តិនៃរាជធានីភ្នំពេញជូនដល់ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ បងប្អូននិស្សិតបញ្ញាវ័ន្ត រួមទាំងមិត្តអ្នកអានគ្រប់ស្រទាប់វណ្ណៈទាំងអស់ឲ្យបានជ្រួលជ្រាបជាមុនសិន។

រាជធានីភ្នំពេញ ត្រូវបានរកឃើញដោយដូនចាស់ម្នាក់ដែលមានព្រះនាមថា ពេញ (ដូនពេញ) នៅក្នុងឆ្នាំ១៣៧២ ពោល គឺឈ្មោះនៃទីក្រុងនេះមកពីឈ្មោះរបស់ដូនពេញនេះឯង។ រាជធានីភ្នំពេញបានក្លាយជារាជធានីរបស់ព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ ១៨៦៤ រហូតមកដល់បច្ចុប្បន្ននេះ។ ដោយឆ្លងកាត់ជាច្រើនសម័យកាល និងរបបនយោបាយបានធ្វើឲ្យស្ថានភាពនៅក្នុងរាជធានីភ្នំពេញមានភាពប្រែប្រួលមិនស្ថិតស្ថេរឡើយ ពោល គឺនៅមុនរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅក្នុងរាជធានីភ្នំពេញមានភាពសុខសាន្ត និងមានការអភិវឌ្ឍយ៉ាងខ្លាំងតែក្រោយមកចាប់តាំងពីថ្ងៃដែលប្រទេសកម្ពុជាទាំងមូលត្រូវបានគ្រប់គ្រងដោយអង្គការខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានធ្វើឱ្យប្រទេសកម្ពុជាទាំងមូលធ្លាក់ក្នុងស្ថានភាពដុនដាបជាទីបំផុត រីឯទីក្រុងភ្នំពេញដែលធ្លាប់តែជាទីកន្លែងដ៏វិសិទ្ធ មានមនុស្សម្នាអ៊ូអរសម្បូរសប្បាយ និងមានការរីកចម្រើនយ៉ាងត្រចះត្រចង់បានប្រែមកទៅជាទីកន្លែងមួយដែលមានសភាពស្ងាត់ជ្រងំប្រៀបបាននឹងទីក្រុងខ្មោចដែលត្រូវបានគេបោះបង់ចោលក្រោមការដឹកនាំគ្រប់គ្រងដោយរបបវាលពិឃាតដ៏ខ្មៅងងឹតខ្មែរក្រហម។ ទោះជាយ៉ាងណាក៏ដោយក្រោមការដឹកនាំនៃរបបប្រល័យពូជសាសន៍ដ៏សាហាវឃោឃៅមួយនេះមិនមានភាពស្ថិតស្ថេរនោះទេ គឺអស់នូវកាលវេលាចំនួន បីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ របបមួយនេះក៏ត្រូវបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលទីក្រុងភ្នំពេញត្រូវបានរំដោះបានដោយជោគជ័យ ហើយពេលនោះដែរក៏ជាពេលមួយដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានរួចផុតពីរបបប្រល័យពូជសាសន៍ ហើយរាជធានីភ្នំពេញទាំងមូលត្រូវបានស្តារឡើងវិញឲ្យមាននូវភាពរីកចម្រើនរហូតមកដល់សព្វថ្ងៃនេះ។

រហូតមកទល់នឹងបច្ចុប្បន្ននេះរាជធានីភ្នំពេញមានការកែប្រែព្រំប្រទល់ចំនួន ៤ ដំណាក់កាលមកហើយ។ ដែលការកែសម្រួលព្រំប្រទល់នោះមានដូចជា ៖

- លើកទី១ ៖ ការបញ្ចូលស្រុកដង្កោរ
- លើកទី២ ៖ ការបង្កើតខណ្ឌឫស្សីកែវ។

- លើកទី៣ ៖ ការបញ្ចូល៤ភូមិ របស់ឃុំកន្ទោក មកក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ។[1]
- លើកទី៤ ៖ ការបញ្ចូល២០ឃុំ របស់ស្រុកទាំង៥ ( ពញាឮ, មុខកំពូល, កៀនស្វាយ, កណ្តាលស្ទឹង, អង្គស្នួល ) នៃខេត្តកណ្តាលមកក្នុងដែនដីរដ្ឋបាលនៃរាជធានីភ្នំពេញ។[2]

ភ្នំពេញជារាជធានីរបស់ព្រះរាជាណាចក្រកម្ពុជា ហើយជាទីក្រុងដែលធំជាងគេនៅក្នុងប្រទេសកម្ពុជា ដែលមានចំនួនប្រជាជនជិត២លាននាក់នៅក្នុងឆ្នាំ២០១៧។ ភ្នំពេញត្រូវបានចាត់ទុកជាមជ្ឈមណ្ឌលធ្វើជំនួញ ពាណិជ្ជកម្ម ឧស្សាហកម្ម និងមានបណ្តុំសំណង់អគារធំៗជាច្រើន រួមបញ្ចូលទាំងផ្សារ និងផ្សារទំនើបដែលធំជាងគេនៅក្នុងប្រទេសកម្ពុជា។ ក្រៅពីនេះ គេឃើញមានសកលវិទ្យាល័យធំៗនានា ព្រលានយន្តហោះអន្តរជាតិ កំពង់ផែ ផ្លូវទឹក និងមធ្យោបាយធ្វើដំណើរផ្លូវគោកសម្រាប់ផ្គត់ផ្គង់ការដឹកជញ្ជូន និងផ្ទុកទំនិញផ្សេងៗ និងជាកន្លែងទេសចរណ៍ដែលទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិបានច្រើនជាងគេបន្ទាប់ពីខេត្តសៀមរាប។[3]

### ១.១.២. ស្ថានភាពនៃរាជធានីភ្នំពេញ

#### ១.១.២.១. ទីតាំងភូមិសាស្ត្ររាជធានីភ្នំពេញ

រាជធានីភ្នំពេញស្ថិតនៅតំបន់ខាងត្បូងភាគកណ្តាលនៃប្រទេសកម្ពុជា ដែលប្រសព្វនៅទន្លេធំៗ ៣ ជាប់ដៃទន្លេ ៤ នៃទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់។ ដែលទន្លេទាំងនេះបានផ្តល់នូវ ប្រព័ន្ធអេកូឡូស៊ីទឹកសាប និងជាទន្លេប្រកបដោយសក្តានុពល ជាធនធាន ដ៏សំខាន់សម្រាប់លក្ខខណ្ឌបរិស្ថានប្រកបដោយចិរភាព សោភ័ណ្ឌភាពធម្មជាតិ។ នៅក្នុងរាជធានីភ្នំពេញមានការប្រែប្រួលអាកាសធាតុបន្តិចបន្តួចប៉ុណ្ណោះ កម្រិតស៊ីតុណ្ហភាពនៅក្នុងរាជធានីភ្នំពេញមានចាប់ពី១៨ អង្សារសេ ដល់៣៨ អង្សារសេ ( ៦៤ ដល់ ១០០ អង្សារ ហ្វារិនហាយ )។

រាជធានីភ្នំពេញមានផ្ទៃដីសរុបចំនួន ៦៩២,៤៦ គីឡូម៉ែត្រក្រឡា។ ចំពោះប្រជាជននៅក្នុងរាជធានីភ្នំពេញសរុប ១.៤៧០.៣០៣ នាក់(ឆ្នាំ២០១៨) ក្នុងនោះស្ត្រីចំនួន ៩៦០.០៨១ នាក់ ដែលស្មើរនឹង ៣០៥.៧៦៧ គ្រួសារ។ រីឯដង់ស៊ីតេប្រជាជននៅក្នុងរាជធានីភ្នំពេញមានចំនួនស្មើរនឹង ២.២១៣ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ រាជធានីភ្នំពេញត្រូវបានបែងចែកចេញជា ១៤ ខណ្ឌគឺ

- ខណ្ឌដូនពេញ
- ខណ្ឌទួលគោក

[1] ព្រះរាជក្រឹតលេខ០៧០៦/៣២៩ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការកែប្រែព្រំប្រទល់រាជធានីភ្នំពេញ និងខេត្តកណ្តាល

[2] http://phnompenh.gov.kh(ថតចម្លង់នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០)

[3] http://phnompenh.gov.kh(ថតចម្លង់នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០)

- ខណ្ឌ៧មករា
- ខណ្ឌដង្កោ
- ខណ្ឌមានជ័យ
- ខណ្ឌឬស្សីកែវ
- ខណ្ឌពោធិ៍សែនជ័យ
- ខណ្ឌសែនសុខ
- ខណ្ឌចំការមន
- ខណ្ឌច្បារអំពៅ (ថ្មី)
- ខណ្ឌជ្រោយចង្វារ (ថ្មី)
- ខណ្ឌព្រែកព្នៅ (ថ្មី)
- ខណ្ឌបឹងកេងកង (ថ្មី)
- ខណ្ឌកំបូល (ថ្មី)។[4]

**១.១.២.២. ស្ថានភាពសេដ្ឋកិច្ចរាជធានីភ្នំពេញ**

រាជធានីភ្នំពេញត្រូវបានគេចាត់ទុកថាជាបេះដូងនៃសេដ្ឋកិច្ចជាតិកម្ពុជាទាំងមូល ដូច្នេះហើយខ្ញុំសូមដកស្រង់អត្ថបទទាំងស្រុងតាមរបាយការណ៍ប្រចាំឆមាសនៅក្នុងគេហទំព័រផ្លូវការរបស់ធនាគារពិភពលោកដោយបានបង្ហាញអំពីរបកគំហើញមួយចំនួនពាក់ព័ន្ធនឹងសេដ្ឋកិច្ចនៅកម្ពុជាដូចខាងក្រោម៖

យោងតាមរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាចុងក្រោយរបស់ធនាគារពិភពលោកដែលបានចេញផ្សាយនៅខែតុលា ឆ្នាំ២០១៩ គឺស្ថិតនៅខ្ទង់ ៧%។ អត្រាកំណើន៧% នេះ គឺបានធ្លាក់ចុះ 0.៥% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨។ ទោះជាយ៉ាងណាក៏ដោយក្តី របាយការរបស់ធនាគារពិភពលោកបានអះអាងថា សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២០នេះ នៅតែបន្តស្វាហាប់។[5]

**១.១.២.៣. បច្ចុប្បន្នភាពយានយន្ត និងកំណើនប្រជាជន**

រយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជារក្សាបាននូវកំណើនសេដ្ឋកិច្ច៧%ជារៀងរាល់ឆ្នាំដែលកំណើនសេដ្ឋកិច្ចបែបនេះ បានធ្វើឲ្យជីវភាពប្រជាពលរដ្ឋដែលមានចំណូលកម្រិតមធ្យមមានសភាពប្រសើរឡើង ពោល គឺ

[4] http://phnompenh.gov.kh (ថតចម្លង់នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០)
[5] របាយការណ៍របស់ធនាគាពិភពលោក ចុះផ្សាយថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩

គ្រប់ក្រុមគ្រួសារនីមួយៗមានលទ្ធភាពស្វែងរកចំណូល ដើម្បីទិញរថយន្តឯកជនផ្ទាល់ខ្លួនយកមកប្រើប្រាស់បាន ។ កំណើនតម្រូវការប្រើប្រាស់រថយន្តនៅកម្ពុជាមានការកើនឡើងបែបនេះ ជាកត្តាសំខាន់ធ្វើឲ្យក្រុមហ៊ុនរថយន្តល្បីៗមួយចំនួនបានដាក់ការចាប់អារម្មណ៍មកលើទីផ្សារកម្ពុជា។ បច្ចុប្បន្ននេះ កម្ពុជាបាននាំចូលរថយន្តស្ទើរតែគ្រប់ប្រភេទ ដើម្បីបំពេញតម្រូវការក្នុងស្រុកដែលភាគច្រើននាំចូលមកពីប្រទេសដែលជាដៃគូដូចជា ជប៉ុន ថៃ ចិន កូរ៉េខាងត្បូង សហរដ្ឋអាមេរិក និងបណ្តាប្រទេសមួយចំនួនទៀតនៅសហភាពអឺរ៉ុប។

យោងតាមស្ថិតិរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន គិតត្រឹមខែធ្នូឆ្នាំ២០១៩ ស្ថិតិយានយន្តក្នុងរាជធានីភ្នំពេញមានរថយន្តចំនួន៥០៨,១៤៣គ្រឿង និងទោចក្រយានយន្តចំនួន១,៩៦៦,៣២២គ្រឿង។ ចំនួនប្រជាជនក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្នបានកើនឡើងដល់ ២,១២៩, ៣៧១នាក់។[6]

**១.១.២.៤. ទិដ្ឋភាពគតិយុត្តពាក់ព័ន្ធនឹងបញ្ហាចរាចរណ៍**

នៅក្នុងអំឡុងមុនឆ្នាំ១៩៩៣ កម្ពុជាមិនទាន់បានរួចផុតពីបញ្ហាសង្គ្រាមស៊ីវិលផ្ទៃក្នុងនោះទេ ជាមូលហេតុដែលធ្វើឲ្យរាជធានីភ្នំពេញមានសភាពស្ងប់ស្ងាត់ មិនសូវមានយានយន្តច្រើនធ្វើដំណើរនោះទេ ហើយជាក់ស្តែងសូម្បីតែបញ្ហាកកស្ទះចរាចរណ៍ក៏មិនទាន់បានកើតមានឡើងនោះឡើយ។ ប៉ុន្តែក្រោយពីទទួលបាននូវភាពសុខសាន្តពេញលេញ និងការឈានជើងចូលទៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរីរួចមក កម្ពុជាបានអភិវឌ្ឍនូវវិស័យជាច្រើនដូចជា វិស័យពាណិជ្ជកម្ម រោងចក្រ សហគ្រាស វិស័យអប់រំ ទូរគមនាគមន៍ កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាពិសេសការធ្វើឲ្យវត្តមាននៃការវិនិយោគរបស់បរទេសមកកម្ពុជាសំដៅមករាជធានីភ្នំពេញ ជាកត្តាបង្កឲ្យរាជធានីភ្នំពេញមានការរីកចម្រើនយ៉ាងឆាប់រហ័ស។

ទន្ទឹមនឹងការរីកចម្រើននៃសង្គមជាតិនាយុគសម័យថ្មីនេះ យើងឃើញថាមានការកើនឡើងឥតឈប់ឈរនូវតម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងការកើនឡើងជាបន្តបន្ទាប់ឥតដាច់នៃកំណើនប្រជាជននៅក្នុងរាជធានីភ្នំពេញ បានជម្រុញឲ្យមាននូវកំណើននូវមធ្យោបាយធ្វើដំណើរ រួមមានយានយន្តគ្រប់ប្រភេទផងនោះបានធ្វើឲ្យរាជធានីភ្នំពេញត្រូវប្រឈមនឹងបញ្ហាចរាចរណ៍ជារៀងរាល់ថ្ងៃ។ បញ្ហាចរាចរណ៍នេះទៀតសោត កំពុងតែជាបញ្ហាក្តៅដែលជះឥទ្ធិពលយ៉ាងខ្លាំងខ្លាទៅដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក៏ដូចជាប៉ះពាល់ស្ទើរគ្រប់វិស័យរួមទាំងបានធ្វើឲ្យមានការត្អូញត្អែរពីសំណាក់ប្រជាពលរដ្ឋ និងជាបញ្ហាប្រឈមដ៏សំខាន់ដែលរដ្ឋាភិបាលកំពុងរកដំណោះស្រាយ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកំពុងតែកើតមានទាំងនេះ កម្ពុជាយើងក៏មាននូវលិខិតបទដ្ឋានគតិយុត្តជាច្រើនបានប្រតិដ្ឋឡើង ដើម្បីជារនាំងកំណត់ពីព្រំដែននៃការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងគោលបំណងធានាធ្វើឱ្យសង្គមជាតិទាំងមូលមានការរស់នៅប្រកបដោយភាពចុះសម្រុងនឹងគ្នាមានសន្តិភាព ភាពសុខ

[6] ជំរឿនទូទៅប្រជាជននៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងសាធារណៈការ

សាន្ត ជាពិសេសការលប់បំបាត់នូវបញ្ហានានាដែលបានបង្កជាការលំបាកដល់ប្រជាពលរដ្ឋ។ ចំពោះបញ្ហាចារាចរណ៍វិញ យើងឃើញមានច្បាប់ អនុក្រឹត្យ និងសេចក្តីណែនាំជាច្រើនបានលេចចេញជារូបរាងបន្តបន្ទាប់គ្នាដើម្បីធានានូវការគោរពច្បាប់ឲ្យមានប្រសិទ្ធិភាព ជាក់ស្តែងយើងឃើញមានលិខិតបទដ្ឋានសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- ច្បាប់ចរាចរណ៍ផ្លូវគោកចុះថ្ងៃទី ០៦ មករា ឆ្នាំ២០១៥ និង ច្បាប់ស្តីពីផ្លូវថ្នល់ចុះថ្ងៃទី ០៤ ឧសភា ឆ្នាំ២០១៤
- ព្រះរាជក្រមលេខ នស/រកម/០១១៧/00២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីវិសោធនកម្មច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។
- អនុក្រឹត្យលេខ៣៩ ស្តីពីការកែប្រែអនុក្រឹតលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក។
- ផែនការសកម្មភាព របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ។ល។

## ១.២. កត្តាសំខាន់ៗដែលនាំឲ្យមានការកកស្ទះចរាចរណ៍

ស្របពេលដែលរាជធានីភ្នំពេញកំពុងតែមានភាពរីកចម្រើនស្ទើរគ្រប់វិស័យក៏ដោយក៏ចំណុចអវិជ្ជមានមួយត្រូវបានលេចឡើងជាផលវិបាក និងជាកត្តាសំខាន់ដែលរដ្ឋកំពុងតែយកចិត្តទុកដាក់ដោះស្រាយនោះគឺបញ្ហាកកស្ទះចរាចរណ៍។ ជារៀងរាល់ថ្ងៃ ជាពិសេសនៅពេលម៉ោងធ្វើដំណើរទៅធ្វើការ ឬត្រលប់មកពីបំពេញការងារវិញ រាជធានីភ្នំពេញទាំងមូលហាក់បីដូចជាមានភាពអួរអាប់ពោរពេញដោយសំឡេងមនុស្សត្រហឹងអឹងកងព្រមទាំងផ្សែងដែលភាយចេញពីយានជំនិះរបស់ប្រជាពលរដ្ឋបង្កបានជាការបំពុលបរិស្ថានមួយដ៏សម្បើម។

តាមការសិក្សាស្រាវជ្រាវបានរកឃើញកត្តាមួយចំនួនដែលបង្កឲ្យមានការកកស្ទះចរាចរណ៍ គឺកត្តាយានយន្ត កត្តាផ្លូវថ្នល់ និងកត្តាមនុស្ស។

### ១.២.១. កត្តាយានយន្ត

សន្តិភាព និងការអភិវឌ្ឍប្រកបដោយមោទនភាពក្នុងនាមជាម្ចាស់ប្រទេសបានក្លាយជាមូលហេតុបណ្តាលឲ្យវត្តមានរោងចក្រ សហគ្រាសតូចធំជាច្រើនបានកើតឡើងនៅគ្រប់ទីប្រជុំជននានាក្នុងប្រទេសកម្ពុជាដែលធ្វើអោយប្រទេសកម្ពុជាមានការរីកចម្រើនជាខ្លាំង ហើយក៏មានតម្រូវការយានយន្តជាច្រើនក្នុងការប្រើប្រាស់។ ក្នុងនោះដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់នៅក្នុងប្រទេស ទើបធ្វើឱ្យមានការនាំចូលនូវមធ្យោបាយដឹកជញ្ជូន និងមធ្យោបាយធ្វើដំណើរទំនើបជាច្រើនសម្បូរបែប ដែលធ្វើឱ្យមានការកើនឡើងជាបន្តបន្ទាប់នៃចំនួនយានយន្ត និងទោចក្រយានយន្ត។ គេសន្និដ្ឋានថាបណ្តាលមកពីកត្តាជីវភាពរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរឡើងទើបធ្វើឱ្យមានការកើនឡើងនូវចំនួនយានយន្តជាច្រើនសន្ធឹកសន្ធាប់ ជាក់ស្តែង

បច្ចុប្បន្ននេះបើយើងសង្កេតមើលពីជីវភាពរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងរង្វង់គ្រួសារនីមួយៗរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ ជាមធ្យមយ៉ាងហោចណាស់ក្នុងមួយគ្រួសារក៏មានរថយន្តចំនួន១គ្រឿងដែរ ហើយខ្លះទៀតមានរហូតទៅដល់២ ឬ៣ គ្រឿងឯណោះ។ ការកើនឡើងនូវចំនួនយានជំនិះគ្រប់ប្រភេទនៅក្នុងរាជធានីភ្នំពេញ ដែលកំពុងតែចរាចរណ៍នៅតាមដងវិថីនានានោះ ធ្វើឱ្យទំហំនៃការប្រើប្រាស់ផ្លូវរបស់អ្នកធ្វើដំណើរកាន់តែតូចទៅៗ ដែលជាកត្តាបណ្តាលឲ្យដងវិថីទាំងមូលស្ទើរតែគ្មានកន្លែងសម្រាប់ធ្វើដំណើរជាពិសេសនៅរៀងរាល់ម៉ោងចេញ ឬចូលបំពេញការងារ។

ម្យ៉ាងវិញទៀតនោះ អ្វីដែលគួរឲ្យកត់សម្គាល់អំពីផ្នត់គំនិតរបស់ប្រជាពលរដ្ឋកម្ពុជាក្នុងការជ្រើសរើសយកប្រភេទរថយន្តសម្រាប់តែការធ្វើដំណើរលក្ខណៈគ្រួសារវិញនោះ គឺពួកគេតែងតែធ្វើការជ្រើសរើសយកប្រភេទរថយន្តដែលមានលក្ខណៈសម្បត្តិចំពោះតែរូបរាងខាងក្រៅ ទំហំ ឬក៏តម្លៃតែប៉ុណ្ណោះ។ ជាទូទៅពួកគាត់មិនបានសម្លឹងឃើញអំពីអត្ថប្រយោជន៍ ស្ថានភាពភូមិសាស្ត្រ ភាពងាយស្រួលនៃការធ្វើដំណើរ ឬការដឹកជញ្ជូនដែលរថយន្តនោះបានផ្តល់មកឲ្យខ្លួនវិញនោះទេ ជាក់ស្តែងរថយន្តដែលមានរូបរាងធំៗ ដូចជាប្រភេទ Lexus, Tuntra , Ford F-150 Raptor ជាដើម ត្រូវបានចរាចរពាសពេញរាជធានីភ្នំពេញ ដែលតាមពិតទៅប្រភេទរថយន្តទាំងអស់នោះធ្វើឱ្យអ្នកបើកបរជួបប្រទះនឹងបញ្ហាដូចជា ពិបាកក្នុងការស្វែងរកកន្លែងចត ដែលជាផ្នែកមួយក្នុងការចូលរួមឲ្យបញ្ហាកកស្ទះចរាចរណ៍កាន់តែមានភាពស្មុគស្មាញ។

**១.២.២. កត្តាផ្លូវថ្នល់**

ចំពោះរាជធានីភ្នំពេញ ផ្លូវថ្នល់ប្រៀបបាននឹងសរសៃឈាមដែលមិនអាចនឹងខ្វះបាន ហើយបាននឹងកំពុងតែឆ្លើយតបទៅនឹងតម្រូវការឥតឈប់ឈររបស់អ្នកធ្វើដំណើរ។ ដោយសារតែកម្ពុជាទើបតែទទួលបានការអភិវឌ្ឍក្រោយពេលដែលបានបញ្ចប់នូវសង្គ្រាមស៊ីវិលនៅក្នុងអំឡុងឆ្នាំ១៩៩៣ ហេតុដូច្នេះហើយ ប្រព័ន្ធគមនាគមន៍មួយចំនួនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅឡើយនោះទេ។ បើយើងក្រឡេកមើលចំពោះទិដ្ឋភាពនៅក្នុងរាជធានីភ្នំពេញវិញ យើងអាចសង្កេតឃើញថា នៅមានបណ្តាផ្លូវជាច្រើនត្រូវបានសាងសង់ដោយពុំមានស្តង់ដារបច្ចេកទេសច្បាស់លាស់ គ្មានការបំពាក់នូវស្លាកសញ្ញាចរាចរណ៍ឲ្យបានត្រឹមត្រូវ គ្មានការគិតគូរពីទំហំផ្លូវប្រៀបធៀបនឹងស្ថានភាពចរាចរណ៍ដែលកំពុងតែបើកបរជារៀងរាល់ថ្ងៃ ហើយផ្លូវខ្លះទៀតត្រូវបានខូចខាត ដែលទាមទារឲ្យអាជ្ញាធរមានសមត្ថកិច្ចចាំបាច់ត្រូវតែគិតគូរឲ្យបានទាន់ពេលវេលា។ ជាការពិតមែនហើយ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតែដើរតួនាទីដ៏សំខាន់ក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ ហើយបើផ្លូវថ្នល់តូចនោះ អ្នកបើកបរពិតមានភាពលំបាកហើយបង្ករជាការកកស្ទះគួរឲ្យធុញទ្រាន់ជាក់ជាមិនខាន ម្យ៉ាងទៀតដោយសារតែប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅតែមានទម្លាប់រុលទៅមុខដោយមិនបានគិតគូរពីអ្នកដទៃដែលនៅជុំវិញខ្លួនបែបនេះហើយ ដូច្នេះស្ថានភាពផ្លូវតូចៗមួយចំនួនពិតជាបង្កឲ្យស្ថានភាពកកស្ទះចរាចរណ៍

កាន់តែធ្ងន់ធ្ងរទៅពីមួយថ្ងៃទៅមួយថ្ងៃ។ មូលហេតុដ៏ចម្បងមួយដែលបង្កជាការកកស្ទះចរាចរណ៍ គឺការជួសជុលផ្លូវ ហើយវាក៏ជាកត្តាដ៏ចម្បងមួយដែលរួមចំណែកធ្វើឱ្យអ្នកធ្វើដំណើរមានផលវិបាកជាខ្លាំង ព្រោះនៅលើផ្លូវសុទ្ធតែគ្រឿងចក្រជួសជុលផ្លូវ ដូចនេះបង្កឱ្យការធ្វើដំណើរយឺតយ៉ាវហើយថែមទាំងធ្វើឱ្យស្ទះចរាចរណ៍ទៀតផង ។

**១.២.៣. កត្តាមនុស្ស**

កត្តាមួយដែលត្រូវបានគេតែងតែលើកឡើងថា ជាកត្តាសំខាន់បំផុតដែលបង្កឲ្យមានការកកស្ទះចរាចរណ៍នោះ គឺឥរិយាបថរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់។ កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍ ដូច្នេះហើយស្ថានភាពនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិតនៅឡើយ តួយ៉ាងបើយើងក្រឡេកទៅមើលក្នុងទិដ្ឋភាពចរាចរណ៍កម្ពុជាវិញ អ្នកបើកបរមួយចំនួនពុំបានយល់ដឹងពីច្បាប់ចរាចរណ៍នោះឡើយ ដោយពួកគេខ្លះគ្មានបណ្ណបើកបរ ខ្លះមិនស្គាល់ពីសិទ្ធិអាទិភាពរបស់ខ្លួននៅលើដងវិថី ខ្លះបើកបរបញ្ច្រាសទិស ខ្លះមិនគោរពភ្លើងសញ្ញាចរាចរណ៍ជាដើម។ ការបើកបរដោយមិនមានទំនួលខុសត្រូវ មិនចេះអធ្យាស្រ័យ និងមិនបានសិក្សាស្វែងយល់ពីផលប៉ះពាល់ ដែលខ្លួនយើងម្នាក់ៗអាចនឹងបង្កឲ្យមានការខូចខាត ឬគ្រោះថ្នាក់ដល់អ្នកដទៃ បង្កើតឲ្យមានបរិយាកាសអាប់អួរជាទីបំផុតដែលទង្វើនោះមិនគួរឲ្យកើតមានឡើយនៅក្នុងសង្គម។

**១.២.៣.១. ការមិនគោរពភ្លើងសញ្ញាចរាចរណ៍**

ភ្លើងសញ្ញាចរាចរណ៍ត្រូវបានគេបង្កើតឡើង ដើម្បីសម្រួលដល់ការធ្វើដំណើររបស់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ដោយធ្វើការបែកចែងនូវពេលវេលាត្រឹមត្រូវច្បាស់លាស់ សិទ្ធិអាទិភាពក្នុងការបើកបរ ធ្វើយ៉ាងណាឲ្យសមស្របសម្រាប់ទិសដៅ និងស្ថានភាពទំហំផ្លូវនីមួយៗ។ ភ្លើងសញ្ញាចរាចរណ៍មានបីពណ៌ គឺភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺពណ៌លឿង ជាសញ្ញាឲ្យប្រុងប្រយ័ត្ន ត្រៀមឈប់ ពន្លឺពណ៌បៃតង ជាសញ្ញាអនុញ្ញាតឲ្យយានជំនិះចេញដំណើរ ពន្លឺពណ៌ក្រហមជាសញ្ញាឃាត់ឲ្យឈប់ ។[7] ការបើកបរដោយមិនបានគោរពទៅតាមភ្លើងសញ្ញាចរាចរណ៍ឲ្យបានត្រឹមត្រូវ បណ្តាលឲ្យស្ថានភាពដងផ្លូវមានសភាពញ៉េរញ៉ៃ និងគ្មានសណ្តាប់ធ្នាប់បង្កជាការកកស្ទះចរាចរណ៍ដ៏គួរឲ្យធុញទ្រាន់។ តាមការសង្កេតមើលជាក់ស្តែង អ្នកបើកបរភាគច្រើនមិនបានប្រុងប្រយ័ត្នមើលភ្លើងសញ្ញា ឬមិនយល់ដឹងអំពីភ្លើងសញ្ញាចរាចរណ៍ ឬបានដឹងហើយ ប៉ុន្តែតែងតែលើកយកមូលហេតុផ្សេងៗជាច្រើនឥតគណនាមកបំពានលើភ្លើងសញ្ញាទាំងអស់នោះ បើទោះបីជាទង្វើនោះបណ្តាលឲ្យខ្លួនក្លាយជាមនុស្សអាត្មានិយមក៏ដោយ។

**១.២.៣.២. ការមិនគោរពផ្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍**

ប្រការមួយផ្នែកទៀតដែលធ្វើឱ្យមានការកកស្ទះជារៀងរាល់ថ្ងៃនោះ គឺដោយសារការមិនគោរពផ្លាកសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍របស់អ្នកបើកបរ។ ការបើកបរបែបនេះ គឺធ្វើឱ្យស្ទះផ្លូវទៅណាមិនរួចនោះទេ

[7] មាត្រា១១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

ដោយសារតែអ្នកគោរពនៅតែគោរព រីឯអ្នកមិនគោរពនៅតែមិនគោរព ចំណុចនេះហើយទើបធ្វើឱ្យវាទៅមុខមិនកើត បកក្រោយក៏មិនបានចុងក្រោយស្ទះទាំងអស់គ្នា។ ផ្លាកសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ ត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារៈប្រយោជន៍ ដែលធ្វើឲ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ។ បើទោះបីជាការបំពាក់នូវសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញពុំទាន់ត្រឹមត្រូវបានគ្រប់ជ្រុងជ្រោយក៏ដោយ ប៉ុន្តែសញ្ញាចរាចរណ៍ទាំងអស់នោះបានផ្តល់នូវភាពសមល្មមសម្រាប់អ្នកបើកបរ ដើម្បីនឹងអនុវត្តហើយក៏ជាការរួមចំណែកដ៏សំខាន់ក្នុងការកាត់បន្ថយការកកស្ទះចរាចណ៍ផងដែរ។ ប៉ុន្តែផ្ទុយមកវិញ អ្នកបើកបរនៅរាជធានីភ្នំពេញបច្ចុប្បន្ននេះ មិនបានគោរពទៅតាមគំនូសសញ្ញា ឬផ្លាកសញ្ញាចរាចរណ៍នោះទេ សូម្បីតែគំនូសសញ្ញាចរាចរណ៍សម្រាប់អ្នកថ្មើរជើងនៅពេលបច្ចុប្បន្ននេះ ក៏ត្រូវបានប្រែក្លាយទៅជាចំណតសម្រាប់យានយន្តឈប់រង់ចាំភ្លើងសញ្ញាចរាចរណ៍របស់អ្នកបើកបរនៅតាមដងផ្លូវបាត់ទៅហើយ។ យើងឃើញថា វាហាប់បីដូចជាគ្មានសណ្តាប់ធ្នាប់ គ្មានភាពជាជួរ រំលោភលើគន្លងផ្លូវ និងស្នាមគំនូសកាត់ទទឹងទ្រូងផ្លូវ[8] គំនូសអ្នកថ្មើរជើង ដែលបង្កបានជាការកកស្ទះ និងការរិះគន់ច្រើនពីសំណាក់ប្រជាពលរដ្ឋដែលបានគោរពច្បាប់ចរាចរណ៍។ លើសពីនេះទៅទៀតនោះ នៅតាមបណ្តាដងវិថីមួយចំនួនមានការចតយានជំនិះជាច្រើនហូរហែ ទាំងដែលនៅតាមដងវិថីទាំងអស់នោះមានផ្លាកសញ្ញាហាមចត ហាមឈប់ ដែលកត្តាទាំងអស់នេះធ្វើឲ្យទំហំផ្លូវកាន់តែរួមតូចបង្កជាបញ្ហាកកស្ទះចរាចរណ៍ស្ទើរតែរាល់ថ្ងៃ។ នៅពេលខ្លះ ស្លាកសញ្ញាចរាចរណ៍ស្ទើរតែគ្មានអត្ថន័យសម្រាប់អ្នកបើកបរមួយចំនួននៅក្នុងរាជធានីភ្នំពេញសព្វថ្ងៃនេះ។

### **១.២.៣.៣. ការជិះបញ្ច្រាសផ្លូវរបស់អ្នកបើកបរ**

នៅលើដង់ផ្លូវនៅក្នុងប្រទេសកម្ពុជា គឺមានការបែងចែកគន្លងផ្លូវសម្រាប់ធ្វើចរាចរណ៍ជាពីហើយអ្នកបើកបរត្រូវប្រកាន់យកចំណែកផ្លូវខាងស្តាំក្នុងការធ្វើចរាចរណ៍[9]។ ប៉ុន្តែប្រជាជនមួយចំនួនបានបើកបររំលោភបំពានទៅលើចំណែកផ្លូវរបស់ខ្លួន ដោយការជិះបញ្ច្រាសផ្លូវ ជាពិសេសនៅពេលដែលស្ថានភាពផ្លូវកំពុងតែមានការកកស្ទះនៅតាមដងវិថីនានានោះ ពួកគាត់បែរជាធ្វើការសម្រេចចិត្តជិះបញ្ច្រាសផ្លូវ ជិះចូលគន្លងផ្លូវរបស់អ្នកដទៃ ធ្វើយ៉ាងណាឲ្យតែយានជំនិះរបស់ពួកគាត់បានរុលទៅមុខ និងដល់ទិសដៅដោយមិនខ្វល់ពីស្ថានភាពចរាចរណ៍នឹងទៅជាយ៉ាងណានោះទេ។ កត្តានេះ មិនត្រឹមតែធ្វើឲ្យពួកគាត់កាន់តែខាតពេលវេលានោះទេ ថែមទាំងបានបង្កឲ្យស្ថានភាពផ្លូវម្ខាងទៀតនោះមានការកកស្ទះលើសដើម ហើយជួនកាលអាចនឹងបង្កឲ្យគ្រោះថ្នាក់ចរាចរណ៍ប៉ះពាល់ដល់អាយុជីវិតអ្នកដទៃថែមទៀតផង។ ករណីពាក់ព័ន្ធនឹងករណីជិះបញ្ច្រាសនេះ យោងតាមរបាយការណ៍របស់នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈបានឱ្យដឹងថាក្នុងរយៈពេល ១០ថ្ងៃ នៃការរឹត

[8] កថាខណ្ឌទី២ នៃមាត្រា១១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

[9] កថាខណ្ឌទី២ នៃមាត្រា១០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

បន្តឹងស្តីពីចរាចរណ៍ផ្លូវគោក មានយានយន្តចំនួន ១៨៤៥០ គ្រឿង ល្មើសច្បាប់ស្មើនឹង១៩១៦០ ករណីត្រូវបានផាកពិន័យតាមអនុក្រឹត្យលេខ៣៩ របាយការណ៍ដដែលបានបង្ហាញថាក្នុងចំណោមយានយន្តទាំង១៨៤ ៤៥០ គ្រឿងនេះមានម៉ូតូចំនួន ១៤៦០៣គ្រឿងល្មើសច្បាប់ស្មើនឹង ១៤៣៤០ករណី និងរថយន្តចំនួន៤៨៤៧ គ្រឿង ល្មើសច្បាប់ស្មើនឹង៤៨២០ ករណីក្នុងនោះ អំពើល្មើសភាគច្រើន អត់មួកសុវត្ថិភាព អត់កញ្ចក់ និងជិះបញ្រ្ចាស់ផ្លូវ។

**១.២.៣.៤. ការប្រើប្រាស់ទូរស័ព្ទក្នុងពេលបើកបរ**

ប្រជាពលរដ្ឋកម្ពុជាចូលចិត្តណាស់ចំពោះការប្រើប្រាស់ទូរសព្ទដៃទំនើបៗ ថែមទាំងពេលខ្លះពួកគេចាត់ទុកថា វាជារឿងដ៏លំបាកប្រសិនបើធ្វើដំណើរទៅណាមកណាដោយគ្មានទូរស័ព្ទជាប់ជាមួយខ្លួនទេនោះ។ ប៉ុន្តែការប្រើប្រាស់ទូរស័ព្ទក្នុងខណៈពេលបើកបរត្រូវបានច្បាប់កំណត់មិនឲ្យប្រើប្រាស់នោះទេ ករណីគ្មានឧបករណ៍ភ្ជាប់សំឡេង[10]។ អំឡុងមួយរយៈពេលក្រោយនេះ គេសង្កេតឃើញថា អ្នកបើកបរនៅរាជធានីភ្នំពេញមួយចំនួនតែងតែងប្រើប្រាស់ទូរស័ព្ទចូលទៅកាន់ហ្វេកបុក ហ្គេម ឬនិយាយទូរស័ព្ទគ្រប់ពេលវេលា ដែលទង្វើទាំងអស់នេះធ្វើឲ្យអ្នកបើកបរបាត់ការផ្តោតអារម្មណ៍លើដងវិថី ដែលបណ្តាលឲ្យយានយន្តមានលក្ខណៈវេចង្កូត ឆ្វេង ស្តាំជារឿយៗដែលអាចនឹងបង្កជាបញ្ហាដល់អ្នកដទៃហើយនាំឲ្យមានការកកស្ទះចរាចរណ៍ផងដែរ។

**១.២.៣.៥. ការមិនគោរពសិទ្ធិអាទិភាព**

ការបើកបរបំពានលើផ្លូវអាទិភាពនេះក៏ជាចំណែកមួយក្នុងការបង្កើនឱ្យមានការកកស្ទះកាន់តែខ្លាំងមានន័យថា អ្នកបើកបរមិនបានដឹងពីច្បាប់ ផ្លូវណាសម្រាប់រថយន្ត ផ្លូវណាសម្រាប់ម៉ូតូនោះទេ គឺរំលោភបំពានលើផ្លូវអាទិភាពរបស់គេ។ មូលហេតុចម្បង ដែលនាំឱ្យមានរូបភាពបែបនេះ គឺមកពីអ្នកបើកបរទាំងឡាយចង់ប្រជែងទៅមុខរៀងខ្លួន។ នៅពេលដែលយើងនិយាយអំពីពាក្យថា អាទិភាព យើងសំដៅទៅលើសិទ្ធិដែលអ្នកបើកបរអាចនឹងទទួលបានមុនគេនៅក្នុងស្ថានភាពផ្លូវធ្វើដំណើរពេលកំពុងបើកបរ។ សិទ្ធិអាទិភាព ជាកត្តាសំខាន់ដែលអ្នកបើកបរចាំបាច់ត្រូវតែទទួលការយល់ដឹងអំពីការប្រើប្រាស់ផ្លូវរបស់ខ្លួន ថាតើការប្រើប្រាស់មធ្យោបាយធ្វើដំណើររបស់ខ្លួនតាមដងផ្លូវនោះ វាប៉ះពាល់ ឬបំពានសិទ្ធិអ្នកដទៃដែលឬទេ ? ករណីនៅពេលដែលអ្នកកំពុងបើកបរនៅក្នុងផ្លូវលំក្នុងទិសដៅកែងគ្នានឹងមហាវិថីធំៗនោះ នៅពេលដែលដល់ចំណុចប្រសព្វគ្នា អ្នកចាំបាច់ត្រូវធ្វើការបន្ថយល្បឿន និងទុកសិទ្ធិអាទិភាពឲ្យយានយន្តដែលកំពុងតែចរាចរនៅលើផ្លូវធំនោះ ចេញដំណើរទៅមុន រួចទើបអ្នកមានសិទ្ធិបើកចេញទៅតាមក្រោយ។[11] នេះជាការអនុវត្តទៅតាមផ្លូវច្បាប់ ហើយអ្វីដែលបានលើកឡើងខាងលើនេះ សុទ្ធតែជាចំណុចតូចៗ ដែលបច្ចុប្បនេះអ្នកបើកបរកំពុងតែប្រើប្រាស់មធ្យោបាយធ្វើដំណើរទាំង

[10] ចំណុចទី៦ នៃមាត្រា៨ ថ្មីនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

[11] ចំណុច១០ នៃមាត្រា២១ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

បំពានលើសិទ្ធិអាទិភាពរបស់អ្នកដទៃ មិនចេះយោគយល់ មិនចេះបន្ថយល្បឿនឲ្យយានជំនិះផ្សេងគេទៅមុននោះទេ គិតតែពីភាពប្រញាប់ប្រញាល់របស់ខ្លួនឯងបង្កបានជាកត្តានាំឲ្យបញ្ហាកកស្ទះចរាចរណ៍ចោទឡើង រហូតពេលខ្លះធ្វើឲ្យអ្នកបើកបរដែលជាមនុស្សថ្លៃថ្នូរ មានមុខមាត់នៅក្នុងសង្គមក្លាយទៅជាមនុស្សអាត្មានិយមមួយរំពេចដោយសារការបើកបររបស់ខ្លួន។

**១.២.៣.៦. ការមិនចេះអធ្យាស្រ័យឱ្យគ្នា**

នៅក្នុងការធ្វើដំណើរនៅលើដងផ្លូវអ្នកបើកបរក៏ដូចជាអ្នកប្រើប្រាស់ផ្លូវមួយចំនួននៅខ្វះការអធ្យាស្រ័យឲ្យគ្នាដែលកត្តានេះបានចោទជាបញ្ហាចម្បងនៅក្នុងការចូលរួមចំណែកនាំឲ្យមាននូវក៏ការកកស្ទះចរាចរណ៍ដែលតែងតែកើតមានជារឿយៗ។ បើកបរឬអ្នកប្រើប្រាស់ផ្លូវមួយចំនួនមិនសូវមាននូវការយោគយល់ អធ្យាស្រ័យរវាងគ្នានឹងគ្នាដោយយកឈ្នះយកចាញ់រៀងៗ ខ្លួនដែលនាំឲ្យប៉ះពាល់ទៅដល់ប្រយោជន៍សាធារណៈក៏ដូចជាប៉ះពាល់ដល់អ្នកដទៃ។

**១.២.៣.៧. ការបិទផ្លូវ**

ការបិទផ្លូវនៅក្នុងស្ថានភាពមួយចំនួនក៏បានបណ្តាលឲ្យអ្នកបើកបរប្រឈមនឹងបញ្ហាកកស្ទះចរាចរណ៍ផងដែរ ហើយជាទូទៅការបិទផ្លូវនោះអាចបណ្តាលមកពីការហែក្បួនអមគណៈប្រតិភូ ពិធីបុណ្យសាសនាប្រពៃណីជាតិផ្សេងៗ ការធ្វើបាតុកម្ម ឬការតវ៉ានានា ការរៀបចំពិធីបុណ្យ ឬមង្គលការរបស់ប្រជាពលរដ្ឋជាដើម។ តាមបទពិសោធន៍នៃការមើលឃើញកន្លងមក គ្មាននរណាម្នាក់ហ៊ានមកអះអាងទេថា នៅក្នុងសង្គមនៃការរស់នៅរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ប្រជាពលរដ្ឋនិងថ្នាក់ដឹកនាំបច្ចុប្បន្ននេះ មានលក្ខណៈស្មើគ្នា តម្លាភាពមិនលំអៀងនោះ។ អ្វីទាំងអស់នេះ វាស្តែងចេញពីទង្វើដែលប្រជាពលរដ្ឋមើលឃើញនឹងភ្នែករបស់ពួកគេ ជាក់ស្តែងករណីនៅពេលដែលមានក្បួនហែរគណៈប្រតិភូ ឬអ្នកមានអំណាចធ្វើដំណើរតាមដងវិថីណាមួយ វិថីផ្សេងៗទៀតដែលនៅក្បែរនោះត្រូវបានគេបិទ ដើម្បីទុកផ្លូវឲ្យទូលាយឲ្យក្បួនហែធ្វើចរាចរ ដែលការដែលបិទផ្លូវទាំងនោះនាំឲ្យប្រជាពលរដ្ឋមានការមិនសប្បាយចិត្តដោយសារបង្កឲ្យមានការយឺតយ៉ាវដល់ពួកគេ។

**១.២.៣.៨. ការរំលោភលើចិញ្ចើមផ្លូវ**

យោងតាមឯកសាររបស់រដ្ឋបាលរាជធានីភ្នំពេញបានឲ្យដឹងថា ក្នុងរយៈពេលកន្លងមក បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់លំនៅស្ថាន ម្ចាស់សហគ្រាស ម្ចាស់អាជីវកម្ម មន្ទីរពេទ្យ សាលារៀន ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនផ្សេងទៀត បាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវមិនទាន់បានសមស្របទាំងស្រុង ឬបំពានលើបទប្បញ្ញត្តិច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ជាពិសេសបំពានលើបទប្បញ្ញាត្តិមួយចំនួននៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយដ្ឋាន និងសំណង់។ អំពើរំលោភបំពាននោះស្តែងចេញតាមរូបភាពដូចជា ការយកទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងជាយផ្លូវ

ធ្វើជាចំណតយានជំនិះ ការតស៊ំយ៉ាប ការហ៊ុមព័ទ្ធយកចិញ្ចើមផ្លូវ ការយកផ្លូវថ្មើរជើង ឬចិញ្ចើមផ្លូវធ្វើជាទីតាំងការដ្ឋានទុកដាក់សម្ភារ ឬដាក់តាំងបង្ហាញទំនិញ ឬប្រកបអាជីវកម្មផ្សេងៗជាលក្ខណៈឯកជន ដែលបង្កឲ្យមានការកកស្ទះចរាចរណ៍ និងជះឥទ្ធិពលអវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពរាជធានីភ្នំពេញ[12]។ គួរបញ្ជាក់ផងដែរថាការលក់ដូរនៅលើចិញ្ចើមផ្លូវ គឺជាបញ្ហាចោទដ៏ចម្បងដែលបង្កទៅជាភាពអនាធិបតេយ្យនៅលើដងផ្លូវរួមទាំងបង្កឲ្យមានការកកស្ទះចរាចរណ៍ផងដែរ។

**១.២.៣.៩. កំណើននៃតម្រូវការយានយន្តរបស់ប្រជាពលរដ្ឋ**

គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ ស្ថិតិយានយន្តក្នុងរាជធានីភ្នំពេញមានចំនួនប្រមាណ ៥០ម៉ឺន គ្រឿង និងទោចក្រយានយន្តចំនួនប្រមាណ ២លាន គ្រឿង។ ចំនួនយានយន្តទាំងនេះបានបណ្តាលអោយមានការកកស្ទះចរាចរណ៍ នេះបើតាមមន្ទីរសាធារណការរាជធានីភ្នំពេញ។ កំណើនយានយន្ត កាន់តែកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃដោយសារកត្តាសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ។ ដូចនេះប្រជាពលរដ្ឋអាចនឹងមានលទ្ធភាពទិញរថយន្ត ម៉ូតូ ពោល គឺមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនកាន់តែច្រើនឡើង ចំណែកឯផ្លូវនៅក្នុងទីក្រុងភ្នំពេញមួយចំនួនហាក់មានសភាពតូចចង្អៀតនៅឡើយ ដូច្នេះកំណើននៃយានយន្តកាន់តែច្រើនបានបង្កឲ្យមាននូវការកកស្ទះចរាចរណ៍កាន់ខ្លាំង ។

**១.២.៣.១០. ការមិនចូលរួមក្នុងការប្រើប្រាស់សេវាសាធារណៈ**

សេវាសាធារណៈត្រង់ចំណុចនេះ គឺសំដៅទៅលើរថយន្តក្រុងសាធារណៈដែលកំពុងដឹកជញ្ជូនអ្នកធ្វើដំណើរជារៀងរាល់ថ្ងៃ។ ប៉ុន្តែចំនួនអ្នកប្រើសេវានេះ នៅមានកម្រិតនៅឡើយជាពិសេសសេវារថយន្តក្រុងសាធារណៈនេះនៅមិនទាន់ធំទូលាយនោះទេ មានន័យថារថយន្តដឹកអ្នកដំណើរមានចំនួនតិច ហើយដឹកតែផ្លូវធំៗប៉ុណ្ណោះ។ ដូចនេះ ប្រសិនបើប្រជាពលរដ្ឋមានការយល់ដឹងច្រើនទៅលើសេវាសាធារណៈ នោះរដ្ឋនឹងបង្កើតឱ្យមានសេវារថយន្តក្រុងនេះកាន់តែច្រើន គឺអាចជួយកាត់បន្ថយការកកស្ទះក្នុងទីក្រុងផងដែរ។

## ១.៣. គុណវិបត្តិនៃការកកស្ទះចរាចរណ៍

ជាការពិតណាស់ ករណីដែលយើងមើលទៅតាមស្ថានភាពកកស្ទះម្តងៗ អ្នកបើកបរត្រូវខាតពេលវេលាក្នុងការប្រកបរបររកស៊ី ជំនួញជួញដូរអាចនឹងត្រូវទទួលរងនូវការស្តីបន្ទោសពីកន្លែងធ្វើការងារ ខកខានការប្រជុំជាមួយថ្នាក់ដឹកនាំរបស់ខ្លួនជាដើម។ តាមរយៈការអង្កេតពីទិដ្ឋភាពជាក់ស្តែង យើងអាចធ្វើការបកស្រាយទៅលើចំណុចអវិជ្ជមានចំនួន៣ ដែលបង្កឡើងដោយបញ្ហាកកស្ទះចរាចរណ៍។

[12] សេចក្តីណែនាំលេខ០០៧/១៧ សណន.ច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំ សណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

### ១.៣.១. ខាតពេលវេលា

គ្មាននរណាម្នាក់ដែលចង់ធ្វើដំណើរទៅធ្វើការយឺតនោះទេ ហើយត្រូវឱ្យចៅហ្វាយស្ដីបន្ទោសនៅកន្លែងបំពេញការងារនោះទេ ប៉ុន្តែនៅពេលខ្លះយើងពិតជាមិនអាចប៉ាន់ស្មានពីការកកស្ទះចរាចរណ៍បាននោះទេ។ រឿងជាច្រើនបានកើតឡើងបែបនេះ ផ្លូវធ្វើដំណើរទៅបំពេញការងារ បើធ្វើដំណើរទៅនៅពេលយប់ស្ងាត់ ឬពេលព្រលឹមស្រាងៗនោះ គេអាចនឹងចំណាយពេលវេលាត្រឹមតែ១៥ ទៅ២០នាទីប៉ុណ្ណោះ ប៉ុន្តែប្រសិនបើធ្វើដំណើរក្នុងចន្លោះម៉ោង៧ព្រឹក ឬក៏៥ល្ងាចវិញនោះ គេត្រូវចំណាយពេលវេលាជិត១ម៉ោងទើបទៅដល់កន្លែងបំពេញការងារ។ បច្ចុប្បន្ននេះ ការកកស្ទះចរាចរណ៍ត្រូវបានគេចាត់ទុកថាជាចោរលួចពេលវេលាដ៏សកម្មដែលបញ្ហានេះពិតជាផ្តល់ផលវិបាកជាពន់ពេកសម្រាប់ប្រជាពលរដ្ឋទូទៅ មន្ត្រីរាជការ និងភ្ញៀវបរទេសដែលចូលមកទស្សនានៅក្នុងរាជធានីភ្នំពេញ។

### ១.៣.២. បញ្ហាសតិអារម្មណ៍

អ្វីដែលគួរឲ្យបារម្ភជាងនេះទៅទៀតនោះ ស្ថានភាពកកស្ទះចរាចរណ៍បណ្ដាលឲ្យអ្នកបើកបរមានអារម្មណ៍តានតឹង មួម៉ៅក្នុងចិត្ត ហើយបើបញ្ហានេះបន្តកើតឡើងយូរៗទៅ អាចនឹងបណ្ដាលឲ្យប្រជាពលរដ្ឋប្រឈមមុខនឹងបញ្ហាផ្នែកអារម្មណ៍ ដែលបង្កឡើងឲ្យពួកគេក្លាយជាមនុស្សឆេវឆាវ និងគ្មានភាពអធ្យាស្រ័យ។ អ្នកទាំងអស់គ្នាអាចប្រហែលជាយល់ថា អ្វីដែលបានលើកឡើងខាងលើនេះជាការលេងសើច ប៉ុន្តែផ្អែកតាមវេជ្ជបណ្ឌិតផ្នែកចិត្តសាស្រ្តបានលើកឡើងថា ជំងឺផ្លូវចិត្តភាគច្រើនបណ្ដាលមកពីអាការៈធុញថប់នឹងអ្វីដែលបានកើតឡើងនៅជុំវិញខ្លួន បញ្ហាខឹងច្រើនបង្កជាក្ដៅក្រហាយនៅក្នុងខ្លួន ភាពតានតឹងជាច្រើនដែលបានកើតឡើងជារឿយៗ។ ផ្សាភ្ជាប់នឹងចំណុចនេះ ចុះប្រសិនបើអ្នកបើកបរដែលតែងតែប្រឈមនឹងបញ្ហានេះជារៀងរាល់ថ្ងៃ តើអាចទេថាពួកគេនឹងមានអារម្មណ៍តានតឹង?

### ១.៣.៣. ខាតសេដ្ឋកិច្ចជាតិ

នៅពេលដែលមានបញ្ហាកកស្ទះចរាចរណ៍ តើបុគ្គលិកស្ថាប័នរដ្ឋ និងឯកជនប៉ុន្មានរូបដែលខកខានមិនបានទៅបំពេញការងារ តើអ្នកលក់ដូរប៉ុន្មានរូបដែលបាត់បង់ចំណូលប្រចាំថ្ងៃរបស់ពួកគេ? គេត្រូវមើលទៅលើបញ្ហាទាំងអស់នេះ ពីព្រោះថាចំណូលប្រជាពលរដ្ឋក៏បានដើរតួនាទីដ៏សំខាន់ក្នុងការទ្រទ្រង់នូវសេដ្ឋកិច្ចប្រទេសជាតិ ដូច្នេះប្រជាពលរដ្ឋបាត់បង់ប្រាក់ចំណូល មានន័យថាសេដ្ឋកិច្ចជាតិក៏ត្រូវបានខាតបង់ដែរ។ កាលពីឆ្នាំ២០១៧កន្លងទៅនេះ ផ្អែកតាមប្រសាសន៍អភិបាលរងរាជធានីភ្នំពេញ លោក អៀង អូននី បានលើក

ឡើងថា គ្រាន់តែបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញរាល់ថ្ងៃនេះ បានធ្វើឱ្យប្រទេសកម្ពុជាខាតបង់ប្រាក់ដល់ទៅជាងប្រមាណ៦លានដុល្លារក្នុងមួយឆ្នាំ។

# ជំពូកទី ២

# ដំណោះស្រាយ និងវិធានការនៃការកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញ

# ជំពូកទី២

# ដំណោះស្រាយនិងវិធានការនៃការកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញ

ជាការពិតណាស់ គ្រប់បញ្ហាដែលបានកើតមានឡើងសុទ្ធតែមានដំណោះស្រាយ ប៉ុន្តែថាតើយើងអាចស្វែងរកដំណោះស្រាយក្នុងការដោះស្រាយបញ្ហាទាំងនោះដោយវិធីណា? ក្នុងករណីស្វែងរកឃើញហើយ តើមានអ្នកណាខ្លះដែលត្រូវចូលរួម ដើម្បីដោះស្រាយបញ្ហានោះ? គ្រប់សំណួរសុទ្ធតែបានបង្កប់អត្ថន័យនៃការស្វែងយល់ឱ្យបានស៊ីជម្រៅអំពីទម្រង់បញ្ហាដែលបានកើតឡើង ដូចជាករណីបញ្ហាកកស្ទះចរាចរណ៍នេះជាដើម យើងទាំងអស់គ្នាចាំបាច់ត្រូវតែស្វែងរកមូលហេតុពិតប្រាកដរបស់វា និងហ៊ានលាតត្រដាងអំពីអ្វីដែលអាជ្ញាធរមានសមត្ថកិច្ចបានអនុវត្តកន្លងមក ហើយឆ្លុះបញ្ចាំងមើលថា តើវាឆ្លើយតបទៅនឹងដំណោះស្រាយហើយ ឬយ៉ាងណា?

នៅក្នុងជំពូកនេះ ខ្ញុំបាទទាំងពីនាក់នឹងលើកអំពីដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ទូទៅមួយដែលថ្នាក់ដឹកនាំបាននឹងកំពុងតែព្យាយាមអនុវត្តយ៉ាងយកចិត្តទុកដាក់ ហើយចាំបាច់ទាមទារឱ្យមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសំណាក់ប្រជាពលរដ្ឋ អ្នកបើកបរដែលកំពុងតែធ្វើចរាចរណ៍ក្នុងរាជធានីភ្នំពេញ រួមជាមួយនឹងផែនការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញដែលបានអនុវត្តកន្លងមក។

## ២.១. ទីតាំង និងពេលវេលាកកស្ទះចរាចរណ៍

ដើម្បីស្វែងរកដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ឲ្យបានត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយនោះ សមត្ថកិច្ចនិងមន្ត្រីរាជការគ្រប់ស្ថាប័នពាក់ព័ន្ធចាំបាច់ត្រូវតែធ្វើការតាមដានត្រួតពិនិត្យឱ្យបានម៉ត់ចត់ ព្រមទាំងក្តោបព័ត៌មានឲ្យបានទាំងអស់អំពីគោលដៅ ទីកន្លែង និងពេលវេលាជាអចិន្ត្រៃយ៍ដែលរមែងតែងតែជួបប្រទះនឹងបញ្ហាកកស្ទះចរាចរណ៍។ យោងតាមការពិនិត្យជាក់ស្តែងនៅក្នុងរបាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ទីតាំងកកស្ទះចរាចរណ៍នៅរាជធានីភ្នំពេញបច្ចុប្បន្ននេះត្រូវបានគេអង្កេតទៅលើផ្នែកចំនួនពីរ ពោលគឺចំណុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវ និងចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារ[13]។

### ២.១.១. ចំណុចកកស្ទះចរាចរណ៍នៅតាមដងផ្លូវ

មានចំណុចកករស្ទះចរាចរណ៍ជាច្រើននៅតាមដងផ្លូវនៅក្នុងរាជធានីភ្នំពេញ ចំណុចកករស្ទះទាំងនោះមានដូចខាងក្រោម ៖[14]

---

[13] ផែនការសកម្មភាពលេខ១១៤ ផ.ក ,ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ

[14] របាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញឆ្នាំ២០១៦

- ខណ្ឌដូនពេញ ចំនួន ២៧ គោលដៅ
- ខណ្ឌ៧មករា ចំនួន ៣៣ គោលដៅ
- ខណ្ឌចំការមន ចំនួន ១៦ គោលដៅ
- ខណ្ឌទួលគោក ចំនួន ៣២ គោលដៅ
- ខណ្ឌឫស្សីកែវ ចំនួន ០៨ គោលដៅ
- ខណ្ឌជ្រោយចង្វា ចំនួន ០៣ គោលដៅ
- ខណ្ឌព្រែកព្នៅ ចំនួន ០២ គោលដៅ
- ខណ្ឌសែនសុខ ចំនួន ១២ គោលដៅ
- ខណ្ឌពោធិ៍សែនជ័យ ចំនួន ០៥ គោលដៅ
- ខណ្ឌដង្កោ ចំនួន ០៦ គោលដៅ
- ខណ្ឌមានជ័យ ចំនួន ០៦ គោលដៅ
- ខណ្ឌច្បារអំពៅ ចំនួន ០៥ គោលដៅ
- ខណ្ឌបឹងកេងកង ចំនួន ១៥ គោលដៅ
- ខណ្ឌកំបូល ចំនួន ០២ គោលដៅ។

### ២.១.២. ចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារ

យោងតាមការអង្កេតជាក់ស្តែង ចំណុចកកស្ទះចរាចរណ៍នៅតាមទីផ្សារក្នុងរាជធានីភ្នំពេញនាពេលបច្ចុប្បន្ននេះ មានដូចខាងក្រោម៖

- ខណ្ឌដូនពេញ ៖ ផ្សារធំថ្មី ផ្សារចាស់ ផ្សារកណ្តាល ផ្សារសុរិយា ផ្សាររាត្រី
- ខណ្ឌ៧មករា ៖ ផ្សារអូរឫស្សី
- ខណ្ឌចំការមន ៖ ផ្សារAEON1
- ខណ្ឌទួលគោក ៖ ផ្សារដើមគរ ផ្សារសាមគ្គី ផ្សារហេងលី ផ្សារដេប៉ូ
- ខណ្ឌឫស្សីកែវ ៖ ផ្សារទួលសង្កែ ផ្សារខាំកូ
- ខណ្ឌពោធិ៍សែនជ័យ ៖ ផ្សារពោធិ៍ចិនតុង ផ្សារស៊ិនជូវីផ្លាហ្សា ផ្សារជម្ពូវ័ន្ត
- ខណ្ឌច្បារអំពៅ ៖ ផ្សារច្បារអំពៅ ផ្សារព្រែកឯង
- ខណ្ឌសែនសុខ ៖ ផ្សារAEON2 ផ្សារឈូកមាស
- ខណ្ឌបឹងកេងកង ៖ ផ្សារអូឡាំពិក ផ្សារទួលទំពូង...។

### ២.១.៣. ពេលវេលានៃការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ

ដូចដែលយើងបានដឹងស្រាប់ហើយថា ទីក្រុងជាមជ្ឈមណ្ឌលផ្តល់សេវាកម្មជូនប្រជាជនដ៏សម្បូរបែបមាន ដូចជា សេវាកម្សាន្ត សេវាកម្មអប់រំ សេវាបណ្តុះបណ្តាលធនធានមនុស្ស សេវាផ្តល់ការងារជូនប្រជាជន និងផ្តល់សេវាសាធារណៈជូនប្រជាជន។[15] រាជធានីភ្នំពេញជាទីក្រុងមួយដែលធំជាងគេនៅក្នុងប្រទេសកម្ពុជា សម្បូរទៅដោយមនុស្សរស់នៅច្រើនកុះករ ដោយសារទីក្រុងភ្នំពេញជាមជ្ឈមណ្ឌលដែលផ្តល់សេវាទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ ។ សភាពការណ៍ចរាចរណ៍នៅរាជធានីភ្នំពេញមានការកកស្ទះទៅតាមពេលវេលា ដែលពេលវេលាកកស្ទះគឺនៅពេលព្រឹកចាប់ពីម៉ោង៧:០០ដល់ម៉ោង៨:០០ ពេលថ្ងៃត្រង់ចាប់ពីម៉ោង១១:៣០ ដល់ម៉ោង២:៣០ និងពេលល្ងាចចាប់ពីម៉ោង៥:០០ ដល់ម៉ោង៧:០០។ មូលហេតុដោយសារ អ្នករាជការ អ្នកធ្វើការក្រុមហ៊ុន អ្នករកស៊ី និងកូនសិស្សនិស្សិត ពួកគាត់ទៅមកពីផ្ទះទៅកន្លែងដែលពួកគាត់ទទួលយកនឹងផ្តល់សេវាដែលបានរៀបរាប់ខាងលើ។ ចំណែកឯថ្ងៃសៅរ៍ និងអាទិត្យវិញពេលព្រឹក និងពេលថ្ងៃមិនសូវកកស្ទះទេ រីឯពេលល្ងាចនៅតែកកស្ទះដដែល តែចាប់ពីម៉ោង៦ល្ងាចតទៅ ពីព្រោះវាជាពេលវេលាដែលអ្នករស់នៅក្នុងក្រុងភ្នំពេញចេញពីផ្ទះដើម្បីធ្វើដំណើរទៅកម្សាន្តនៅតាមរមណីយដ្ឋាននានា។

## ២.២. ដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍

### ២.២.១. ការអប់រំ និងផ្សព្វផ្សាយ

ការអប់រំ និងផ្សព្វផ្សាយត្រូវបានចាត់ទុកថាជាកាតាលីករមួយដ៏មានប្រសិទ្ធភាពក្នុងការធានាឲ្យផែនការកាត់បន្ថយការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលតាមគោលដៅដែលបានកំណត់។ ជាការពិតណាស់ នៅក្នុងការអភិវឌ្ឍសង្គមមួយប្រកបដោយភាពរីកចម្រើនជាទូទៅ គឺគ្មានអ្វីដែលធំធេងជាងការផ្តល់ចំណេះដឹង និងព័ត៌មានដែលត្រឹមត្រូវជូនប្រជាពលរដ្ឋនោះទេ។ ចំពោះបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញអាចឲ្យយើងលើកឡើងបានថា ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការបើកបរ និងសារៈសំខាន់នៃការគោរពច្បាប់ចរាចរណ៍នៅមានកម្រិតនៅឡើយ ដូច្នេះក្នុងនាមជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការសាធារណៈចាំបាច់ត្រូវតែយកចិត្តទុកដាក់ផ្សព្វផ្សាយពីចំណេះដឹងពាក់ព័ន្ធនឹងច្បាប់ចរាចរណ៍ដូចជា ការគោរពគំនូសសញ្ញាចរាចរណ៍ ផ្លាកចរាចរណ៍ សិទ្ធិអាទិភាពចរាចរណ៍ជាដើម...។ ការអប់រំ និងផ្សព្វផ្សាយនេះ អាចធ្វើឡើងតាមរយៈការបើកយុទ្ធនាការចែកខិត្តបណ្ណផ្សព្វផ្សាយតាមទីសាធារណៈ ការរៀបចំសិក្ខាសាលាដែលមានការចូលរួមអំពីអង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាលជាដើម។ ម៉្យាងវិញទៀតនោះ ស្របតាមគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកចំពោះការអប់រំ និងផ្សព្វផ្សាយត្រូវបានកំណត់តាមយុទ្ធសាស្ត្រដូចខាងក្រោម ៖

[15]សៀវភៅ នីតិនគរូបនីយវិទ្យា របស់បណ្ឌិត អ៊ុន សកក្កដា

- ការរៀបចំបញ្ចូលក្នុងកម្មវិធីសិក្សាស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅក្នុងប្រព័ន្ធអប់រំ
- ជំរុញការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក
- ជំរុញការផ្សព្វផ្សាយ និងអប់រំសុវត្ថិភាពចរាចរណ៍នៅតាមផ្លូវថ្នល់ និងនៅតាមសហគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។[16]

### ២.២.២. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

#### ២.២.២.១. ការរៀបចំផ្លូវថ្នល់ និងស្ពានអាកាស

ស្ថិតនៅក្នុងស្ថានភាពប្រទេសកំពុងអភិវឌ្ឍន៍ ប្រទេសកម្ពុជាចាំបាច់បន្តនិរន្តរភាពក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ព្រមទាំងធានាឲ្យបាននូវគុណភាពក្នុងការរៀបចំគម្រោងផែនការនីមួយៗ។ នៅក្នុងក្របខណ្ឌនេះ រដ្ឋាភិបាលមានកាតព្វកិច្ចធានាឲ្យការរៀបចំផ្លូវថ្នល់តាមទីប្រជុំជននីមួយៗ មានលក្ខណៈត្រឹមត្រូវតាមស្ដង់ដារ លុបបំបាត់អំពើពុករលួយគ្រប់រូបភាពដែលអាចនឹងបណ្ដាលឲ្យសំណង់ផ្លូវថ្នល់មិនធានាបានគុណភាពដើម។ លើសពីនេះទៅទៀត រដ្ឋាភិបាលចាំបាច់ត្រូវតែយកចិត្តទុកដាក់បំផុតចំពោះការបំពេញហេដ្ឋារចនាសម្ព័ន្ធដែលកំពុងតែខ្វះខាត និងព្យាយាមធ្វើយ៉ាងណាកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍នៅតាមផ្លូវចំណុចប្រសព្វនានាឲ្យខានតែបាន។ ចំពោះបញ្ហាភ្លើងសញ្ញាចរាចរណ៍នៅក្នុងរាជធានីភ្នំពេញវិញនោះ លោក សំ ពិសិដ្ឋ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ទទួលបន្ទុកគម្រោងដំឡើងភ្លើងស្តុបក្នុងរាជធានីភ្នំពេញលើកឡើងថា "ការដំឡើងស្តុបថ្មីនៅរាជធានីភ្នំពេញ ដើរដោយប្រព័ន្ធ Smart Signal អាចជួយសម្រួលដល់ចរាចរណ៍នៅតំបន់កកស្ទះ ហើយអ្វីដែលសំខាន់ទៀតនោះ គេអាចបញ្ជាភ្លើងស្តុបចេញពីបន្ទប់ត្រួតពិនិត្យផ្ទាល់យ៉ាងងាយស្រួល ហើយពាក់ព័ន្ធនឹងភ្លើងស្តុបដំណើរការនៅលើមហាវិថីធំពីរ តួយ៉ាងមហាវិថីព្រះមុនីវង្ស និងមហាវិថីនរោត្តម គេឃើញមានភ្លើងស្តុបជាច្រើន ដាក់បញ្ឈរកៀកៗគ្នា ក្នុងរយៈចម្ងាយប្រហែល ១គីឡូម៉ែត្រ មានស្តុបមួយយ៉ាងហោចណាស់ "[17]។

ក្រៅពីនេះ ក្រោមជំនួយរបស់ក្រសួងសន្តិសុខសាធារណៈចិន កម្ពុជាបានបំពាក់កាមេរ៉ាត្រួតពិនិត្យចរាចរណ៍នៅតាមស្តុបមួយចំនួនដែលក្នុងនោះទីតាំងនីមួយៗ ត្រូវបានបំពាក់កាមេរ៉ាគ្រប់គ្រងចរាចរណ៍ចំនួន ០៨កាមេរ៉ា។ ខាងក្រោមនេះ ជាទីតាំងស្តុបដែលនឹងត្រូវបំពាក់កាមេរ៉ាត្រួតពិនិត្យចរាចរណ៍៖

- ស្តុបច្រមុះជ្រូកក្បាលថ្នល់ នៅតាមបណ្តោយផ្លូវព្រះមុនីវង្ស
- ស្តុបក្រសួងមហាផ្ទៃ នៅតាមបណ្តោយមហាវិថីព្រះនរោត្តម កែងផ្លូវលេខ ៤៨៤

---

[16] (ចំណុចទី៤)សៀវភៅគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

[17] https://urbanvoicecambodia.net (ថតចម្លងនាថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០)

- ស្តុបចំការមន នៅតាមបណ្តោយមហាវិថីព្រះនរោត្តម កែងមហាវិថីម៉ៅសេទុង
- ស្តុបបូកគោ នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងមហាវិថីម៉ៅសេទុង
- ស្តុបពេទ្យចិន នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងមហាវិថីព្រះសីហនុ
- ស្តុបទូតអាឡឺម៉ង់ នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងផ្លូវលេខ ២១៤
- ស្តុបអូរឫស្សី នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងផ្លូវលេខ ១៨២
- ស្តុបផ្សារធំថ្មី នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងផ្លូវ២១៧
- ស្តុបសួនកាណាឌីយ៉ា នៅតាមបណ្តោយមហាវិថីមុនីវង្ស កែងមហាវិថីសហព័ន្ធរុស្ស៊ី
- ស្តុបសណ្ឋាគារណានជីង នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម កែងផ្លូវលេខ ១៣៩
- ស្តុបដេអិន នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម កែងផ្លូវលេខ១៦៩
- ស្តុបវិទ្យាល័យសន្ធរម៉ុក នៅតាមបណ្តោយមហាវិថីកម្ពុជាក្រោម កែងមហាវិថីម៉ៅសេទុង
- ស្តុបទេពផន នៅតាមបណ្តោយមហាទេពផន កែងមហាវិថីម៉ៅសេទុង
- ស្តុបម៉ុងឌីយ៉ាល់ នៅតាមបណ្តោយមហាវិថីម៉ៅសេទុង កែងផ្លូវលេខ ២៣០
- ស្តុបអាងទឹកស្អាតអូរឡាំពិក នៅតាមបណ្តោយមហាវិថីព្រះមុន្នីវ៉េត កែងមហាវិថីព្រះសីហនុ
- ស្តុបនាងគង្ហីង រង្វង់មូលនាងគង្ហីង
- ស្តុបផ្សារដេប៉ូ នៅតាមបណ្តោយវិថី កែងផ្លូវលេខ ២១៥
- ស្តុបច្បារអំពៅ ២ នៅតាមបណ្តោយផ្លូវជាតិលេខ១
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ១ និងផ្លូវលេខ៣៦៣ផ្សារច្បារអំពៅ
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ១ និងផ្លូវលេខ ៦២៨
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ១ និងផ្លូវលេខ ៣៥១ វត្តនិរោធន៍
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ១ និងផ្លូវទូរទស្សន៍បាយ័ន
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ១ និងផ្លូវចូលបុរី ប៉េងហួតបឹងស្នោរ
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ១ និងផ្លូវចូលមន្ទីរពេទ្យចារីយ៍
- ភ្លើងស្តុបប្រសព្វរវាងមហាវិថីព្រះសីហនុ និងមហាវិថីសុធារស
- ភ្លើងស្តុបប្រសព្វរវាងផ្លូវលេខ ៣៣៧ និងផ្លូវលេខ ៥៦៦
- ភ្លើងស្តុបប្រសព្វផ្លូវលេខ ២៧១ និងផ្លូវលេខ ២០០២
- ភ្លើងស្តុបប្រសព្វរវាងផ្លូវជាតិលេខ ៤ និងផ្លូវរោងចក្រ QMI…។[18]

[18] http://phnompenh.gov.kh/(ថតចម្លង នាថ្ងៃ១០ ខែមីនា ឆ្នាំ២០២០)

បន្ថែមពីនេះទៅទៀតនោះ បន្ទាប់ពីបញ្ហាកកស្ទះចរាចរណ៍កាន់តែមានភាពធ្ងន់ធ្ងរទៅពីមួយថ្ងៃទៅមួយថ្ងៃនោះ សំណង់ស្ពានអាកាសត្រូវបានប្រតិដ្ឋឡើងនៅចំណុចផ្លូវប្រសព្វនានានៃរាជធានីភ្នំពេញ ក្នុងគោលបំណងដើម្បីរំដោះប្រជាពលរដ្ឋចេញពីការកកស្ទះដោយមានប្រសិទ្ធិភាព។ កន្លងទៅនេះ ការដ្ឋានសាងសង់ស្ពានអាកាសទី៥ នៅក្នុងរាជធានីភ្នំពេញបានបើកឲ្យប្រជាពលរដ្ឋធ្វើដំណើរក្នុងគោលបំណងបញ្ចៀសនូវបញ្ហាកកស្ទះចរាចរណ៍ ។ យោងតាមទិន្នន័យរបស់សាលារាជធានីភ្នំពេញបច្ចុប្បន្ននេះ រាជធានីភ្នំពេញបច្ចុប្បន្ននេះមានស្ពានអាកាសចំនួន៦ គឺ

- ស្ពានអាកាសក្បាលថ្នល់
- ស្ពានអាកាស ៧មករា
- ស្ពានអាកាសស្ទឹងមានជ័យ
- ស្ពានអាកាស ៥មករា
- ស្ពានអាកាសផ្សារដើមហុយ
- ស្ពានអាកាសចោមចៅ ដែលស្ពាននេះកំពុងដំណើរការសាងសង។[19]

**២.២.២.២.ការរៀបចំចំណតរថយន្តក្រោមដី**

ទីក្រុងភ្នំពេញក្នុងរយៈពេលចុងក្រោយនេះ គឺយើងសង្កេតឃើញថាមានការកើនឡើងនូវចំនួនប្រជាជនគួរអោយកត់សម្គាល់ ហើយទន្ទឹមនឹងការកើនឡើងនៃចំនួនប្រជាជននេះផងដែរ មធ្យោបាយនៃការធ្វើដំណើររបស់ប្រជាពលរដ្ឋដែលជាយានយន្តផ្សេងៗ ក៏មានការកើនឡើងទៅតាមនោះផងដែរ ចំណុចនេះហើយដែលជាហេតុធ្វើអោយមានមានការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ ដោយសារមូលហេតុខ្វះចំណតក្នុងការចតយានយន្តធ្វើដំណើររបស់ពួកគេ ដែលធ្វើអោយមានការចតយានយន្តនៅលើគែមផ្លូវសាធារណៈ។ ដោយសារមានបញ្ហាកកស្ទះដោយសារមូលហេតុនេះទើបរដ្ឋបាលរាជធានីភ្នំពេញបានសាងសង់ចំណតយានយន្តក្រោមដីសរុបចំនួន ៤ កន្លែង ដែលមានការឯកភាពពីរាជរដ្ឋាភិបាល ដែលចំណតនីមួយៗមានកំពស់ ២ជាន់ និងមានទំហំសរុបទាំងអស់ជាង ៩១០០ ម៉ែត្រការ៉េ។ គិតមកទល់ពេលនេះសម្រេចបាន២កន្លែងហើយ ដែលចំណតទី១ នៅក្រោមសួនច្បារចន្លោះវិមានកាណាឌីយ៉ា និងអាគារវឌ្ឍនៈកាពីតាល់ឆ្ពោះទៅកាន់ផ្សាររាត្រីមាត់ទន្លេ និងចំណតទី២ នៅក្រោមសួនច្បារមិត្តភាពកម្ពុជា-ថៃ ត្រង់ចំណុចខាងលិចវត្តភ្នំចន្លោះស្ថានទូតអាមេរិក និងក្រសួងសេដ្ឋកិច្ច។ ហើយចំពោះ ២កន្លែងផ្សេងទៀត ក៏គ្រោងនឹងបញ្ចប់ការសាងសងក្នុងពេលឆាប់ៗខាងមុខ។[20]

ក្រៅពីនេះរដ្ឋាភិបាលក៏បានអំពាវនាវទៅដល់ក្រុមហ៊ុនឯកជន អង្គភាពឯកជន និងស្ថាប័នឯកជននានាចូលរួមក្នុងការកាត់បន្ថយនូវការកកស្ទះចរាចរណ៍ តាមរយៈការសាងសង់ចំណតផ្ទាល់ខ្លួននៅក្រោមអគារ ឬមាន

---

[19] http://phnompenh.gov.kh/(ថតចម្លង នាថ្ងៃ១០ ខែមីនា ឆ្នាំ២០២០)

[20] http://phnompenh.gov.kh/(ថតចម្លង នាថ្ងៃ១០ ខែមីនា ឆ្នាំ២០២០)

ចំណតរបស់ខ្លួនសម្រាប់ការសំចតដោយមិនយកចំណីផ្លូវសារធារណៈមកធ្វើជាចំណតរបស់អង្គភាព ឬស្ថាប័នរបស់ខ្លួនឡើយ។

ចំពោះការសាងសង់ចំណតរថយន្តក្រោមដីនេះផងដែរ គឺធ្វើឡើងក្នុងគោលដៅសម្រួលដល់ការកកស្ទះចរាចរណ៍ និងធ្វើឲ្យសណ្តាប់ធ្នាប់តាមដងផ្លូវកាន់តែប្រសើរឡើង។

### ២.២.៣. ការរៀបចំមធ្យោបាយធ្វើដំណើរសាធារណៈ

#### ២.២.៣.១. រថយន្តក្រុង

សេវាកម្មរថយន្តក្រុងសាធារណៈ គឺជាសេវាមួយដែលបាននឹងកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងជាកតាលីករដ៏មានប្រសិទ្ធិភាពក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍។ ដោយសារតែចំណុចនេះជាដំណោះស្រាយដ៏មានប្រសិទ្ធិភាព ទើបរដ្ឋាភិបាលកម្ពុជាបានព្យាយាមធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដៃគូនានា ក្នុងគោលបំណងពង្រីកវិសាលភាពនៃការប្រើប្រាស់មធ្យោបាយសាធារណៈឲ្យកាន់តែទូលំទូលាយ ជាពិសេសនោះគឺ ការកែផ្នត់គំនិតប្រជាពលរដ្ឋឲ្យពួកគាត់ងាកមកប្រើប្រាស់មធ្យោបាយសាធារណៈជំនួសឲ្យយានជំនិះឯកជនវិញ។ ហើយជាលទ្ធផលនៃការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា សេវាសារធារណៈដែលប្រើប្រាស់រថយន្តក្រុងជាឧបករណ៍ត្រូវបានបង្កើតឡើង ដែលតម្រាយផ្លូវរត់របស់រដ្ឋាករស្វយ័តដឹកជញ្ជូនសាធារណៈរថយន្តក្រុងរាជធានីភ្នំពេញមានដូចខាងក្រោម៖[21]

- ខ្សែរត់ទី១A ពីស្ថានីយ៍រថយន្តក្រុងដល់ចំណតបឹងឈូក៖ ចេញពីស្ថានីយ៍រថយន្តក្រុងដល់ចំណតបឹងឈូកដោយឆ្លងកាត់ផ្លូវជាតិលេខ៥ គីឡូម៉ែត្រលេខ៩ រង្វង់មូលក្បួចកាណុង មហាវិថីព្រះមុនីវង្ស ផ្សារច្បារអំពៅ កំណាត់ផ្លូវជាតិលេខ១ ស្ថានីយ៍ចំណតបឹងឈូក។
- ខ្សែរត់ទី១B ពីចំណត់បឹងឈូកដល់មជ្ឈមណ្ឌលកំសាន្តព្រីនស៍ម៉ាណ័រ៖ ចេញពីចំណត់បឹងឈូកដោយឆ្លង់កាត់ផ្លូវជាតិលេខ១។
- ខ្សែរត់ទី២ ពីរង្វង់មូលក្បួចកាណុងដល់ស្ពានព្រែកសំរោង៖ ចេញពីរង្វង់មូលក្បួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ស្ពានអាកាសក្បាលថ្នល់ ផ្លូវជាតិលេខ២ ដល់ស្ពានព្រែកសំរោង។
- ខ្សែរត់ទី៣ ពីសួនច្បារឫស្សីកែវ ដល់ប៉ុរីសន្តិភាព២ ៖ ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី មហាវិថីកម្ពុជាក្រោម ស្ពានអាកាស៧មករា មហាវិធីសហព័ន្ធរុស្ស៊ី រង្វង់មូលចោមចៅផ្លូវជាតិលេខ៣ ដល់ចំណតបុរីសន្តិភាព២។
- ខ្សែរត់ទី៤A ពីចំណតសួនច្បារឫស្សីកែវ ដល់បុរីសន្តិភាព២ផ្លូវហ្សាដឹហ្គោលសម្តេចមុន្នីរ៉េត ៖ ចេញពីចំណតសួនច្បារឫស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បួចកាណុង ផ្លូវជាតិលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាលឌឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីមុន្នីរ៉េត កាត់មុខផ្សារដើមគរ

[21] http://phnompenh.gov.kh/ (ថតចម្លង នាថ្ងៃ១០ ខែមីនា ឆ្នាំ២០២០)

ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវែងស្រេង ស្តុបអាងទឹកកាណាឌីយ៉ា ផ្សារទួលពង្រ ដល់បុរីសន្តិភាព២ផ្លូវហ្សាដឺហ្គោលសម្តេចមន្នីរ៉េត។

- ខ្សែរត់ទី៤B ពីសួនច្បារឬស្សីកែវ ដល់មជ្ឈមណ្ឌលពាណិជ្ជកម្ម កម្ពុជា-ចិន (ផ្លូវវែងស្រេង)៖ ចេញពីចំណតសួនច្បារឬស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលគួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ផ្លូវលេខ១៣០ ផ្សារធំថ្មី វិថីហ្សាលដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក វិថីព្រះមុន្នីរ៉េតកាត់មុខផ្សារដើមគរ ស្ពានអាកាសស្ទឹងមានជ័យ ផ្លូវវែងស្រេង រង្វង់មូលចោមចៅ ផ្លូវជាតិលេខ៤ ដល់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។
- ខ្សែរត់ទី៤C ចំណតសួនច្បារឬស្សីកែវ ដល់សាលាសង្កាត់ព្រែកកំពឹស(ផ្លូវចំការដូង)៖ចេញពីចំណតសួនច្បារឬស្សីកែវ ផ្លូវជាតិលេខ៥ រង្វង់មូលក្បួចកាណុង ផ្លូវលេខ៤៧ វត្តភ្នំ មហាវិថីព្រះនរោត្តម ផ្លូវលេខ៣១០ ផ្សារធំថ្មី វិធីហ្សាដឺហ្គោល ស្តុបនាងគង្ហីង ស្តុបអាងទឹកអូឡាំពិក ច្រមុះជ្រូកស្ទឹងមានជ័យ ផ្លូវចំការដូង ដល់សាលាសង្កាត់ព្រែកកំពឹស។
- ខ្សែរត់ទី៥A ពីស្ថានីយ៍រថយន្តក្រុងព្រែកភ្នៅ ដល់ចំណតផ្សារអ៊ីអន២ (ផ្លូវកប់ស្រូវ)៖ ចេញពីស្ថានីយ៍រថយន្តក្រុងព្រែកភ្នៅ ដល់ផ្សារអ៊ីអន២។
- ខ្សែរត់ទី៥B ពីចំណត់ផ្សាអ៊ីអនទី២ ដល់ចំណត់ផ្សារអ៊ីអនទី១៖ ចេញពីអ៊ីអនទី២ តាមផ្លូវលេខ១០០៣ បត់ឆ្វេងតាមផ្លូវលេខ១៩៦៦ឆ្ពោះទៅផ្លូវលេខ៦៩៨ ផ្លូវលេខ៣៣៧ បត់ស្តាំតាមផ្លូវលេខ៥៦៦ សាលាបឋមសិក្សាពៅអ៊ុំ ទួលគោក វិថីគឹម អ៊ីលស៊ុង កាត់ក្រោមស្ពានអាកាសប្រាំមករា មហាវិថីម៉ៅសេទុង ស្តុបបូកគោ ស្តុបជលផល វិថីសុធារស ដល់ចំណតផ្សារអ៊ីអន១។
- ខ្សែរត់ទី៦ ពីរង្វង់មូលក្បួចកាណុង ដល់ស្ថានីយ៍រថយន្តក្រុងព្រែកភ្នៅ ៖ ចេញពីរង្វង់មូលក្បួចកាណុង ឆ្លងស្ពានជ្រោយចង្វារ ផ្លូវជាតិលេខ៦ កាត់តាមសួនសត្វសាហ្សារី ដល់ស្ថានីយ៍រថយន្តក្រុងព្រែកភ្នៅ។
- ខ្សែរត់ទី៧ ពីចំណតគីឡូម៉ែត្រលេខ៩ ដល់ចំណាត់បឹងឈូក ៖ ចេញពីចំណតគីឡូម៉ែតលេខ៩ ផ្លូវជាសុជាវ៉ា រង្វង់មូលកាំកូ ស្ពានអាកាស៧មករា រង្វង់មូលផ្សារដើមថ្កូវ ផ្សារច្បារអំពៅ ដល់ចំណាត់បឹងឈូក។
- ខ្សែរត់ទី៨ ពីរង្វង់មូលក្បួចកាណុង ដល់ចំណាត់ផ្លូវ២០០៤៖ ចេញពីរង្វង់មូលក្បួចកាណុង កាត់រង្វង់មូលកាំកូ ផ្លូវម៉ុងរឹទ្ធី ផ្សារសិនជូវីថ្លាហ្សា ដល់ផ្លូវ២០០៤។
- ខ្សែរត់ទី៩ ពីចំណតបុរីសន្តិភាព២ ដល់តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ៖ ចេញពីចំណតបុរីសន្តិភាព២ ផ្លូវជាតិលេខ៣ សួនឧស្សាហកម្មវឌ្ឍនៈ ផ្លូវប្រទះឡាយ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រលប់មកបុរីសន្តិភាព២វិញ។
- ខ្សែររត់ទី១០ ពីចំណាត់ផ្លូវ២០០៤ ដល់ផ្សារច្បារអំពៅ៖ ចេញពីចំណាត់ផ្លូវ២០០៤ កាត់តាមផ្លូវ២០០៤ ផ្លូវសូឡា ផ្លូវ៣៧១ រង្វង់មូលផ្សារដើមថ្កូវ ដល់ចំណាត់ផ្សារច្បារអំពៅ។

- ខ្សែរត់ទី១១ វត្តស្លែង ដល់ច្រមុះជ្រូកស្ទឹងមានជ័យ៖ ចេញពីចំណត់វត្តស្លែង កាត់តាមផ្លូវព្រៃសរ ផ្លូវចំការដូង ដល់ជ្រមុះជ្រូកស្ទឹងមានជ័យ។
- ខ្សែរត់ទី១២ រាជាយស្ម័យយានកម្ពុជា ខ្សែររត់ជារង្វង់ជុំ ៖ចេញពីរាជាយស្ម័នយានតាមផ្លូវនេរុ ផ្លូវ១៦៣ ផ្លូវ៣៦០ ផ្លូវប៉ាស្ទ័រ ត្រសក់ផ្អែម ហើយចូលមករាជាយស្ម័យយានកម្ពុជាវិញ។
- ខ្សែរត់ទី១៣ រាជាយស្ម័យយានកម្ពុជា ដល់រង្វង់មូលផ្សារដើមថ្កូវ៖ ចេញពីរាជាយស្ម័យយានកម្ពុជា កាត់តាម ផ្លូវសាធារណៈរដ្ឋឆេក ផ្លូវ១៦៣ ដល់រង្វង់មូលផ្សារដើមថ្កូវ។

### ២.២.៣.២. រថភ្លើងអាកាស

ថ្វីត្បិតតែមិនទាន់បានលេចចេញជារូបរាងនៅឡើយ ប៉ុន្តែបច្ចុប្បន្ននេះក្រសួងសាធារណការ និងដឹកជញ្ជូនរួមជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន-កម្ពុជា ហៅកាត់ថា(JICA) កំពុងសិក្សាលើការសាងសងរថភ្លើងអាកាសគ្មានមនុស្សបើក(AGT)ចំនួន៤ខ្សែនៅរាជធានីភ្នំពេញ។ ឯកឧត្តម ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូនបានបញ្ជាក់ថា " ការសិក្សាបឋមនេះ បានបញ្ចប់នៅមុនឆ្នាំ២០១៨ និងចាប់ផ្តើមសាងសង់ជាផ្លូវការនៅឆ្នាំ២០១៩ និងបញ្ចប់មុនឆ្នាំ២០២៣ ដើម្បីជាការត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះក្នុងព្រឹត្តិការណ៍ស៊ីហ្គេមឆ្នាំ២០២៣ និងរំដោះបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញផងដែរ។ គម្រោងសាងសង់រថភ្លើងអាកាសបែបបច្ចេកវិទ្យាជប៉ុននេះមាន៤ខ្សែ សរុបប្រវែង១៨គីឡូម៉ែត្រ ដែលក្នុងនោះមានមហាវិថីហ្សាលដឺហ្គោល មហាវិថីមុនីរ៉េត ផ្លូវវែងស្រេងឆ្ពោះទៅកាន់ព្រលានយន្តហោះ និងមួយខ្សែទៀតបែកខ្នែងទៅកាន់ផ្លូវជាតិលេខ៤ និងផ្លូវកប់ស្រូវឆ្ពោះទៅកាន់ពហុកីឡដ្ឋានជាតិថ្មីនៅព្រែកព្នៅ"[22]។

### ២.២.៣.៣. ស្ពានអាកាសថ្មើរជើង

ស្ពានអាកាសថ្មើរជើង គឺជាមធ្យោបាយថ្មីមួយដែលត្រូវបានគេលើកឡើងនៅដំណោះស្រាយបញ្ហាកកស្ទះចរាចរណ៍ក្នុងរាជធានីភ្នំពេញ។ ចំពោះការវាយតម្លៃពីប្រជាពលរដ្ឋ ការសាងសង់ស្ពានអាកាសថ្មើរជើងត្រូវបានគេចាប់អារម្មណ៍ នឹងប្រាកដជាបានដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះនៅតាមចំណុចប្រសព្វនានា។ ឆ្លើយតបទៅនឹងតម្រូវការប្រជាពលរដ្ឋ ស្ពានអាកាសថ្មើរជើងដំបូងបង្អស់នៅកម្ពុជាចំនួនពីរត្រូវបានប្រតិដ្ឋឡើងនៅតាមផ្លូវជាតិលេខ៤ ត្រង់សាលាបឋមសិក្សាជម្ពូវ័ន្ត និងវិទ្យាល័យចំណោះទូទៅហ៊ុនសែនជម្ពូវ័ន្តស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ ជាយរាជធានីភ្នំពេញដែលបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី០៥ខែឧសភា ឆ្នាំ២០១៧ ។ ចំណែកស្ពានអាកាសថ្មើរជើងនាងគង្ហីង ដែលជាស្ពានអាកាសថ្មើរជើងទីបីនៅក្នុងរាជធានីភ្នំពេញដែលត្រូវបានដាក់អោយដំណើរការ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៩។

---

[22] https://www.mpwt.gov.kh/ (ថតចម្លង នាថ្ងៃ១៩ ខែមីនា ឆ្នាំ២០២០)

ដោយឡែកបច្ចុប្បន្ននេះ ស្ពានអាកាសថ្មើរជើងផ្សារដើមគរ និងស្ពានអាកាសសាលាបឋមសិក្សាសន្ធរមុខ ដែលជាស្ពានថ្មើរជើងចុងក្រោយដែលទើបតែសាងសង់នៅក្នុងរាជធានីភ្នំពេញដែលត្រូវបានចាប់ផ្តើមសាងសង់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។ ហើយចំពោះគម្រោងស្ពានអាកាសថ្មើរជើងនេះផងដែរ សាលារាជធានីភ្នំពេញបានឲ្យដឹងថា បើគម្រោងស្ថាបនាស្ពាននេះទទួលការគាំទ្រពីប្រជាពលរដ្ឋនោះ សាលារាជធានីភ្នំពេញអាចនឹងពង្រីកគម្រោងស្ថាបនានេះនៅលើផ្លូវផ្សេងៗមួយចំនួនទៀត ដែលស្ពានអាកាសថ្មើរជើងទាំងនេះនឹងត្រូវសាងសង់នៅមុខសាលារៀន មន្ទីរពេទ្យ និងផ្សារជាដើម ដើម្បីបង្កើនការការពារផ្នែកសុវត្ថិភាពជូនប្រជាពលរដ្ឋនៅពេលឆ្លងកាត់ផ្លូវ និងកាត់បន្ថយការកកស្ទះចរាចរណ៍[23]។

### ២.២.៣.៤. ការដឹកជញ្ជូនតាមផ្លូវទឹក

នៅពេលដែលប្រជាពលរដ្ឋនិយាយអំពី "ហេដ្ឋារចនាសម្ព័ន្ធនៃការដឹកជញ្ជូន" ពួកគេទាំងអស់សុទ្ធតែបានលើកឡើងពីមធ្យោបាយដឹកជញ្ជូនតាម ផ្លូវអាកាស ផ្លូវល្បឿនលឿន ផ្លូវថ្នល់ ផ្លូវដែកជាដើម ដែលជាទូទៅមិនសូវមានមនុស្សច្រើននោះទេដែលបានដឹងថាមធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក គឺវាមានសក្តានុពលខ្លាំងក្នុងការលើកកម្ពស់ការប្រកួតប្រជែងលើផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា។ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសកម្មភាពតាមផ្លូវទឹក វានឹងត្រូវបានគេប្រើប្រាស់ដោយមានអត្ថប្រយោជន៍ក្នុងតម្លៃទាប ក្នុងការដឹកជញ្ជូនផលិតផលកសិកម្ម ទំនិញ ផលិតផលនាំចេញ និងធនធានផ្សេងទៀតពីខេត្តក្រុងនានាទៅកំពង់ផែភ្នំពេញ។ ប្រសិនបើរដ្ឋាភិបាលកម្ពុជាលើកទឹកចិត្តដល់សកម្មភាពដឹកជញ្ជូនបែបនេះវានឹងអាចកាត់បន្ថយការដឹកជញ្ជូនចរាចរណ៍ធ្ងន់ៗ ពីតាមបណ្តាខេត្តនានាមកកាន់រាជធានីភ្នំពេញ ។

បច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាកំពុងណែនាំសេវាដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកតាមដងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់មកកាន់រាជធានីភ្នំពេញ។ ទោះបីប្រជាជនកម្ពុជាមានការនិយមខ្លាំងក្នុងការប្រើម៉ូតូឬរថយន្តផ្ទាល់ខ្លួនក៏ដោយ ប៉ុន្តែតាក់ស៊ីផ្លូវទឹកអាចទាក់ទាញចំណាប់អារម្មណ៍របស់ពួកគាត់ ហើយវាអាចផ្លាស់ប្តូរផ្នត់គំនិតរបស់ពួកគាត់ ជាពិសេសក្នុងចំណោមក្មេងៗជំនាន់ក្រោយ ក្នុងការគាំទ្រការដឹកជញ្ជូនសាធារណៈ។ កត្តានេះ មិនត្រឹមតែកាត់បន្ថយការដឹកជញ្ជូនតាមផ្លូវគោកនោះទេ ប៉ុន្តែការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវទឹកនឹងក្លាយជាដំណោះស្រាយជំនួសមួយ ដើម្បីកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ។

យោងតាមក្រសួងសាធារណការ និងដឹកជញ្ជូនបានឱ្យដឹងថាទូកចំនួន៤គ្រឿងនឹងត្រូវបានប្រើប្រាស់ដើម្បីបម្រើដល់អ្នកដំណើរចំនួន៤ជើងជារៀងរាល់ថ្ងៃ។ ទូកនេះមានសមត្ថភាពអាចផ្ទុកអ្នកដំណើររហូតដល់ទៅ៩០នាក់ហើយបំពាក់ជាមួយនឹងម៉ាស៊ីនត្រជាក់ និងប្រព័ន្ធសុវត្ថិភាពព្រមទាំងអាចធ្វើដំណើរបាន៣០គីឡូម៉ែត្រក្នុងមួយម៉ោង។ ប្រសិនបើការធ្វើដំណើរតាមផ្លូវទឹកនេះបានដំណើរការ អ្នកធ្វើការទូទៅ និងកម្មកររោងចក្រមួយចំនួនដែលស្ថិតនៅមិនឆ្ងាយពីច្រាំងទន្លេនឹងអាចទាញយកប្រយោជន៍ពីសេវាកម្មនេះ។ នៅក្នុងដំណាក់កាល

[23] http://phnompenh.gov.kh/(ថតចម្លង នាថ្ងៃ២០ ខែមីនា ឆ្នាំ២០២០)

បន្ទាប់ ក្រសួងសាធារណការ និងដឹកជញ្ជូននឹងចាប់ផ្តើមការដឹកជញ្ជូនទំនិញ ដែលតភ្ជាប់ទៅកំពង់ផែរាជធានីភ្នំពេញសម្រាប់ការដឹកជញ្ជូនផលិតផលកសិកម្ម។ ការធ្វើដំណើរតាមទូក គឺមានល្បឿនលឿនជាងបីដងនៃការធ្វើដំណើរតាមផ្លូវគោកពីព្រោះគ្មានការកកស្ទះចរាចរណ៍នៅលើផ្លូវទឹកទេ ហើយការដឹកជញ្ជូនតាមផ្លូវទឹកនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍តាមដងផ្លូវពីបណ្តាខេត្តនានាមករាជធានីភ្នំពេញ ព្រមទាំងបានកាត់បន្ថយយានយន្តធុនធ្ងន់ដែលបណ្តាលឱ្យខូចខាតផ្លូវ និងគ្រោះថ្នាក់ចរាចរណ៍។[24]

### ២.២.៤. ការកាត់បន្ថយការប្រើប្រាស់យានយន្ត

បន្ទាប់ពីការអប់រំ និងផ្សព្វផ្សាយអំពីបញ្ហានានាពាក់ព័ន្ធនឹងការកកស្ទះចរាចរណ៍ ក្នុងនោះការកាត់បន្ថយការប្រើប្រាស់យានយន្តជាដំណោះស្រាយដ៏សំខាន់មួយដែលនឹងត្រូវបានលើកឡើងនៅក្នុងការអនុវត្តជាចាំបាច់របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ចៀសនូវការកកស្ទះចរាចរណ៍។ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការណែនាំ និងផ្សព្វផ្សាយពីអត្ថប្រយោជន៍ក្នុងការកាត់បន្ថយការប្រើប្រាស់យានយន្ត និងលាតត្រដាងអំពីផលអវិជ្ជមានចំពោះសង្គមទាំងមូលក្នុងករណីមានការកើនឡើងនៃការប្រើប្រាស់យានយន្តដល់ប្រជាពលរដ្ឋ ហើយលើសពីនេះទៅទៀតនោះ ចាំបាច់ត្រូវតែត្រួតពិនិត្យឲ្យបានល្អិតល្អន់បំផុតចំពោះការនាំចូលនូវប្រភេទយានជំនិះដែលមិនសាកសមសម្រាប់ការបើកបរនៅក្នុងប្រទេសកម្ពុជា និងត្រួតពិនិត្យចំពោះអ្នកបើកបរយានជំនិះដែលទាមទារឲ្យមាន បណ្ណបើកបរត្រឹមត្រូវទៅតាមច្បាប់។ ឆ្លើយតបទៅនឹងបញ្ហានេះផងដែរ មួយរយៈចុងក្រោយនេះគេឃើញមានការកើនឡើងចំនួនរថយន្តនៅក្នុងរាជធានីភ្នំពេញ ហើយតួយ៉ាងមានគ្រោះថ្នាក់ចរាចរណ៍មួយចំនួនបានបង្កឡើងដោយជនបរទេសដែលច្បាប់មិនបានប្រគល់សិទ្ធិឲ្យបើកបរនៅក្នុងប្រទេសកម្ពុជា។ ការកាត់បន្ថយចំនួនយានយន្តនៅកម្ពុជាមិនត្រឹមតែធានាឲ្យការកាត់បន្ថយការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញមានប្រសិទ្ធិភាពប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងជួយសម្រាលបញ្ហាសណ្តាប់ធ្នាប់សាធារណៈ និងចៀសវាងការបំពុលបរិស្ថានផងដែរ។

### ២.២.៥. ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងទំនួលខុសត្រូវ

គ្រប់ការអនុវត្តវិធានការ ឬផែនការរបស់អង្គភាពសាធារណៈ ចាំបាច់ទាមទារឲ្យការអនុវត្តនោះ ទទួលបានភាពជោគជ័យត្រលប់មកវិញ ដើម្បីទទួលបាននូវលទ្ធផលល្អ មន្ត្រីសាធារណៈដែលទទួលបន្ទុកកិច្ចការទាំងនោះចាំបាច់ត្រូវតែបំពេញការងារដោយម៉ត់ចត់ យកចិត្តទុកដាក់ អត់ធ្មត់ និងមានផែនការអនុវត្តសកម្មភាពត្រឹមត្រូវច្បាស់លាស់។ ជាក់ស្តែងណាស់ នៅក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍នេះ សាលារាជធានីភ្នំពេញបានដាក់ចេញនូវយុទ្ធនាការមួយ ដែលប្រជាពលរដ្ឋស្ទើរតែគ្រប់គ្នាបានដឹងថា ជាយុទ្ធនាការរំដោះចិញ្ចើមផ្លូវ ពីការរំលោភបំពានរបស់អ្នកលក់ដូរនៅតាមចិញ្ចើមផ្លូវ។ ប៉ុន្តែចំពោះលទ្ធផលនៃការអនុវត្តយុទ្ធនាការរំដោះចិញ្ចើមផ្លូវ

[24] https://www.mpwt.gov.kh/kh/ (ថតចម្លង ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០)

វិញនោះ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានលើកឡើងក្នុងពេលចូលរួមបិទសន្និបាតបូកសរុបការងាររបស់សាលារាជធានីភ្នំពេញថា ″ ការដែលកាសែតភ្នំពេញប៉ុស្តិ៍ថា សាលារាជធានីភ្នំពេញបរាជ័យក្នុងយុទ្ធនាការរំដោះចិញ្ចើមផ្លូវនោះហាក់បីដូចជាត្រឹមត្រូវ ហើយសំខាន់យើងមិនទាន់អាចដោះស្រាយបញ្ហាហ្នឹងបានមែន ហើយគេថាហ្នឹងត្រឹមត្រូវរបស់គេហើយ ព្រោះពលរដ្ឋយើងគាត់លក់ដូរស្ទើរតែគ្រប់កន្លែង បើពលរដ្ឋយើងយល់ដឹងពីសណ្ដាប់ធ្នាប់នេះច្រើន រាជធានីរបស់យើងនឹងកាន់តែមានសម្រស់ថែមទៀត[25]″។

លើសពីនេះទៅទៀតនោះ អ្វីដែលថ្នាក់ដឹកនាំ និងមន្ត្រីរាជការគួរតែយកចិត្តទុកដាក់នោះ គឺការអនុវត្តការបើកបរជាគំរូសម្រាប់ប្រជាពលរដ្ឋមើលឃើញអំពីគុណតម្លៃដ៏គួរឲ្យគោរពរបស់អ្នកដឹកនាំប្រទេស។ សម័យកាលនេះ បើទោះបីជាបច្ចេកវិទ្យាក្នុងប្រទេសយើងមិនអាចប្រៀបផ្ទឹមនឹងប្រទេសអភិវឌ្ឍធំៗបានក៏ដោយ ប៉ុន្តែប្រសិនបើទង្វើរបស់បុគ្គលណាម្នាក់ធ្វើឲ្យមានផលប៉ះពាល់ដល់សង្គមនោះ អ្នកប្រើប្រាស់ក្នុងប្រព័ន្ធសង្គមអ៊ីនធឺណេតនឹងប្រាកដជាចេញមុនវាយប្រហារហើយមានប្រជាពលរដ្ឋរាប់ម៉ឺននាក់បាននឹងកំពុងមើលផងដែរ។ ទស្សនៈជាច្រើនលើកឡើងថា បើគេថតបាន ឬឃើញប្រជាពលរដ្ឋណាម្នាក់ជាអ្នកបើកបរបញ្ច្រាសផ្លូវ គេចាត់ទុកថាមកពីគាត់មិនបានយល់ពីច្បាប់ មិនយល់ពីការបើកបរ ឬជាមនុស្សអាត្មានិយម ចុះប្រសិនបើមន្ត្រីរាជការម្នាក់ដែលកំពុងនឹងប្រើប្រាស់មធ្យោបាយសាធារណៈហើយបានបំពានដូចគ្នានោះ តើប្រជាពលរដ្ឋមានការយល់យ៉ាងដូចម្ដេច ?

### ២.២.៦ ការចូលរួមរបស់ប្រជាពលរដ្ឋ

ការចូលរួមរបស់ប្រជាពលរដ្ឋពិតជាមានសារៈសំខាន់ចំពោះការដោះស្រាយបញ្ហានានារបស់សង្គម ពីព្រោះថាពេលខ្លះប្រជាពលរដ្ឋអាចជាអ្នកជួបប្រទះបញ្ហាអស់ទាំងនោះដោយផ្ទាល់ ដូច្នេះការចូលរួមរបស់ពួកគាត់ពិតជាមានអត្ថប្រយោជន៍ខ្លាំង។ ជាក់ស្ដែងចំពោះបញ្ហាកកស្ទះនេះ បើប្រជាពលរដ្ឋនីមួយៗ ចេះយោគយល់អធ្យាស្រ័យគ្នាក្នុងនាមជាអ្នកបើកបរដូចគ្នានោះ ម្លេះសមនឹងបញ្ហានេះត្រូវបានកាត់បន្ថយជាអតិបរិមាជាក់ជាមិនខាន។ ចូរផ្ដើមធ្វើជាពលរដ្ឋគំរូនៅក្នុងសង្គមរស់នៅ ដើម្បីកែលម្អអ្វីដែលជាចំណុចអវិជ្ជមាននៅក្នុងសង្គម យូរទៅៗប្រជាពលរដ្ឋផ្សេងៗទៀតនឹងចាប់ផ្ដើមអនុវត្តតាមរហូតក្លាយទៅជាសង្គមដែលពោរពេញដោយភាពល្អប្រសើរ និងសេចក្ដីថ្លៃថ្នូរ។

[25] www.postkhmer.com (ថតចម្លង នាថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០)

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយបញ្ហាកកស្ទះចរាចរណ៍ ប្រជាពលរដ្ឋគួរតែត្រូវបានយល់ដឹងពីអ្វីដែលមានចែងនៅក្នុងច្បាប់ចរាចរណ៍ ហើយកត្តាដែលនាំឱ្យកកស្ទះចរាចរណ៍សំខាន់ទាក់ទងនឹងច្បាប់ចរាចរណ៍នោះគឺ សិទ្ធិអាទិភាព ដែលសិទ្ធិអាទិភាពត្រូវបានកំណត់ដូចខាងក្រោម៖[26]

១.គ្រប់អ្នកបើកបរនៅពេលដែលទៅជិតដល់ផ្លូវប្រសព្វ ត្រូវបន្ថយល្បឿន និងពិនិត្យមើលចលនាចរាចរណ៍នៅលើទ្រូងផ្លូវដែលខ្លួនត្រូវឆ្លងកាត់នោះ ហើយត្រូវធ្វើដំណើរឆ្លងកាត់ដោយប្រុងប្រយ័ត្នបំផុត បើផ្លូវខាងមុខមិនស្រលះល្អ។ ក្នុងករណីចាំបាច់ ត្រូវធ្វើសញ្ញាឲ្យដំណឹងដល់អ្នកបើកបរដែលមកពីផ្លូវផ្សេងគ្នា ដោយប្រើសញ្ញាសូរសព្ទពេលថ្ងៃ និងប្រើភ្លើងសញ្ញាកូត ហ្វាឆ្លាស់គ្នានៅពេលយប់។ នៅលើផ្លូវផ្តល់សិទ្ធិអាទិភាពឲ្យគេ អ្នកបើកបរត្រូវបើកបរក្នុងល្បឿនមួយដែលអាចបញ្ឈប់យានខ្លួនបាន ដើម្បីផ្តល់សិទ្ធិដល់យានដែលនៅលើផ្លូវមានសិទ្ធិទៅមុន។

២.ទោះបីនៅត្រង់ផ្លូវប្រសព្វ មានភ្លើងសញ្ញាចរាចរណ៍ពណ៌បៃតងដែលបានអនុញ្ញាតឲ្យធ្វើចរាចរណ៍ទៅមុខបានក៏ដោយ ក៏អ្នកបើកបរមិនត្រូវបើកចូលទៅក្នុងផ្លូវប្រសព្វឡើយ ប្រសិនបើអំពើនេះអាចតម្រូវឲ្យខ្លួនបញ្ឈប់យានជំនិះនៅក្នុងផ្លូវប្រសព្វដោយសារតែមានចរាចរណ៍ចង្អៀតខ្លាំង។ ក្នុងករណីបែបនេះ អ្នកបើកបរត្រូវឈប់នៅមុខផ្លូវប្រសព្វ ដើម្បីកុំឲ្យស្ទះចរាចរណ៍យានដែលមកពីទិសផ្សេងទៀត។

៣. នៅផ្លូវប្រសព្វដែលគ្មានសញ្ញាអាទិភាព អ្នកបើកបរត្រូវទុកសិទ្ធិឲ្យអ្នកបើកបរយានដែលមកពីស្តាំរបស់ខ្លួនទៅមុន។ ប៉ុន្តែក្នុងករណីផ្លូវប្រសព្វបែកជាបីដែលគ្មានសញ្ញាសិទ្ធិអាទិភាព អ្នកបើកបរយាននៅផ្លូវដែលចប់ត្រូវទុកសិទ្ធិឲ្យអ្នកបើកបរយាននៅផ្លូវត្រូវបន្តទៅមុខ។

៤. អ្នកបើកបរដែលទៅដល់រង្វង់មូល ទោះបីខ្លួនស្ថិតនៅក្នុងផ្លូវប្រភេទណាក៏ដោយ ត្រូវផ្តល់សិទ្ធិអាទិភាពឲ្យអ្នកបើកបរដែលស្ថិតនៅក្នុងទ្រូងផ្លូវឯកទិសក្រវាត់រង្វង់មូលដែលមានសញ្ញាបង្ហាញទិសទៅមុន។

៥. នៅពេលទៅដល់ផ្លូវប្រសព្វដែលមានសញ្ញាសម្គាល់សិទ្ធិអាទិភាព អ្នកបើកបរត្រូវទុកផ្លូវឲ្យយានជំនិះដែលស្ថិតនៅលើផ្លូវមានសិទ្ធិអាទិភាពធ្វើដំណើរទៅមុនហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះបានតែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

៦. នៅពេលទៅដល់ផ្លូវប្រសព្វដែលមានដាក់សញ្ញាថា ឈប់ អ្នកបើកបរត្រូវឈប់ស្ងៀមនៅមុខគំនូសកាត់ទទឹងទ្រូងផ្លូវ ដើម្បីទុកឲ្យយានជំនិះ និងថ្មើរជើងដែលនៅលើផ្លូវមានសិទ្ធិធ្វើដំណើរទៅមុខ ហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះបានតែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

[26] មាត្រា២១ នៃច្បាប់ចរាចរណ៍ផ្លូវគោកឆ្នាំ២០១៧

៧. ដោយឡែកអ្នកបើកបរត្រូវតែទុកឲ្យយានជំនិះបម្រើការរបស់នគរបាល យោធា កងរាជអាវុធហត្ថ យានពន្លត់អគ្គិភ័យ ឬយានសង្គ្រោះរបស់មន្ទីរពេទ្យដែលកំពុងបំពេញភារកិច្ចដោយឲ្យសញ្ញាសូរសព្ទ និងសញ្ញាភ្លើងពិសេសឲ្យដឹងអំពីការមកដល់របស់ខ្លួនទៅមុន។

៨.យានជំនិះកំពុងបំពេញភារកិច្ចដូចខាងក្រោមមានសិទ្ធិអាទិភាពតាមលំដាប់ដូចតទៅ៖

- យានពន្លត់អគ្គិភ័យ
- យានសង្គ្រោះរបស់មន្ទីរពេទ្យ
- យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ

៩.មុននឹងបើកបរចេញពីផ្លូវឯកជនដែលមិនបើកឲ្យធ្វើចរាចរណ៍ជាសាធារណៈដូចជា ពីច្រកគេហដ្ឋាន រោងចក្រ អគារ ឬទីលានផ្សេងៗ អ្នកបើកបរត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវទុកសិទ្ធិអាទិភាពឲ្យយានជំនិះ ឬថ្មើរជើងដែលកំពុងចរាចរណ៍លើផ្លូវសាធារណៈទៅមុន។

១០. អ្នកបើកបរចេញពីផ្លូវលំ ឬផ្លូវដី ត្រូវទុកសិទ្ធិឲ្យអ្នកបើកបរលើផ្លូវផ្សេងទៀតដែលមិនមែនជាផ្លូវលំ ឬផ្លូវដីទៅមុន។

១១. នៅត្រង់ផ្លូវប្រសព្វ បើទ្រូងផ្លូវមួយមានចែកជាច្រើនគន្លងផ្លូវ ហើយមានគន្លងផ្លូវមួយ ឬច្រើនត្រូវបម្រុងសម្រាប់យានជំនិះប្រភេទខ្លះធ្វើចរាចរណ៍ បទប្បញ្ញត្តិស្ដីពីអាទិភាពចរាចរណ៍ដែលមានចែងក្នុងមាត្រានេះត្រូវអនុវត្តចំពោះអ្នកបើកបរដែលធ្វើចរាចរណ៍លើគន្លងផ្លូវប្រភេទនេះ លើកលែងតែយានជំនិះដែលមានចែងនៅក្នុងចំណុចទី៧ និងចំណុចទី៨ខាងលើនេះ។

ក្រៅពីនេះប្រជាពលរដ្ឋត្រូវធ្វើការស្វែងយល់អំពីអត្ថន័យនៃខ្លឹមសារមួយចំនួនទៀត ដែលជាទូទៅតែងតែមានការភ័ន្តច្រឡំពាក់ព័ន្ធនឹងពាក្យដែលត្រូវបានប្រើប្រាស់នៅក្នុងផ្លូវថ្នល់ ជៀសវាងការរំលោភបំពានលើច្បាប់ស្ដីពីផ្លូវថ្នល់ និងច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក៖

- ទ្រូងផ្លូវ សំដៅដល់ចំណែកនៃផ្លូវទុកសម្រាប់ឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។
- ជាយផ្លូវ សំដៅលើផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជន ដែលយានជំនិះអាចចតនៅទីនោះបានក្នុងករណីចាំបាច់។
- ចិញ្ចើមផ្លូវ សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។

- គន្លងផ្លូវ សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវ ខណ្ឌដោយគំនូស ឬបរិក្ខារចែងចំណែកផ្លូវតាមបណ្ដោយទ្រូងផ្លូវ ដែលមានទទឹងគ្រប់គ្រាន់អាចឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ។
- ច្រកចេញចូលផ្ទះឯកជន សំដៅដល់ច្រកចេញចូលផ្ទះដែលមានផ្ទៃរាបស្មើភ្ជាប់ជាមួយនឹងផ្លូវសាធារណៈ និងមិនមែនជាចិញ្ចើមផ្លូវ។
- ឈប់ សំដៅលើការនៅស្ងៀមរបស់យានជំនិះលើទ្រូងផ្លូវមួយរយៈពេលខ្លី ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះរបស់ខ្លួន ដើម្បីឲ្យអ្នកធ្វើដំណើរ ឬយានជំនិះដទៃឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ។
- ចត សំដៅដល់ការទុកឲ្យយានជំនិះនៅស្ងៀមក្នុងរយៈពេលយូរ ឬឆាប់ ដែលអ្នកបើកបរអាចដើរចោលយានជំនិះរបស់ខ្លួនបាន។

ក្រៅពីនេះទៅទៀតនោះ ក្នុងនាមជាប្រជាពលរដ្ឋនៃរដ្ឋមួយ ក្នុងនាមជាម្ចាស់នៃប្រទេសមួយចាំបាច់មានភារកិច្ចក្នុងការចូលរួមសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់ស្រទាប់ជាន់ថ្នាក់ក្នុងការអនុវត្តច្បាប់ក្នុងប្រទេសឱ្យមានប្រសិទ្ធិភាព និងចៀសវាងឲ្យបានរាល់ទង្វើទាំងឡាយណាដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សង្គមទាំងមូល ជាពិសេសការផ្សព្វផ្សាយព័ត៌មានទាំងឡាយគ្មានប្រភពដំណឹងច្បាស់លាស់ដែលទង្វើទាំងអស់នោះមិនត្រឹមតែមិនបានចូលរួមកែលម្អសង្គមនោះទេ ថែមទាំងបង្កជាបញ្ហាដល់សណ្ដាប់ធ្នាប់សាធារណៈថែមទៀតផង។

### ២.២.៧. ការចូលរួមរបស់យុវជនស្ម័គ្រចិត្ត

យុវជនជាធនធានគន្លឹះ និងមានតម្លៃបំផុតសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ បរិស្ថាន និងការរក្សាសន្តិភាព ហើយនៅគ្រប់សម័យកាល គ្រប់សង្គម យុវជនជាកម្លាំងស្នូលដែលមានកម្លាំងកាយកម្លាំងចិត្ត និងស្មារតីភ្លឺស្វាង មានទឹកចិត្តក្លាហានពុះពារមិនរារែកគ្រប់ឧបសគ្គ ការលំបាកនានា ជាពិសេសយុវជន គឺជាសសរទ្រូងរបស់ប្រទេសជាតិទាំងនៅពេលបច្ចុប្បន្ន និងទៅអនាគត។ យ៉ាងណាមិញទាក់ទង់នឹងសកម្មភាពចរាចរណ៍នៅក្នុងរាជធានីភ្នំពេញយើងក៏ឃើញមានក្រុមយុវជនស្ម័គ្រចិត្តជាច្រើនក្រុម បានធ្វើការចំណាយពេលវេលាផ្ទាល់ខ្លួនក្នុងការចូលរួមយ៉ាងសកម្មពីក្រុមយុវជនដូចជា ក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហម ក្រុមយុវជនកាយរឹទ្ធិ និងក្រុមយុវជនគំរូដើម្បីសុវត្ថិភាពចរាចរណ៍។

+យុវជនកាកបាទក្រហមកម្ពុជា និងក្រុមយុវជនកាយរឹទ្ធិ គឺជាក្រុមស្ម័គ្រចិត្តវ័យក្មេង ដែលជាកម្លាំងស្នូលមួយដ៏មានសារៈសំខាន់ និងសកម្មបំផុតក្នុងសកម្មភាពចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ ប្រកបដោយការប្ដេជ្ញាចិត្តខ្ពស់ និងការលះបង់តតងាករេ ស្របតាមប្រធានបទ យុវជនកំពុងនាំគ្នាធ្វើសកម្មភាព យុវជនជាភ្នាក់ងារនៃការផ្លាស់ប្ដូរឥរិយាបថក្នុងសង្គម។ សកម្មភាពរបស់យុវជនកាកបាទក្រហមកម្ពុជាចូលរួមចំពោះការកកស្ទះ

ចរាចរណ៍នៅក្នុងរាជធានីភ្នំពេញមានដូចជា អំពាវនាវឲ្យប្រជាពលរដ្ឋប្រតិបត្តិច្បាប់ចរាចរណ៍ឲ្យបានខ្ជាប់ខ្ជួនដូចជា គោរពផ្លាកសញ្ញាចរាចរណ៍ គោរពភ្លើងស្តុប ការពាក់មួកសុវត្ថិភាពក្នុងពេលបើកបរ ការមិនប្រើប្រាស់ទូរស័ព្ទក្នុងពេលបើកបរ មិនប្រលែងគ្នាក្នុងពេលកាន់ដៃចង្កូត មិនត្រូវបើកបរក្នុងស្ថានភាពស្រវឹង និងបើកបរលើសល្បឿនកំណត់ជាដើម។

+យុវជនគំរូដើម្បីសុវត្ថិភាពចរាចរណ៍ គឺជាក្រុមយុវជនមួយក្រុមដែលមានសកម្មភាពជាច្រើន នៅក្នុងការទប់ស្កាត់ការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តនានា ដោយក្រុមយុវជននេះបានទទួលការបណ្តុះបណ្តាលនៅតាមសាកលវិទ្យាល័យមួយចំនួននៅក្នុងរាជធានីភ្នំពេញ ហើយក្រុមនេះបានធ្វើការចុះទៅផ្សព្វផ្សាយបន្តនៅតាមបណ្តាវិទ្យាល័យមួយចំនួននៅក្នុងរាជធានីភ្នំពេញនូវចំណេះដឹងទាក់ទងនឹងច្បាប់ចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយក្រៅពីនេះ ក្រុមយុវជនគំរូដើម្បីសុវត្ថិភាពចរាចរណ៍ក៏មានរៀបចំកម្មវិធីសំណួរចម្លើយទាក់ទងនឹងច្បាប់ចរាចរណ៍នៅតាមបណ្តាញសង្គម(facbook) ហើយមានជារង្វាន់លើកទឹកចិត្តចំពោះបេក្ខជនណាដែលឆ្លើយត្រូវនឹងសំនួរ ដោយផ្តល់ជាមួកសុវត្ថិភាពជូន ដែលសកម្មភាពនេះគឺជាសកម្មភាពមួយដែលបានចូលរួមចំណែកក្នុងការកាត់បន្ថយនូវបញ្ហាកកស្ទះចរាចរណ៍បានយ៉ាងច្រើន។

ដោយមានការចូលរួមយ៉ាងសស្រាកសស្រានពីក្រុមយុវជនយ៉ាងនេះ នោះស្ថានភាពចរាចរណ៍នឹងល្អប្រសើរឡើង ដោយសារការផ្តល់ជូននូវគំរូរបស់ក្រុមយុវជនចំពោះប្រជាពលរដ្ឋ វានឹងធ្វើអោយពួកគាត់ដែលជាមនុស្សធំមានការអៀនខ្មាស់ចំពោះទង្វើរបស់ខ្លួន ដែលពួកគាត់ជាមនុស្សធំ ប៉ុន្តែបែជាមកទទួលការអប់រំណែនាំពីកូនក្មេងទៅវិញ។

### ២.២.៨. ការចូលរួមពីអង្គការដែលពាក់ព័ន្ធ

ជាទូទៅ នៅក្នុងសង្គមមួយដែលមានការអភិវឌ្ឍជឿនលឿនយ៉ាងណាក៏ដោយ គឺតែងតែមាននូវការខ្វះចន្លោះនៅចំណុចណាមួយជាក់ជាពុំខាន។ តួយ៉ាងនៅក្នុងប្រទេសកម្ពុជាយើងសេដ្ឋកិច្ចមានការរីកចម្រើនទៅមុខគួរអោយកត់សម្គាល់លើគ្រប់វិស័យ ប៉ុន្តែក៏នៅមានចំណុចខ្វះចន្លោះមួយចំនួនដែលត្រូវធ្វើការបំពេញ ទើបថ្នាក់ដឹកនាំបានបង្កើនកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជននានា ដើម្បីរៀបចំយុទ្ធនាការផ្សេងៗក្នុងការដោះស្រាយបញ្ហាដែលនៅមានចំណុចខ្វះចន្លោះទាំងនោះ។ ដោយឡែកចំពោះបញ្ហាកកស្ទះចរាចរណ៍នេះផងដែរ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានយកចិត្តទុកដាក់ជាខ្លាំងក្នុងការដោះស្រាយបញ្ហានេះ ដោយចេញនូវវិធានការផ្សេងក្នុងការអនុវត្តទប់ស្កាត់នូវបញ្ហាកកស្ទះចរាចរណ៍នេះ លើសពីនេះទៅទៀត រដ្ឋាភិបាលបានអនុញ្ញាតអោយមានការចូលរួមនូវសកម្មភាពផ្សេងៗរបស់អង្គការសង្គមស៊ីវិល និង

វិស័យឯកជនជាច្រើនដូចជា អង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោក[27] អង្គការមូលនិធិបង្ការរបួសអាស៊ី[28] កាយរឹទ្ធិ[29] និងកាកបាទក្រហមជាដើម[30] ។

### ២.២.៩. ការអនុវត្តច្បាប់

ជាទូទៅក្នុងការអនុវត្តច្បាប់នៅក្នុងប្រទេសមួយ គឺតែងតែមាននូវការធ្វើវិសោធនកម្មច្បាប់អោយសមស្របទៅតាមនឹងសម័យកាល បច្ចេកទេសជឿនលឿន ការប្រែប្រួលនៃសង្គម ការរីកចម្រើននៃវិទ្យាសាស្ត្រ មានការប្រែប្រួលប្រព័ន្ធនយោបាយ និងតម្រូវការជាក់ស្តែង។ ក្នុងនោះប្រទេសកម្ពុជាក៏មានការធ្វើវិសោធនកម្មទៅលើច្បាប់មួយចំនួន ដើម្បីអោយការអនុវត្តច្បាប់ដើរទាន់នឹងការរីកចម្រើននៃប្រទេសកម្ពុជាសព្វថ្ងៃដោយសារស្ថានភាពសង្គមយើងនៅសតវត្សទី២១នេះ គឺមានការរីកចម្រើនយ៉ាងខ្លាំងលើគ្រប់វិស័យ។ បើយើងក្រឡេកមកមើលទៅលើសកម្មភាពទាក់ទងនឹងចរាចរណ៍នៅក្នុងរាជធានីភ្នំពេញក៏មានភាពប្រែប្រួលទៅតាមនឹងដែរ ដែលជាហេតុធ្វើអោយច្បាប់ចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានធ្វើវិសោធនកម្ម ជាច្រើនលើកច្រើនសារ ដើម្បីអោយទាន់នឹងការប្រែប្រួលនេះ។ ក្រៅពីនេះចំពោះការអនុវត្តច្បាប់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជា គឺរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៤៤ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីផ្តល់ភាពងាយស្រួលក្នុងការអនុវត្តរបស់មន្ត្រីនគរបាលចរាចរណ៍ ក្នុងការផាកពិន័យចំពោះបទល្មើសណាដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ហើយនៅក្នុងពេលថ្មីៗនេះរដ្ឋាភិបាលបានចេញអនុក្រឹត្យថ្មីស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ដែលអនុក្រឹត្យនេះត្រូវបានកែសម្រួលនូវមាត្រាមួយចំនួនដូចខាងក្រោម៖

**ក** ៖ ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន ចំពោះអំពើល្មើសដូចខាងក្រោម៖

១.ត្រូវពិន័យទឹកប្រាក់ចំនួន៦០០០០ រៀល ចំពោះអ្នកបើកបរដែលបាន

អំពើល្មើសដូចជា អ្នកបើកបរ និងអ្នករួមដំណើរមិនពាក់មួកសុវត្ថិភាពត្រឹមត្រូវតាមស្តង់ដារជាតិ អ្នកបើកបរទោចក្រយានយន្តមានទំហំស៊ីឡាំងលើសពី១២៥ សង់ទីម៉ែត្រគូប ឬមានថាមពលអគ្គិសនីលើសពី១១គីឡូវ៉ាត់ ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬម៉ូតូកង់បួន ដែលមិនបានយកឯកសារដើមនៃបណ្ណបើកបរជាប់តាមខ្លួនឈប់ ឬចតល្មើសនឹងមាត្រា២៣នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បើកបរដោយកុងទ័រមិនដំណើរការ បើកបរលើស

[27] https://opendevelopmentcambodia.net/គេហទំព័រអង្គការសម្ព័ន្ធដើម្បីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

[28] http://www.saferoads.org.kh/គេហទំព័រអង្គការមូលនីធិបង្ការរបួសអាស៊ី

[29] http://www.cambodiascouts.org.kh/ គេហទំព័រកាយរឹទ្ធិកម្ពុជា

[30] https://redcross.org.kh/ គេហទំព័រកាកបាទក្រហមកម្ពុជា

ល្បឿនកំណត់ចាប់ពី១ ទៅ១៩ គីឡូម៉ែត្រក្នុងមួយម៉ោង បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ នៃមាត្រា៨ថ្មី បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍ បើកបរដោយគ្មានកញ្ចក់មើលក្រោយ

២.ត្រូវពិន័យទឹកប្រាក់ចំនួន ៨០០០០ រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តល្មើសដូចជា ប្រើប្រាស់ទូរស័ព្ទនៅពេលបើកបរ បើកបរប្រើសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមបញ្ញត្តិច្បាប់ បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស បើកបរលើសល្បឿនកំណត់ចាប់ពី២០ ទៅ២៩ គីឡូម៉ែត្រក្នុងមួយម៉ោង។

៣.ត្រូវពិន័យទឹកប្រាក់ចំនួន ១០០០០០ រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចជា បើកបរបង្ហោះ ធេចុះឡើង ឆាប ឬគៀរ បើកបរអូសជន្ទល់លើផ្លូវថ្នល់ ឬព្រលែងដៃចង្កូត ឬលើកជើងដាក់លើចង្កូត បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើនខុសពីបទដ្ឋានបច្ចេកទេស បើកបរមិនគោរពលក្ខខណ្ឌសុខភាពតម្រូវឱ្យពាក់វ៉ែនតាដែលមានកំណត់នៅក្នុងបណ្ណបើកបរ បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្កូតកណ្តាលទ្រូងផ្លូវ បើកបរលើសល្បឿនកំណត់ចាប់ពី៣០ ទៅ៣៩ គីឡូម៉ែត្រក្នុងមួយម៉ោង បើកបរល្មើសនឹងការជៀស ការបត់ និងការដែលដែង បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្តូរទិស ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស បើកបរដោយគ្មាន ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងបំភ្លឺផ្លាកលេខភ្លើងសញ្ញាប្តូរទិស ភ្លើងហ្វ្រាំង បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែត បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១៥ នៃមាត្រា៥៦ ន,២,ៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

៤. ត្រូវពិន័យទឹកប្រាក់ចំនួន ១២០០០០ រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចជា៖ បើកបរដោយគ្មានបណ្ណបើកបរក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ឬហួសសុពលភាព បើកបរដោយគ្មានបណ្ណសម្គាល់ និងផ្លាកលេខ បើកបរដោយមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានតាមច្បាប់កំណត់ ប្តូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត ប្រើបណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន ប្រើស្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ស្លាក បាត់លេខ ឬដាក់សម្ភារៈបាំងស្លាកលេខ ។

៥. ត្រូវពិន័យទឹកប្រាក់ចំនួន ១៥០០០០ រៀល ចំពោះអ្នកបើកបរដែលប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសាធារណៈសម្រាប់ធ្វើចរាចរណ៍។

៦. ត្រូវពិន័យទឹកប្រាក់ចំនួន ២៥០០០០ រៀល ចំពោះអ្នកបើកបរដែលស្ថិតក្នុងស្ថានភាពស្រវឹងដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ ទៅ០,៣៩ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥ ទៅ០,៧៩ ក្រាមក្នុងមួយលីត្រឈាម។

**ខ** ៖ ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តធុនស្រាល និងអ្នកបើកបរយានយន្តធុនធ្ងន់ដែលប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

១.ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៧៥០០០ រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ១៥០០០០ រៀល ចំពោះអំពើល្មើសដូចជា៖ បើកបរមិនយកភ្ជាប់តាមខ្លួននូវឯកសារដើម្បីមាន បណ្ណបើកបរយានយន្ត និងលិខិតអនុញ្ញាតធ្វើអាជីវកម្ម បើកបរដោយមិនពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ឈប់ ឬចតល្មើសនឹងមាត្រា៣២នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បើកបរដោយមិនដំណើការកុងទ័រល្បឿន បើកបរដឹកអ្នកដំណើរលើសចំណុះ អ្នកបើកបរយានយន្តធុនធ្ងន់យានយន្តបករណ៍យានយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉កបិទស្លាកសញ្ញាចាំងពន្លឺខុសបទដ្ឋាន ឬមិនមានបិទស្លាកសញ្ញាចាំងពន្លឺ។

២.ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១២០០០០ រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ២២៥០០០ រៀល ចំពោះអំពើល្មើសដូចជា៖ បើកបរប្រើទូរស័ព្ទគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង បើកបរប្រើសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់ បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស បើកបរដោយគ្មានផ្លិតទឹកជូតកញ្ចក់មុខ ឬផ្លិតទឹកជូតកញ្ចក់មុខមិនដំណើរការ ឬកញ្ចក់មុខ ឬកញ្ចក់ក្រោយយានប្រេះស្រាំដែលលំបាកមើលផ្លូវ ឬគ្មានកញ្ចក់មើលក្រោយ បើកបរមានប៊ូឡុងកង់ ឬអេគ្រូកង់មិនគ្រប់តាមចំនួនកំណត់នៃប្រភេទរថយន្តនីមួយៗ បើកបរលើសល្បឿនកំណត់ចាប់ពី១ ទៅ១៩គីឡូម៉ែត្រក្នុងមួយម៉ោង បើកបររថយន្តធ្វើអាជីវកម្មផ្ទាល់ខ្លួនដឹកអ្នកដំណើរ ឬដឹកទំនិញ គ្មានសញ្ញាសម្គាល់បញ្ជាក់អំពីទំហំ ទម្ងន់រថយន្ត ទម្ងន់ផ្ទុក ចំណុះផ្ទុក ចំនួនភ្លៅ បើកបរល្មើសនឹងបែបបទនៃការសណ្តោងយានដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់ចរាចរណ៍ផ្លូវគោក បើកបរដោយមិនបានប្រើសញ្ញាអាសន្ន ឬមិនបានដាក់សញ្ញាត្រីកោណជាដំណឹង ក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាន បើកបររថយន្តដឹកទំនិញមានគ្រោះថ្នាក់គ្មានសញ្ញាសម្គាល់ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

៣. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៥០០០០ រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៣០០០០០ រៀល ចំពោះអំពើល្មើសដូចជា៖ បើកបរបង្ហោះ ឆេចុះឆេឡើង ឆាប ឬគៀរ បើកបរបញ្ចេញសម្លេងខ្លាំង ឬផ្សែងច្រើនខុសពីបទដ្ឋានបច្ចេកទេស បើកបរយានយន្តផ្ទាល់ខ្លួនដោយគ្មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬប្រើលិខិតធ្វើអាជីវកម្មហួសសុពលភាព បើកបរមិនគោរពលក្ខខណ្ឌសុខភាព ដែលតម្រូវ

ឱ្យពាក់វ៉ែនតា បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្កួតកណ្ដាលទ្រូងផ្លូវ បើកបរលើសល្បឿនកំណត់ចាប់ពី២០ ទៅ២៩គីឡូម៉ែត្រក្នុងមួយម៉ោង បើកបរល្មើសនឹងការជៀស ការបត់ និងការវ៉ែង បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្តូរទិសនៃយានមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស បើកបរដោយគ្មាន ឬមិនដំណើការភ្លើងហ្វាកូត ភ្លើងសញ្ញាប្តូរទិស ភ្លើងហ្វ្រាំង ភ្លើងទីតាំងខាងមុខរថយន្ត និងភ្លើងក្រហមខាងក្រោយរថយន្ត បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែតៗ បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់ បើកបរប្រើប្រាស់សំបកកង់សឹកលើសកម្រិតកំណត់ ឬរហែក ឬប្រេះ ឬប៉ោង បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍ បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១,២,៣,៤ និងទី៥ មាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បើកបររថយន្តធុនធ្ងន់ដែលគ្មានរនាំងសុវត្ថិភាព ឬមានរនាំងសុវត្ថិភាពមិនត្រឹមត្រូវតាមតួរថយន្តខាងក្រោម ឬគ្មានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតេន័រ ឬមានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតេន័រមិនគ្រប់គ្រាន់ ឬគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតេន័រមិនដំណើរការ។

៤.ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៨០០០០ រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៣៧៥០០០ រៀល ចំពោះអំពើល្មើសដូចជា៖ បើកបរដោយគ្មានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយាន ឬប្រើវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសហួសសុពលភាព ប្តូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត ប្រើប្រាស់បណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន ប្រើប្រាស់បណ្ណបើកបរយានហួសសុពលភាព បើកបរយានដែលមានកង់ច្រវ៉ាក់ដែកផ្ទាល់នៅលើទ្រូងផ្លូវថ្នល់ក្រាលកៅស៊ូ ប្រើប្រាស់ផ្លាក់លេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាក បាត់លេខ ឬដាក់សម្ភារៈ ឬវត្ថុផ្សេងៗបាំងផ្លាកលេខ បើកបរល្មើសល្បឿនកំណត់ចាប់ពី ៣០ ទៅ៣៩ គីឡូម៉ែត្រក្នុងមួយម៉ោង។

៥. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៣០០០០០ រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៦២៥០០០ រៀល ចំពោះអំពើល្មើសដូចជា៖ បើកបរយានយន្តដែលកែច្នៃដំឡើងខុសបទដ្ឋានបច្ចេកទេស បើកបរប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍សាធារណៈ បើកបរលើសល្បឿនកំណត់ចាប់ពី៤០ គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅ ។

៦. ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរស្ថិតក្នុងស្ថានភាពស្រវឹងដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ ទៅ០,៣៩ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៥ ទៅ០,៧៩ ក្រាមក្នុងមួយលីត្រឈាមដូចតទៅ៖

ទឹកប្រាក់ចំនួន៤០០០០០ រៀល សម្រាប់យានយន្តធុនស្រាល, ទឹកប្រាក់ចំនួន៨០០០០០រៀល សម្រាប់យានយន្តធុនធ្ងន់។

**គ** ៖ ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈដូចតទៅ៖ ទឹកប្រាក់ចំនួន ១២០០០០០ រៀល សម្រាប់យានយន្តធុនស្រាល, ទឹកប្រាក់ចំនួន ២៤០០០០០ រៀល សម្រាប់យានយន្តធុនធ្ងន់។

**ឃ** ៖ ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណសម្គាល់យានជំនិះ ឬគ្មានផ្លាកលេខដូចតទៅ៖ ទឹកប្រាក់ចំនួន ១២០០០០០ រៀល សម្រាប់យានយន្តធុនស្រាល,ទឹកប្រាក់ចំនួន ២៤០០០០០ រៀល សម្រាប់យានយន្តធុនធ្ងន់។

**ង** ៖ ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តស្ថិតក្នុងស្ថានភាពស្រវឹង ដែលមានអត្រាជាតិអាល់កុលចាប់ពី ០,៤០ មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០ ក្រាមក្នុងមួយលីត្រឈាមឡើងទៅដូចជា៖

- ទឹកប្រាក់ចំនួន ១០០០ ០០០ រៀល សម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន
- ទឹកប្រាក់ចំនួន ២០០០ ០០០ រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៤០០០ ០០០ រៀល សម្រាប់យានយន្តធុនធ្ងន់

**ច** ៖ ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទដែលមិនបានបំពេញបែបបទចុះបញ្ជីយានយន្ត សុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឱ្យបានចប់សព្វគ្រប់មុនប្រគល់ឱ្យអ្នកទិញ ត្រូវទទួលរងពិន័យអន្តរការណ៍ដូចតទៅ៖

- ទឹកប្រាក់ចំនួន ១២០០០០ រៀល សម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន
- ទឹកប្រាក់ចំនួន ១២០០ ០០០ រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ២៤០០ ០០០ រៀល សម្រាប់យានយន្តធុនធ្ងន់

ត្រូវពិន័យអន្តរការណ៍ចំពោះនីតិបុគ្គលដែលមិនបានស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដូចតទៅ៖

- ទឹកប្រាក់ចំនួន ១៥០ ០០០ រៀលសម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៣០០ ០០០ រៀលសម្រាប់យានយន្តធុនធ្ងន់

## ២.៣. វិធានការអនុវត្តចំពោះបញ្ហាកកស្ទះចរាចរណ៍

### ២.៣.១. ការណែនាំ និងចាត់វិធានការចំពោះបញ្ហាសណ្តាប់ធ្នាប់តាមដងផ្លូវ

បញ្ហានៅក្នុងសង្គមមួយអាចនឹងត្រូវដោះស្រាយបាន អាស្រ័យដោយសារការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកដែលពាក់ព័ន្ធនានានៅក្នុងបញ្ហានោះ ហើយក្នុងករណីដែលភាគីទាំងឡាយមិនបានសហការណ៍ទេនោះ រដ្ឋនឹងចាត់វិធានការទៅតាមផ្លូវច្បាប់។ ចំពោះបញ្ហាដែលបងប្អូនអាជីវករជាច្រើនបានរំលោភលើចំណីផ្លូវ ដើម្បីដំណើរការមុខរបរជួញដូររបស់ខ្លួននោះ ប្រហែលជាដល់ពេលដែលអាជ្ញាធរត្រូវអនុវត្តវិធានការច្បាប់ ដាក់ទណ្ឌកម្មចំពោះអ្នកដែលល្មើសនោះហើយ។

ចំពោះដំណោះស្រាយបញ្ហាទាំងអស់នេះផងដែរ យោងតាមស្មារតីនៃកិច្ចប្រជុំគណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានីភ្នំពេញបានសម្រេចជ្រើសរើសយកផ្លូវសំខាន់ៗចំនួន១១ខ្សែ ធ្វើជាអាទិភាពគំរូសម្រាប់អនុវត្តវិធានការដោះស្រាយចរាចរណ៍ និងរៀបចំសណ្តាប់ធ្នាប់សាធារណៈ ហើយផ្លូវគំរូអាទិភាពទាំងនោះរួមមាន៖ មហាវិថីសហព័ន្ធរុស្ស៊ី មហាវិថីព្រះមុនីវង្ស មហាវិថីកម្ពុជាក្រោម មហាវិថីម៉ៅសេទុង មហាវិថីព្រះសីហនុ និងមហាវិថីនេរុហ៍ មហាវិថីព្រះនរោត្តម មហាវិថីសម្តេចមុនីរ៉េត ផ្លូវឧកញ៉ាទេពផន មហាវិថីហ្សាលដឺហ្គោល មហាវិថីយោធពលខេមរភូមិន្ទ(ផ្លូវ២៧១) និងផ្លូវឧកញ៉ាឃ្លាំងមឿង(ផ្លូវលេខ៧០) និងតីរវិថីព្រះស៊ីសុវត្ថិ។ ដើម្បីសម្រេចបានផែនការកាត់បន្ថយការកកស្ទះចរាចរណ៍នោះ រដ្ឋបាលរាជធានីភ្នំពេញបានដាក់ចេញសេចក្តីណែនាំដូចខាងក្រោម៖

**ក** .ចំពោះប្រជាពលរដ្ឋ ម្ចាស់លំនៅដ្ឋាន ម្ចាស់អាជីវកម្ម ម្ចាស់ការដ្ឋាន មន្ទីរពេទ្យ សាលារៀន វិស័យឯកជន អគារសាធារណៈ និងអ្នកប្រើប្រាស់ថ្នល់ត្រូវអនុវត្ត៖

- ហាមចតយានយន្តគ្រប់ប្រភេទលើទ្រូងផ្លូវ ហាមដាច់ខាតមិនឲ្យម្ចាស់ការដ្ឋានសំណង់គ្រប់ប្រភេទ ធ្វើការហ៊ុមព័ទ្ធការដ្ឋានលើចិញ្ចើមផ្លូវលើសពី១/៣(មួយភាគបី) និងប្រើប្រាស់ទ្រូងផ្លូវដើម្បីទុកដាក់សម្ភារសំណង់របស់ខ្លួនដូចជា ដែក ខ្សាច់ គ្រួស ថ្មជាដើម។[31]
- រថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង និងរថយន្តក្រឡុកស៊ីម៉ង់ត៍ត្រូវចេញចូលគោរពតាមការណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ និងចៀសវាងការប្រើប្រាស់ទ្រូងផ្លូវក្នុងការលើកដាក់ ផ្ទេរទំនិញ និងបាញ់បេតុង។ ក្នុងករណីចៀសមិនបាន ត្រូវអនុវត្តការលើកដាក់ទំនិញ និងការបាញ់បេតុងចាប់ពីម៉ោង ២១:០០ នាទី រហូតដល់ម៉ោង ០៦:០០ នាទីព្រឹក។

[31] ចំណុចទី២ នៃមាត្រា៣៨ នៃច្បាប់ស្តីពីផ្លូវថ្នល់

• ការរៀបចំសម្ភារៈ ទំនិញ ម៉ូតូ និងរថយន្តដាក់តាំងលក់អាចប្រើប្រាស់ចំណែកចិញ្ចើមផ្លូវត្រឹម១/៣(មួយភាគបី) ជាលក្ខណៈបណ្ដោះអាសន្នតែប៉ុណ្ណោះ ដោយទុក២/៣ (ពីរភាគបី) សម្រាប់ថ្មើរជើង និងបម្រើការងារសណ្ដាប់ធ្នាប់ និងចរាចរណ៍។

• រាល់ការប្រើប្រាស់ចិញ្ចើមផ្លូវជាទីតាំងផ្ញើកង់ ម៉ូតូមិនឲ្យលើសពី១/៣(មួយភាគបី)ឡើយ។

**ខ**. ចំពោះគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង ១៤ ត្រូវអនុវត្តដូចខាងក្រោម៖

• ត្រូវចុះធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋ ដែលបាននឹងកំពុងប្រើប្រាស់ទ្រូងផ្លូវ ចិញ្ចើមផ្លូវដោយរំលោភបំពានដោយប្រើប្រាស់វិធីសាស្ត្រទន់ភ្លន់តែម៉ឺងម៉ាត់ ឲ្យចូលរួមអនុវត្តតាមស្មារតីនៃសេចក្ដីណែនាំនេះ។ ក្នុងករណីនៅតែមិនអនុវត្តតាមការណែនាំនោះទេ មន្ត្រីអនុវត្តត្រូវធ្វើកំណត់ហេតុ និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

• ត្រូវណែនាំដល់ម្ចាស់ទីតាំងភោជនីយដ្ឋាន និងម្ចាស់ទីតាំងអាជីវកម្មនានាឲ្យគោរពតាមខ្លឹមសារនៃសេចក្ដីណែនាំនេះ ក្នុងករណីពុំព្រមអនុវត្តតាមអាជ្ញាធរខណ្ឌត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច និងជំនាញពាក់ព័ន្ធធ្វើការផាកពិន័យតាមច្បាប់ និងអាចឈានទៅដល់ការបិទទីតាំងអាជីវកម្ម។

• ត្រូវធ្វើការណែនាំ និងធ្វើកំណត់ហេតុឲ្យបានត្រឹមត្រូវជាមួយម្ចាស់ការដ្ឋានដែលរំលោភបំពានលើទ្រូងផ្លូវ ចិញ្ចើមផ្លូវ ក្នុងករណីមិនរាងចាលត្រូវផ្អាកការដ្ឋាននោះភ្លាម។

• ត្រូវចុះល្បាត និងឃ្លាំមើលជាប្រចាំចំពោះរថយន្តដឹកទំនិញធំៗ រថយន្តកុងតឺន័រ រថយន្តបាញ់បេតុង រថយន្តក្រឡុកស៊ីម៉ងត៍ និងត្រូវមានវិធានការឲ្យបានម៉ឺងម៉ាត់ក្នុងករណីការចេញចូលរាជធានីភ្នំពេញខុសពីសេចក្ដីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ។

• ត្រូវអនុវត្តតាមការណែនាំខាងលើនេះឲ្យបានត្រឹមត្រូវ ហ្មត់ចត់ ទន់ភ្លន់ និងត្រូវរាយការណ៍ប្រចាំសប្ដាហ៍អំពីលទ្ធផលនៃការងារនេះមកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីភ្នំពេញឲ្យបានទៀងទាត់ និងទាន់ពេលវេលា។

**គ** . ស្នងការដ្ឋាននគរបាល និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញត្រូវ៖

• បន្ថែមកម្លាំងនគរបាលចរាចរណ៍ដោះស្រាយចរាចរណ៍តាមគោលដៅដែលមានការកកស្ទះនៅចន្លោះម៉ោងមមាញឹក គឺម៉ោង ០៧:៣០ នាទី ដល់ម៉ោង ០៨ : ៣០ នាទី ម៉ោង ១១ : ៣០ នាទី ដល់ម៉ោង ១២ :៣០ នាទី និងម៉ោង១៧ : ០០ ដល់ម៉ោង ១៨ : ៣០ នាទី។

• រៀបចំរថយន្តស្ទូច ក្នុងគោលបំណងសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌទាំង១២ ដើម្បីអនុវត្តវិធានការច្បាប់។

### ២.៣.២. ការប្រើប្រាស់កម្លាំងជាក់ស្តែង

បច្ចុប្បន្ននេះ ស្នងការដ្ឋាននគរបាលរាជធានីបាននឹងកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំសម្រួលចរាចរណ៍នៅតាមគោលដៅនីមួយៗក្នុងរាជធានីភ្នំពេញ ក្នុងគោលបំណងធានាទាំងការបម្រើសុវត្ថិភាពជូនប្រជាពលរដ្ឋ និងការរៀបចំសណ្តាប់ធ្នាប់។ ចំពោះបញ្ហារៀបចំសណ្តាប់ធ្នាប់ និងដោះស្រាយបញ្ហាកកស្ទះចរាចរណ៍នេះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានប្រើប្រាស់កម្លាំងសរុបចំនួន ១.០៩១នាក់/១៨៥គោលដៅ (ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក៥៩០/៧០គោលដៅ) ការិយាល័យនគរបាលសណ្តាប់ធ្នាប់ចំនួន៤២នាក់/០៦គោលដៅ អង្គភាពអន្តរាគមន៍ពិសេសចំនួន៦០នាក់ តាមបណ្តាខណ្ឌទាំង១២ចំនួន ៣៩៩នាក់/១០៩គោលដៅ ក្នុងនោះរួមមាន៖

- ការិយាល័យន.បចរាចរណ៍ផ្លូវគោក ៤៩៦នាក់/៦២គោលដៅ (បញ្ជាការ១៦នាក់)
- អធិការដ្ឋានន.បខណ្ឌដូនពេញ ២៥នាក់/០៨គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌ៧មករា ៥៨នាក់/២២គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌចំការមន ៦៣នាក់/១៥គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌទួលគោក ៦៣នាក់/២០គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌឫស្សីកែវ ១៩នាក់/០៧គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌជ្រោយចង្វារ ១៥នាក់/០៣គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌព្រែកព្នៅ ១៤នាក់/០២គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌសែនសុខ ៣០នាក់/១០គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌពោធិ៍សែនជ័យ ៣៣នាក់/០៦គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌដង្កោ ២៧នាក់/០៦គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌមានជ័យ ២៦នាក់/០៥គោលដៅ (បញ្ជាការ០៣នាក់)
- អធិការដ្ឋានន.បខណ្ឌច្បារអំពៅ ២៦នាក់/០៥គោលដៅ (បញ្ជាការ០៣នាក់)

នៅក្នុងចំណោមចំណុចកកស្ទះទាំង២០ផ្សារ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានប្រើប្រាស់កម្លាំងការិយាល័យនគរបាលសណ្តាប់ធ្នាប់ចំនួន ២៩នាក់/០៤ផ្សា(ផ្សារធំថ្មី ផ្សារអូឬស្សី ផ្សារអូឡាំពិក ផ្សារដើមគរ) និងចំនួន១៦ផ្សារផ្សេងទៀតប្រើប្រាស់កម្លាំងរដ្ឋបាលខណ្ឌ។

ចំពោះល្បាតចល័តរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានប្រើប្រាស់កម្លាំង ២៧នាក់(បញ្ជាការ៣នាក់) /០៩គោលដៅសំខាន់ ឲ្យធ្វើការល្បាតចល័តរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈនៅតាមមហាវិថីសំខាន់ៗ និងចំណុចស្មុគស្មាញ

កកស្ទះចរាចរណ៍(ការិយាល័យនគរបាលចរាចរណ៍ផ្លូវគោក កម្លាំង១៤នាក់/រថយន្តស្ទូច ០៧គ្រឿង/០៧គោលដៅ ការិយាល័យនគរបាលសណ្តាប់ធ្នាប់ កម្លាំង១៣នាក់/ រថយន្តស្ទូច ០២គ្រឿង/ ០២គោលដៅ)។

ចំពោះកម្លាំងអន្តរាគមន៍វិញនោះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ប្រើប្រាស់កម្លាំងចំនួន ១៤០នាក់ (រថយន្ត១០ គ្រឿង) ក្នុងនោះមានកងអន្តរាគមន៍នការិយាល័យកណ្តាលសណ្តាប់ធ្នាប់ចំនួន៨០នាក់(ចែកចេញជា៣ខ និង៣ក្រុម) និងអង្គភាពអន្តរាគមន៍ពិសេសចំនួន៦០នាក់។ កម្លាំងអន្តរាគមន៍ទាំងពីរក្រុមនេះ ត្រូវទទួលភារកិច្ចត្រៀមអន្តរាគមន៍នៅកន្លែងដែលមានការកកស្ទះចរាចរណ៍ធ្ងន់ធ្ងរ ឬពេលមានព្រឹត្តិការណ៍ការពារសំខាន់ៗ។ [32]

### ២.៣.៣. អំពីភារកិច្ចរបស់នគរបាលចរាចរណ៍

ដើម្បីធានាការដោះស្រាយបញ្ហាចរាចរណ៍ក្នុងរាជធានីភ្នំពេញ មន្ត្រីនគរបាលចរាចរណ៍ដែលស្ថិតនៅតាមគោលដៅនីមួយៗ ចាំបាច់ត្រូវមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តភារកិច្ចរបស់មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក(ជំពូកទី០៩ មាត្រា៦០ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក)។
- ក្តាប់សភាពការណ៍ និងព្យាករណ៍រាល់ការកកស្ទះ ដោយធ្វើការសិក្សាលក្ខណៈភូមិសាស្ត្រជាក់ស្តែងនូវចំណុចកកស្ទះ រៀបចំដំឡើងផែនទី និងការប្រើប្រាស់កម្លាំងជំនាញអនុវត្តឲ្យបានសមស្របទាន់ពេលវេលា(មិនទុកឱ្យមានការកកស្ទះណែនណាប់ ទើបធ្វើការដោះស្រាយជាក្រោយ)។
- រៀបចំសណ្តាប់ធ្នាប់សាធារណៈលើទ្រូងផ្លូវ-ចិញ្ចើមផ្លូវ ជុំវិញទីផ្សារធំៗ (ការតាំងលក់ដូរ ធ្វើអាជីវកម្ម ការឈប់-ចតយានយន្ត ចំណតគ្មានសណ្តាប់ធ្នាប់លើផ្លូវ) ចំណតរថយន្តឈ្នួល-តាក់ស៊ី អាជីវកម្មដ្ឋាន (ភោជនីយដ្ឋាន សណ្ឋាគារ រង្គសាល...) ក្រសួង មន្ទីរ ក្រុមហ៊ុន គ្រឹះស្ថានសិក្សានានា ដោយសហការជាមួយស្ថាប័ន អាជ្ញាធរដែនដី និងកម្លាំងពាក់ព័ន្ធ។
- បំប៉នសមត្ថភាពជំនាញ និងច្បាប់ដល់មន្ត្រីនគរបាលអនុវត្តផ្ទាល់ ហ្វឹកហាត់រហ័សរហួន គោរពបានវិន័យអាកប្បកិរិយា សីលធម៌ស្មោះត្រង់ ទន់ភ្លន់ ម៉ឺងម៉ាត់ ស្មារតីទទួលខុសត្រូវ។
- កសាងផែនការជាក់ស្តែងតាមការិយាល័យជំនាញ និងអធិការដ្ឋាននគរបាលខណ្ឌនីមួយៗ (មានផែនទីភូមិសាស្ត្រ) និងផ្សព្វផ្សាយដល់កងកម្លាំងអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់។

---

32 របាយការណ៍ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ស្តីពីការបូកសរុប សភាពការណ៍ កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២. លេខ៣៤១ រ.ប.ក. ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧

• អនុវត្តផែនការលេខ ០០២ ផ.ក ចុះថ្ងៃ០១ មករា ឆ្នាំ២០១៦ របស់ស្នងការដ្ឋានរាជធានីភ្នំពេញ ស្តីពីការរក្សាសណ្តាប់ធ្នាប់នៃការធ្វើចរាចរណ៍រថយន្តដឹកជញ្ជូនគ្រប់ប្រភេទចេញ-ចូលរាជធានី ភ្នំពេញ។

• ធ្វើរបាយការណ៍បូកសរុបជាប្រចាំថ្ងៃ-សប្តាហ៍ និងខែ ផ្ញើមកស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដើម្បីបូកសរុបដកពិសោធន៍រាយការណ៍ ជូនរដ្ឋបាលរាជធានីភ្នំពេញ និងអគ្គស្នងការដ្ឋាននគរបាលជាតិ។

គួបញ្ជាក់ផងដែរថា នៅប្រតិបត្តិការនីមួយៗ អគ្គស្នងការនគរបាលរាជធានីភ្នំពេញបាននឹងកំពុងប្រើប្រាស់មធ្យោបាយប្រតិបត្តិការជារួមមាន រថយន្តចំនួន៣៧គ្រឿង (រថយន្តស្ទូចចំនួន០៩គ្រឿង រថយន្តដឹកកងកម្លាំងចំនួនគ្រឿង) និងម៉ូតូធំចំនួន១៩០គ្រឿង។

បន្ទាប់ពីបញ្ហាចរាចរណ៍បានកើតឡើងនិងការតែរីករាលដាលបង្កជាការលំបាកយ៉ាងខ្លាំងនោះ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានដាក់វិធានការជាបន្តបន្ទាប់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាពដូចខាងក្រោម៖

• បង្កើនជំរុញការផ្សព្វផ្សាយ អប់រំ ណែនាំអំពីច្បាប់ចរាចរណ៍ផ្លូវគោកឲ្យបានទូលំទូលាយពីរាជធានីដល់ខណ្ឌ សង្កាត់ ភូមិ សហគមន៍ តាមគ្រប់រូបភាពនិងគ្រប់ប្រព័ន្ធផ្សព្វផ្សាយ(វិទ្យុ ទូរទស្សន៍សារព័ត៌មាន ទស្សនាវដ្តី បណ្តាញទំនាក់ទំនងសង្គម...)។

• បន្តនិរន្តភាពនៃការអនុវត្តច្បាប់ ដោយបង្កើនក្រុមត្រួតពិនិត្យ និងយកចិត្តទុកដាក់លើបទល្មើសចរាចរណ៍អំពីការបើកបរលើសល្បឿនកំណត់ បើកបរក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ការត្រួតពិនិត្យលិខិតស្នាមយានយន្ត និងអ្នកបើកបរ។ល។ ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ០០៩សណន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ របស់ស្នងការដ្ឋាននគរបាលជាតិ ស្តីពីការបន្តត្រួតពិនិត្យរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងផែនការសកម្មភាពស្តីពីការត្រួតពិនិត្យរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកនៅរាជធានីភ្នំពេញ របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ(ផែនការលេខ០៩៩ ផក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦)។ អនុវត្តតាមប្រសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តនាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ នាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ និងស្មារតីអង្គប្រជុំនៅអគ្គស្នងការដ្ឋាននគរបាលជាតិនាថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលវិធានការរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានរៀបចំផែនការស្តីពីការកែសម្រួលគោលដៅត្រួតពិនិត្យរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក នៅរាជធានីភ្នំពេញ។

• បង្កើនប្រសិទ្ធិភាពក្រុមការងារចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តតាមគោលដៅក្នុងរាជធានីភ្នំពេញ (តាមលិខិតបង្គាប់ការលេខ០០១/១៧ លបក.រ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧ របស់រដ្ឋបាលរាជធានីភ្នំពេញ)។

- បូកសរុបស្រង់ស្ថិតិអ្នកបើកបរ និងម្ចាស់យានយន្តមិនព្រមចូលខ្លួនបង់ផាកពិន័យត្រៀមលក្ខណៈកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ(ករណីមិនចូលខ្លួនមកបង់ផាកពិន័យលើសពី៩០ថ្ងៃ) និងចេញលិខិតអញ្ជើញក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋឱ្យចូលមកបង់ប្រាក់ផាកពិន័យ។

- ពង្រឹងប្រសិទ្ធិភាពការអនុវត្តសេចក្តីណែនាំលេខ១៩ សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ របស់សាលារាជធានីភ្នំពេញស្តីពីសណ្តាប់ធ្នាប់នៃការធ្វើចរាចរណ៍រថយន្តដឹកជញ្ជូនគ្រប់ប្រភេទ ចេញ-ចូលរាជធានីភ្នំពេញ (ដោះស្រាយបញ្ហាកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ដែលបង្កដោយរថយន្តដឹកជញ្ជូនគ្រប់ប្រភេទក្នុងទីប្រជុំជន)។

- ជំរុញការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងសណ្តាប់ធ្នាប់សាធារណៈ បើកទូលាយចរាចរណ៍លើទ្រូងផ្លូវ និងចិញ្ចើមផ្លូវ តាមដងមហាវិថីសំខាន់ៗ ទប់ស្កាត់លុបបំបាត់ការរំលោភលើទ្រូងផ្លូវ និងចិញ្ចើមផ្លូវ ដើម្បីផលប្រយោជន៍ផ្ទាល់ (តាំងលក់ ធ្វើអាជីវកម្ម ការដ្ឋានសំណង់ផ្សេងៗ ជាចំណតយានយន្ត ផ្ញើយានយន្ត សង់រោងបុណ្យ ពិធីមង្គលការ)។ល។ បង្កភាពបាត់សណ្តាប់ធ្នាប់ កកស្ទះចរាចរណ៍ និងបាត់ចំណែកផ្លូវសម្រាប់អ្នកថ្មើរជើងធ្វើដំណើរ។

- បំប៉នបន្ថែមសមត្ថភាពច្បាប់ និងជំនាញដល់កងកម្លាំងអនុវត្តច្បាប់នូវវិន័យ សីលធម៌ ភាពស្អាតស្អំស្មោះត្រង់ ទទួលខុសត្រូវចំពោះតួនាទី ភារកិច្ចសម្រេចបានល្អរាល់ភារកិច្ច។ ផ្សព្វផ្សាយ និងអនុវត្តឲ្យមានប្រសិទ្ធិភាពសេចក្តីណែនាំស្តីពីការពង្រឹងសីលធម៌ វិន័យ និងរបៀបរបបការងាររបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក និងមន្ត្រីនគរបាលសណ្តាប់ធ្នាប់។

### ២.៣.៤. បញ្ហាប្រឈមមួយចំនួនរបស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

យោងតាមឯកសារជំនួយស្មារតីដែលរៀបចំឡើងដោយស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញក្នុងកិច្ចពិភាក្សាតុមូលស្តីពី ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍នៅកម្ពុជា និងការទទួលខុសត្រូវរបស់អ្នកបើកបរ និងការអនុវត្តច្បាប់នៅរាជបណ្ឌិត្យសភាកម្ពុជា នាថ្ងៃ២៤ ខែមីនា ឆ្នាំ២០១៨ ក៏បានលើកឡើងផងដែរអំពីបញ្ហាប្រឈមមួយចំនួនចំពោះការចេញប្រតិបត្តិការរបស់ខ្លួនកន្លងមកដូចជា៖

- ការធ្វើវិស្វកម្មផ្លូវថ្នល់នៅមិនទាន់បានឆ្លើយតបទៅនឹងការរីកចម្រើនឥតឈប់ឈរនៃវិស័យសណ្តាប់ធ្នាប់ចរាចរណ៍ (ការថែទាំ កែលម្អផ្លូវថ្នល់ កសាងស្ពាន ស្ពានអាកាស ផ្លូវរថភ្លើងលើអាកាស ផ្លូវរូងក្រោមដី ការដាក់របាំងបែងចែកទ្រូងផ្លូវ គំនូសសញ្ញាចរាចរណ៍ ការកំណត់ទិសចរាចរណ៍ ការបំពាក់ប្រព័ន្ធចរាចរណ៍ កាមេរ៉ាត្រួតពិនិត្យ ប្រព័ន្ធលូរទឹក ភ្លើងបំភ្លឺពេលយប់ជាដើម...)។

- ការអប់រំផ្សព្វផ្សាយច្បាប់មិនទាន់បានទូលំទូលាយគ្រប់ប្រព័ន្ធផ្សព្វផ្សាយគ្រប់ទីកន្លែង និងកែប្រែឥរិយាបថខ្លាចនគរបាល មកគោរពច្បាប់ចរាចរណ៍ផ្លូវគោកវិញ។

• ការរឹតបន្តឹងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកមិនបានអនុវត្តជាប្រចាំ គ្រប់ទីកន្លែង (ជាប់ភារកិច្ចច្រើន សភាពការណ៍នយោបាយ) មិនបានត្រួតពិនិត្យនៅចំណុចដើមទី អនុវត្តមិនអស់លទ្ធភាពនៃប្រសិទ្ធភាពច្បាប់ និងខ្វះកម្លាំងសម្រាប់ពង្រាយឲ្យបានគ្រប់ចំណុចកកស្ទះ ស្មារតីគោរពអនុវត្តច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិត ការងារត្រួតពិនិត្យរថយន្តកែច្នៃខុស លក្ខណៈបច្ចេកទេស មន្ត្រីជំនាញមិនមានសម្ភារៈគ្រប់គ្រាន់សម្រាប់ធ្វើការកែសម្រួល កាត់ទ្រុងតាមលក្ខណៈបច្ចេកទេសស្តង់ដារកំណត់។

• វត្តមានរថយន្តដឹកជញ្ជូនទំនិញគ្រប់ប្រភេទ (រថយន្តធុនធ្ងន់) ធ្វើចរាចរណ៍ចេញ ចូល ឆ្លងកាត់ភូមិសាស្ត្ររាជធានីភ្នំពេញ ល្មើសនឹងសេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ ដោយបើកបរគ្មានបណ្ណអនុញ្ញាត បើកបរខុសតម្រាយផ្លូវ និងពេលវេលាកំណត់។

• វត្តមានបណ្តាឃ្លាំង រោងចក្រ សហគ្រាស ក្រុមហ៊ុនដឹកជញ្ជូន មានទីតាំងនៅក្នុងរាជធានីភ្នំពេញ (តម្រូវការក្នុងការអភិវឌ្ឍរាជធានីភ្នំពេញ និងការសាងសង់អគារ លំនៅឋានជាដើម)។

• កង្វះការសហការចូលរួមពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលមានកាតព្វកិច្ចចូលរួមដោះស្រាយសណ្តាប់ធ្នាប់ចរាចរណ៍ឲ្យបានម៉ឺងម៉ាត់។ ការផ្តន្ទាទោសចំពោះជនប្រព្រឹត្តបទល្មើសនៅមានភាពធូររលុង បណ្តោះឲ្យជនល្មើសរួចពីសំណាញ់ច្បាប់។

• សេវាដឹកជញ្ជូនអ្នកដំណើរនៅក្នុងរដ្ឋបាលរាជធានីភ្នំពេញ មិនទាន់មានលក្ខណៈគ្រប់គ្រាន់ ដើម្បីកាត់បន្ថយមធ្យោបាយផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋ ម៉្យាងទៀតប្រជាពលរដ្ឋមិនទាន់មានទម្លាប់ និងចំណូលចិត្តច្រើនអំពីការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសាធារណៈ។

• ការរៀបចំសណ្តាប់ធ្នាប់អ្នកលក់ដូរតាមទ្រូងនិងចិញ្ចើមផ្លូវនៅមានលក្ខណៈដូចវែកចក។

• ទ្រូងផ្លូវមួយចំនួនត្រូវបានរំលោភ តាំងការលក់ដូរ ធ្វើអាជីវកម្ម គ្មានចំណតយានយន្ត ដាក់វត្ថុធាតុដើមរបស់ការដ្ឋាន អាគារ លំនៅដ្ឋាន លើទ្រូង-ចិញ្ចើមផ្លូវ។ល។

• ស្មារតីទទួលខុសត្រូវរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិតនៅឡើយ អសកម្ម អនុវត្តលើសពីបទបញ្ជា បង្កភាពស្មុគស្មាញ គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន និងភាពថ្នាំងថ្នាក់របស់ប្រជាពលរដ្ឋចំពោះកងកម្លាំង។

### ២.៣.៥. ការហាមឃាត់ចំពោះរថយន្តធុនធ្ងន់ចេញ-ចូលរាជធានីភ្នំពេញពេលថ្ងៃ

ដោយសាររាជធានីភ្នំពេញជាតំបន់សេដ្ឋកិច្ច ហើយជាចំណុចស្នូលនៃប្រទេសកម្ពុជា ហើយក៏ជាតំបន់ប្រជុំជនដែលមានមនុស្សរស់នៅច្រើនជាងគេ បើប្រៀបធៀបនឹងបណ្តាខេត្តនានានៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះហើយទើបធ្វើអោយមានចរន្តចេញចូលនៃទំនិញ និងរបស់របរផ្សេងៗចេញពីភ្នំពេញទៅបណ្តាខេត្តនានា និងដឹកចូលពីបណ្តាខេត្តនានាចូលមកក្នុងរាជធានីភ្នំពេញវិញតាម មធ្យោបាយដឹកជញ្ជូននានាមានដូចជាតាមមធ្យោបាយផ្លូវទឹក ផ្លូវអាកាស និងផ្លូវថ្នល់។ ហើយចំពោះចរន្តដឹកទំនិញចេញចូលនៅក្នុងរាជធានីភ្នំពេញ

ដែលធ្វើអោយមានការកកស្ទះចរាចរណ៍ខ្លាំងជាងគេ គឺ ផ្លូវគោកដែលមានផ្លូវថ្នល់និងផ្លូវដែក ប៉ុន្តែចំពោះមធ្យោបាយធ្វើដំណើរតាមផ្លូវដែកមិនមានបង្ករជាបញ្ហាក្នុងការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញនោះទេ ការដឹកទំនិញផ្សេងៗតាមផ្លូវគោគទើបជាចំណុចដែលចោទជាបញ្ហា។ ដោយសារការចេញចូលក្នុងរាជធានីភ្នំពេញរបស់យានយន្តដឹកទំនិញធំៗបានបង្ករជាបញ្ហាកកស្ទះចរាចរណ៍ទើបលោក ឃួង ស្រេង ជាអភិបាលរាជធានីភ្នំពេញបានដាក់ចេញនូវវិធានការហាមឃាត់រថយន្តធំៗ ចេញ ចូលរាជធានីភ្នំពេញនៅពេលថ្ងៃដាច់ខាត រួមនឹងការលុបបំបាត់មិនឱ្យមានប័ណ្ណអនុញ្ញាតិចេញចូលរាជធានីភ្នំពេញប្រភេទA B និងC។ ដោយសាររថយន្តចេញចូលរាជធានីភ្នំពេញបានតាមចិត្តឱ្យតែមានប័ណ្ណអនុញ្ញាតចេញចូលក្រុងប្រភេទA B និងC បង្ករឱ្យមានគ្រោះថ្នាក់ និងកកស្ទះចរាចរនៅក្នុងរាជធានីភ្នំពេញយ៉ាងខ្លាំង។ ប័ណ្ណអនុញ្ញាតចេញ ចូលក្រុងប្រភេទA B និងC គេអាចថតចម្លងបានយ៉ាងស្រួល ហើយមិនមានស្ថាប័នណាមួយមកត្រួតពិនិត្យបានយ៉ាងត្រឹមត្រូវនោះទេ នេះហើយដែលជាមូលហេតុធ្វើអោយមានឡានធំៗ ចេញចូលរាជធានីភ្នំពេញនៅពេលថ្ងៃបាន ដូច្នេះចាប់ពីពេលនេះតទៅឡានធំ ចេញ ចូលរាជធានីភ្នំពេញពេលថ្ងៃ មិនអនុញ្ញាតិឱ្យមានដាច់ខាត តែអាចចេញចូលក្រុងបានចាប់ពីម៉ោង ៨ ទៅ៩យប់។[33]

[33] ផែនការលេខ ០០២ ផ.ក ចុះថ្ងៃ០១ មករា ឆ្នាំ២០១៦ របស់ស្នងការដ្ឋានរាជធានីភ្នំពេញ ស្តីពីការរក្សាសណ្តាប់ធ្នាប់នៃការធ្វើចរាចរណ៍រថយន្តដឹកជញ្ជូនគ្រប់ប្រភេទចេញ-ចូលរាជធានី ភ្នំពេញ

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បញ្ហាចរាចរណ៍ គឺជាបញ្ហាដ៏ចម្បងមួយដែលបាននឹងកំពុងតែកើតមានជារៀងរាល់ថ្ងៃ ហើយបានជះឥទ្ធិពលអវិជ្ជមានដល់សង្គមជាតិកម្ពុជាជាច្រើន ពោល គឺវាបានធ្វើឲ្យប៉ះពាល់ស្ទើរគ្រប់វិស័យដែលជាបញ្ហាដ៏ចម្បងនាំឲ្យប៉ះពាល់ទៅដល់សេដ្ឋកិច្ចជាតិទាំងមូល ដែលរាជរដ្ឋាភិបាលបានដាក់ជាបញ្ហាអាទិភាពមួយក្នុងការដោះស្រាយ ដែលទន្ទឹមនឹងការដោះស្រាយនោះ ដើម្បីកាត់បន្ថយបញ្ហានេះទៀតសោតលុះត្រាតែមានការចូលរួមសាមគ្គី និងសហការគ្នាពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចក៏ដូចជាស្ថាប័នពាក់ព័ន្ធ ក៏ដូចជាប្រជាពលរដ្ឋដែលជាអ្នកអនុវត្ត និងប្រតិបត្តិតាម។ បញ្ហាចរាចរណ៍បានបង្កនូវផលអវិជ្ជមានជាច្រើន ដូចជាខាតបង់ពេលវេលា ថវិកា និងបញ្ហាសតិអារម្មណ៍ជាដើម។ ជាពិសេសជាងនេះមុននឹងស្វែងយល់ឲ្យបានស៊ីជម្រៅអំពីបញ្ហានៃការកកស្ទះចរាចរណ៍នេះយើងត្រូវសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅទៅនឹងប្រភពដើមចង ក៏ដូចជាកត្តាសំខាន់ៗដែលរួមផ្សំគ្នា ដែលនាំឲ្យមានការកកស្ទះចរាចរណ៍នេះ ពោល គឺក្រោយពីបានឆ្លងកាត់នូវការសិក្សាក៏ដូចជាវិភាគយ៉ាងស៊ីជម្រៅអំពីខ្លឹមសារនៃសារណានេះហើយខ្ញុំបាទទាំងពីរនាក់ជឿជាក់យ៉ាងមុតមាំថា លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ បងប្អូននិស្សិតបញ្ញាវ័ន្ត រួមទាំងមិត្តអ្នកអានទាំងអស់ប្រាកដជាជ្រួលជ្រៀបយ៉ាងច្បាស់អំពីដើមចងដែលជាមូលហេតុនាំឲ្យមានបញ្ហានៃការកកស្ទះចរាចរណ៍នៅក្នុងរាជធានីភ្នំពេញដូចដែលខ្ញុំបាទទាំងពីរនាក់បានបង្ហាញក្នុងជំពូកទីមួយ រួមទាំងដំណោះស្រាយដែលបានបង្ហាញនៅក្នុងជំពូកទីពីរ។ ដូច្នេះហើយក្នុងការសិក្សាស្វែងយល់ក៏ដូចជាវិភាគអំពីបញ្ហាអ្វីមួយវារមែងតែងតែកើតនូវផលវិជ្ជមាន ពោល គឺដំណោះស្រាយ ដូច្នេះហើយខ្ញុំបាទទាំងពីរនាក់នូវតែមានជំនឿយ៉ាងមុតមាំថា បងប្អូនប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសនឹងរួបរួមសាមគ្គីគ្នាសហការជាមួយអជ្ញាធររួមទាំងស្ថាប័នមានសមត្ថកិច្ចបានយ៉ាងល្អហ្មត់ហ្មងដើម្បីដោះស្រាយក៏ដូចជាកាត់បន្ថយនៅបញ្ហាចរាចរណ៍ ដើម្បីបញ្ចៀសនូវរាល់ផលអវិជ្ជមានទាំងអស់ដែលប៉ះពាល់សេដ្ឋកិច្ចជាតិ ដើម្បីសង្គមជាតិកម្ពុជាទាំងមូលរីកចម្រើនទៅមុខតរៀងទៅ។

# អនុសាសន៍

# អនុសាសន៍

ដោយឆ្លងកាត់តាមការបកស្រាយអំពីប្រធានបទនៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់ខ្ញុំបាទទាំងពីរនាក់នេះ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ បងប្អូនជានិស្សិតបញ្ញវ័ន្តរួមទាំង មិត្តអ្នកអាន ទាំងឡាយប្រាកដជាបានជ្រួលជ្រាបយ៉ាងច្បាស់អំពីស្ថានភាពចរាចរណ៍ក៏ដូចជាផលអវិជ្ជមានដែលបង្ករពីការកកស្ទះចរាចរណ៍ជាពិសេសជាងនេះទៅទៀតគឺដំណោះស្រាយដើម្បីឆ្លើយតប។ បើទោះបីជាខ្ញុំបាទទាំងពីរនាក់បានបង្ហាញយ៉ាងស៊ីជម្រៅនៅក្នុងខ្លឹមសាររួចមកហើយក្តី ក៏ខ្ញុំបាទទាំងពីរនាក់សូមលើកឡើងនូវមតិយោបល់ ពោល គឺអនុសាសន៍មួយចំនួនដើម្បីជាការរួមចំណែកមួយក្នុងការដោះស្រាយបញ្ហានេះក្នុងនាមជាអ្នកស្រាវជ្រាវនៃប្រធានបទមួយនេះ ដែលមតិយោបល់នោះមានខ្លឹមសារដូចតទៅ ៖

- អាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចគួរតែចេញនូវវិធានការអប់រំ ផ្សព្វផ្សាយ ឲ្យបានទូលំទូលាយទៅដល់ប្រជាពលរដ្ឋដោយប្រើគ្រប់មធ្យោបាយ
- អាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ចគួរដែលចេញនូវផែនការ ឬយុត្តិសាស្ត្រមួយដែលមានភាពជាក់លាក់ដែលប្រាកដថាពេលដាក់អនុវត្តទៅមានប្រសិទ្ធភាពខ្ពស់
- អាជ្ញាធរឬស្ថាប័ន្តមានសមត្ថិកិច្ចដែលធ្វើការពាក់ព័ន្ធគួរតែសហការជាមួយពលរដ្ឋឲ្យបានស៊ីជម្រៅក្នុងការចុះអនុវត្តច្បាប់
- អាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកអនុវត្តច្បាប់គួរតែអនុវត្តច្បាប់ប្រកបដោយសុក្រឹត្វភាពឥតលម្អៀង
- អាជ្ញាធរមានសមត្ថកិច្ចគួរតែលើកទឹកចិត្តឲ្យមាននូវការលើកឡើងនូវមតិយោបលជាសាធារណោះពាក់ព័ន្ធទៅនឹងបញ្ហាចរាចរណ៍នេះ ដើម្បីជាការវិភាគមួយក្នុងការស្វែងយល់ពីចន្លោះប្រហោង ចំណុចខ្វះខាតដើម្បីបំពេញបន្ថែម ឬកែលម្អរ ដើម្បីប្រសិទ្ធភាពនិងនិរន្តន៍ភាព
- ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសក៏ដូចជាអ្នកប្រតិបត្តិ គួរតែសហការឲ្យបានស៊ីជម្រៅជាមួយស្ថាប័នក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទៅនឹងបញ្ហាចរាចរណ៍។

# ឯកសារយោង

# ឯកសារយោង


## ច្បាប់

- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, លេខនស/រកម/០១១៥/០០១, ០៦ មករា ២០១៧។
- ច្បាប់ស្តីពីផ្លូវថ្នល់, លេខនស/រកម/០៥១៤/០០៨, ០៤ ឧសភា ២០១៤។

## អនុក្រឹត្យ

- អនុក្រឹត្យលេខ៣៩ ស្តីពីការកែសម្រួលលេខ៤៤ អនក្រ.បក, ២១ មីនា ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

## ផែនការ/សេចក្តីណែនាំ

- ផែនការសកម្មភាពលេខ១១៤ ផ.ក, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍ និងកាត់បន្ថយភាពកកស្ទះចរាចរ ណ៍ក្នុងរាជធានីភ្នំពេញ។
- សេចក្តីណែនាំលេខ០០៧/១៧ សណន.ច ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដោះស្រាយចរាចរណ៍ និងរៀបចំ សណ្តាប់ធ្នាប់តាមដងផ្លូវនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។

## សៀវភៅ

- បណ្ឌិត អ៊ុន សក្កដា. ២០១៨. នីតិនគរូបនីយវិទ្យារបស់បណ្ឌិត។
- សៀវភៅគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោករបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៤

## របាយការណ៍

- រដ្ឋបាលរាជធានីភ្នំពេញ. ២០១៩. របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ. លេខ០២០/១៨របក.រប.គ្រ. សាលារាជធានីភ្នំពេញ។
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ. ២០១៧. របាយការណ៍ស្តីពីការបូកសរុប សភាពការណ៍ កិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ឆ្នាំ២០១៧. លេខ៣៤១ រ.ប.ក. ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ០៤. កក្កដា។
- របាយការណ៍របស់ធនាគាពិភពលោក ចុះផ្សាយថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩
- របាយការណ៍របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញឆ្នាំ២០១៦
- ជំរឿនទូទៅប្រជាជននៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិរបស់ក្រសួងសាធារណៈការ។

## គេហទំព័រ

- www.mpwt.gov.kh
- www.phnompenh.gov.kh
- www.angkorpost.net
- https://opendevelopmentcambodia.net/
- http://www.saferoads.org.kh/
- http://www.cambodiascouts.org.kh/

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ


១. ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ ផែនទីរាជធានីភ្នំពេញ

ឧបសម្ព័ន្ធទី២៖ ស្ពានអាកាស និងស្ពានអាកាសថ្មើរជើង

ឧបសម្ព័ន្ធទី៣៖ ចំណតរថយន្ត

២.ឧបសម្ព័ន្ធគតិយុត្តិ

ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

ឧបសម្ព័ន្ធទី២៖ អនុក្រឹត្យលេខ៣៩ ស្តីពីការកែសម្រួលលេខ៤៤ អនក្រ.បក, ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖ ផែនទីរាជធានីភ្នំពេញ



## ឧបសម្ព័ន្ធទី២៖ ស្ពានអាកាស និងស្ពានអាកាសថ្មើរជើង




ស្ពានអាកាស៧មករា



ស្ពានអាកាសក្បាលថ្នល់




ស្ពានអាកាសចោមចៅ( រូបភាព3D )




ស្ពានអាកាសតិចណូ



ស្ពានអាកាសផ្សារដើហុយ



ស្ពានអាកាសស្ទឹងមានជ័យ




ស្ពានអាកាសថ្មើរជើងស្តុបនាងគង្ហីង



ស្ពានអាកាសថ្មើរជើងជម្ពូវ័ន



ស្ពានអាកាសថ្មើរជើងផ្សារដើមគរ

## ឧបសម្ព័ន្ធទី៣៖ ចំណតរថយន្ត




ចំណតក្រោមដីសួនច្បារមិត្តភាពកម្ពុជា-ថៃ



ចំណតមុខវត្តឧណ្ណាលោម



ចំណតរថយន្តលើអគារ

# ឧបសម្ព័ន្ធគតិយុត្តិ

# ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

## ព្រះរាជក្រម

នស/រកម/០១១៧/០០៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឲ្យប្រើ**

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ច្បាប់នេះមានគោលបំណងធានាសុវត្ថិភាព សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងធានាការពារសុខភាពនិងអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន។

**មាត្រា២ ._**

ច្បាប់នេះមានគោលដៅដូចតទៅ៖

- ផ្តល់ការយល់ដឹងអំពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- គ្រប់គ្រងសុវត្ថិភាពចរាចរណ៍ផ្លូវគោក
- រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក
- ទប់ស្កាត់ការប្រព្រឹត្តបទល្មើសដែលបណ្តាលមកពីការប្រើប្រាស់ផ្លូវថ្នល់។

**មាត្រា៣._**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធនឹងចរាចរណ៍ផ្លូវគោកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ._**

វាក្យសព្ទដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោម៖

- **ផ្លូវថ្នល់** ហៅថាផ្លូវ សំដៅដល់ទំហំទាំងមូលរួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវ ឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានរំលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់
- **ផ្លូវជាតិ** សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើន៖
  - ក- ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញ ឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស។
  - ខ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត។
  - គ- ផ្លូវភ្ជាប់ចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវជាតិ។
  - ឃ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ។
  - ង- ផ្លូវបែកចេញពីផ្លូវជាតិឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋាន ទេសចរណ៍ ច្រកទ្វារព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត។
  - ច- ផ្លូវសំខាន់ៗរបស់ជាតិ មានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។
- **ផ្លូវខេត្ត** សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យម៖
  - ក- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។
  - ខ- ផ្លូវបែកចេញពីផ្លូវជាតិ ឆ្ពោះទៅកាន់ផ្លូវខេត្ត។
  - គ- ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុង ឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ។

ឃ- ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយ ឆ្ពោះទៅកាន់ផ្លូវខេត្ត។
ង- ផ្លូវបែកចេញពីផ្លូវខេត្ត ឆ្ពោះទៅកាន់ផ្លូវខេត្ត។
ច- ផ្លូវបែកចេញពីផ្លូវខេត្ត ឬផ្លូវក្រុង ឬផ្លូវទីប្រជុំជននានាក្នុងខេត្ត ទៅកាន់តំបន់សំខាន់ៗ ដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែនទ្វេភាគីតំបន់ មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។

- **ផ្លូវជនបទ** សំដៅដល់៖
ក- ផ្លូវដែលភ្ជាប់ពីផ្លូវជាតិ ផ្លូវខេត្ត ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ។
ខ- ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ។
គ- ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌ ទៅទីប្រជុំជនឃុំ សង្កាត់។
ឃ- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅទីប្រជុំជនឃុំ សង្កាត់។
ង- ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ ទៅភូមិ។
ច- ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ។
ឆ- ផ្លូវក្នុងភូមិ។

- **ផ្លូវល្បឿនលឿន** សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នា ឬចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយ ឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ដើម្បីធានានូវលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងដើម្បីបន្ថយពេលវេលាធ្វើដំណើរ និងមានកន្លែងកំណត់សម្រាប់ឲ្យយានយន្ត ចេញ និងចូលផ្លូវល្បឿនលឿន
- **បរិក្ខារផ្លូវថ្នល់** សំដៅដល់ទីចំណត ទីសំចត ភ្លើងសញ្ញា ផ្លាកសញ្ញាកំណត់ល្បឿន ផ្លាកសញ្ញាបង្ហាញផ្លូវ សញ្ញាចន្លោះគម្លាត គំនូសសញ្ញា ឬរបាំង ឬបរិក្ខារបែងចំណែកផ្លូវ រង្វង់មូល ខឿនបែងចែកទិសចរាចរណ៍ ថ្មចិញ្ចើមផ្លូវ ជញ្ជាំង របងការពារ បង្គោលគីឡូម៉ែត្រ បង្គោលសញ្ញាកំណត់ព្រំ ព្រមទាំងផ្លាកសញ្ញា និងឧបករណ៍បំពាក់ផ្សេងទៀតនៅតាមបណ្តោយផ្លូវថ្នល់
- **ទ្រូងផ្លូវ** សំដៅដល់ចំណែកនៃផ្លូវទុកសម្រាប់ឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍
- **ជាយផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជន ដែលយានជំនិះអាចចតនៅទីនោះបានក្នុងករណីចាំបាច់
- **ចិញ្ចើមផ្លូវ** សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជន ដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ
- **គន្លងផ្លូវ** សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវ ខណ្ឌដោយគំនូសឬបរិក្ខារបែងចំណែកផ្លូវតាម បណ្តោយទ្រូងផ្លូវ ដែលមានទទឹងគ្រប់គ្រាន់អាចឲ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ

- **ទីប្រជុំជន** សំដៅដល់ទីកន្លែងដែលមានអគារឬគេហដ្ឋានសង់ជិតៗគ្នា ហើយផ្លូវចេញឬចូលនៅទីនោះមានដាក់ផ្លាកសញ្ញាប្រាប់ទីប្រជុំជន ឈ្មោះទីប្រជុំជនសម្គាល់ការចូល ឬឈ្មោះ ទីប្រជុំជនដែលមានគំនូសបន្ទាត់ទ្រូងពណ៌ក្រហមសម្គាល់ការចេញពីទីប្រជុំជនតាមដងផ្លូវ និងមានមនុស្សធ្វើចរាចរណ៍ឆ្លងកាត់ទៅមកច្រើន
- **កន្លែងផ្លូវប្រសព្វឬផ្លូវប្រសព្វ** សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើន ដែលមានផ្ទៃតែមួយ និងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ ផ្លូវប្រសព្វអាចមានរាងជា +, X, T, Y ឬរង្វង់មូលជាដើម
- **រង្វង់មូល** សំដៅដល់កន្លែងផ្លូវប្រសព្វដែលនៅចំកណ្ដាលមានខឿនជារាងរង្វង់មូល មានផ្លាកសញ្ញាបង្ហាញទិសចរាចរណ៍ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយសញ្ញាព្រួញប្រាប់ទិសចរាចរណ៍
- **ច្រកចេញចូលផ្ទះឯកជន** សំដៅដល់ច្រកផ្លូវចេញចូលផ្ទះដែលមានផ្ទៃរាបស្មើភ្ជាប់ជាមួយផ្លូវសាធារណៈ និងមិនមែនជាចិញ្ចើមផ្លូវ
- **ឈប់** សំដៅដល់ការនៅស្ងៀមនៃយានជំនិះលើទ្រូងផ្លូវមួយរយៈពេលខ្លី ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូតឬក្បែរយានជំនិះខ្លួន ដើម្បីឲ្យអ្នកដំណើរឬយានជំនិះដទៃទៀតឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ
- **ចត** សំដៅដល់ការទុកឲ្យយានជំនិះនៅស្ងៀមក្នុងរយៈពេលយូរឬឆាប់ ដែលអ្នកបើកបរអាច ដើរចោលយានជំនិះរបស់ខ្លួនបាន
- **អ្នកបើកបរ** សំដៅដល់អ្នកបញ្ជាយានជំនិះគិតទាំងអ្នកជិះសត្វ អ្នកដឹកសត្វ និងអ្នកបរសត្វ នៅលើផ្លូវ
- **មួកសុវត្ថិភាព** សំដៅដល់មួកសុវត្ថិភាពតាមស្តង់ដាជាតិដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច សម្រាប់ពាក់នៅពេលធ្វើដំណើរតាមទោចក្រយានយន្តឬត្រីចក្រយានយន្តក្នុងគោលបំណងកាត់បន្ថយហានិភ័យនៃការរងរបួសក្បាលនៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង
- **ឧបករណ៍បច្ចេកទេស** សំដៅដល់ឧបករណ៍សម្រាប់ត្រួតពិនិត្យល្បឿន ឬជាតិអាល់កុល ឬសារធាតុញៀន ឬឧបករណ៍ប្រមូលរូបភាពនិងព័ត៌មានជាអាទិ៍
- **ឧបករណ៍សញ្ញា** សំដៅដល់ឧបករណ៍ប្រើប្រាស់ដោយភ្នាក់ងារចរាចរណ៍សម្រាប់ផ្តល់ជា សញ្ញាក្នុងការបញ្ជាឲ្យឈប់។ ឧបករណ៍សញ្ញានេះបញ្ចេញភ្លើងពណ៌ក្រហមនៅពេលងងឹត
- **យានជំនិះឬយាន** សំដៅដល់យានសម្រាប់ដឹកមនុស្សឬទំនិញនៅលើផ្លូវ ឬសម្រាប់សណ្តោង ឬត្រូវគេសណ្តោងទោះមានឬគ្មានម៉ាស៊ីន
- **រថយន្តដឹកជញ្ជូនអ្នកដំណើរធុនតូច** សំដៅដល់រថយន្តដឹកអ្នកដំណើរមានចំណុះចាប់ពី១០ (ដប់)នាក់ ដល់២០(ម្ភៃ)នាក់ ដោយគិតទាំងអ្នកបើកបរ
- **រថយន្តដឹកជញ្ជូនអ្នកដំណើរធុនធំ** សំដៅដល់រថយន្តដឹកអ្នកដំណើរមានចំណុះលើសពី២០ (ម្ភៃ)នាក់ ដោយគិតទាំងអ្នកបើកបរ

- **យានយន្ត** សំដៅដល់យានគ្រប់ប្រភេទ ដែលធ្វើចរាចរណ៍ដោយម៉ាស៊ីននៅលើផ្លូវថ្នល់
- **រថយន្តគ្រួសារ** សំដៅដល់រថយន្តដែលមានផ្ទុកមនុស្សមិនលើសពី៩(ប្រាំបួន)នាក់ ដោយគិតទាំងអ្នកបើកបរ។ រថយន្តប្រភេទនេះអាចត្រូវបានប្រើប្រាស់ជាលក្ខណៈគ្រួសារ
- **រថយន្តធុនស្រាល** សំដៅដល់រថយន្តដែលមានទម្ងន់សរុបអតិបរមាមិនលើសពី៣,៥ (បីក្បៀស ប្រាំ)តោន
- **រថយន្តធុនធ្ងន់** សំដៅដល់រថយន្តដែលមានទម្ងន់សរុបអតិបរមាលើសពី៣,៥(បីក្បៀសប្រាំ) តោនឡើងទៅ
- **រថយន្តក្រុង** សំដៅដល់រថយន្តដឹកជញ្ជូនអ្នកដំណើរធុនធំដែលបម្រើសេវាដឹកជញ្ជូនសាធារណៈ លើកំណាត់ផ្លូវមានកំណត់ក្នុងរាជធានីឬទីក្រុង និងយកកម្រៃ
- **យានយន្តកសិកម្មកែច្នៃ** សំដៅដល់យានយន្តបករណ៍កែច្នៃសម្រាប់បម្រើការងារកសិកម្ម ដូចជា យានយន្តច្រូតស្រូវ យានយន្តបោកបែនស្រូវ និងយានយន្តកិនស្រូវ ជាអាទិ៍
- **យានយន្តបករណ៍** សំដៅដល់យានយន្តពិសេសដែលមានឧបករណ៍ គ្រឿងចក្របំពាក់បន្ថែម គ្មានផ្ទុកមនុស្ស ឬគ្មានផ្ទុកទំនិញនៅក្រៅកាប៊ីន ដូចជារថយន្តលាយស៊ីម៉ងត៍ឬរថយន្តសម្រាប់ បម្រើការងារសាងសង់ផ្លូវ ស្ពានជាអាទិ៍
- **រថយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញនិងអ្នកដំណើរ** សំដៅដល់រថយន្តធ្វើអាជីវកម្មដឹកជញ្ជូនទំនិញរបស់អ្នកដទៃឬផ្ទាល់ខ្លួន និងដឹកជញ្ជូនអ្នកដំណើរ
- **អ្នកប្រើប្រាស់ផ្លូវ** សំដៅដល់អ្នកបើកបរនិងថ្មើរជើងដែលធ្វើដំណើរនៅលើផ្លូវ
- **ទម្ងន់ទទេរបស់យាន** សំដៅដល់ទម្ងន់របស់យានដែលគ្មានមនុស្សឬគ្មានទំនិញ ប៉ុន្តែមាន ប្រេងឥន្ធនៈសម្រាប់ផ្តល់ឲ្យយាន មានឧបករណ៍ជួសជុល និងកង់បម្រុង
- **ទម្ងន់ផ្ទុកអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់ផ្ទុកមនុស្សនិងទម្ងន់ផ្ទុកទំនិញដែល កំណត់ដោយរោងចក្រផលិតយាន
- **ទម្ងន់សរុបអតិបរមារបស់យាន** សំដៅដល់ផលបូកសរុបទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ ផ្ទុកអតិបរមារបស់យាន។ ប្រសិនបើយានមានសណ្តោង ទម្ងន់សរុបអតិបរមារបស់យានគឺជា ផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ
- **ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញអនុញ្ញាត។ ប្រសិនបើយានមានសណ្តោង ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន គឺជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ
- **ទម្ងន់សរុបជាក់ស្តែងរបស់យាន** សំដៅដល់ផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្សនិងទម្ងន់ផ្ទុកទំនិញជាក់ស្តែង
- **ទំនិញ** សំដៅដល់សម្ភារៈ វត្ថុ ដី ថ្ម ក្រួស ខ្សាច់ ប្រេងឥន្ធនៈ សត្វ និងវត្ថុផ្សេងៗទៀត ដែលដឹកជញ្ជូនតាមយានជំនិះ
- **រ៉ឺម៉ក** សំដៅដល់យានសម្រាប់ផ្តក់ជាមួយរថយន្តឬយានជំនិះផ្សេងទៀត

- **សីមីរ៉ឺម៉ក** សំដៅដល់យានសម្រាប់ថ្កក់ជាប់នឹងក្បាលរថយន្តសណ្តោង។

## ជំពូកទី២
## សញ្ញាចរាចរណ៍

**មាត្រា៥ .-**

សញ្ញាចរាចរណ៍ផ្លូវគោករួមមាន ផ្លាកសញ្ញាចរាចរណ៍នៅតាមផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត។

ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ ត្រូវរៀបចំជាប្រព័ន្ធទាក់ទងស៊ីចង្វាក់គ្នាជាហូរហែនៅតាមកន្លែងមានសារប្រយោជន៍ ដែលធ្វើឲ្យអ្នកប្រើប្រាស់ផ្លូវ ងាយស្រួលមើលឃើញ។

សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយសមស្រប ល្មមគ្រប់គ្រាន់តាមប្រភេទផ្លូវ ចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវ ដែលអាចធ្វើឲ្យអ្នកបើកបរមានស្មារតី ប្រុងប្រយ័ត្នជាមុនបាន។

ហាមបិទក្រដាសឬរបស់ផ្សេងៗទៀត ឬគូសវាសនៅលើផ្លាកសញ្ញា ឬប្រើប្រាស់ទម្រផ្លាកសញ្ញា ឬនៅលើសម្ភារៈអ្វីផ្សេងៗទៀតដែលប្រើប្រាស់សម្រាប់សញ្ញាចរាចរណ៍ ដែលជាហេតុធ្វើឲ្យអ្នកបើកបរ មិនអាចមើលឃើញសញ្ញាចរាចរណ៍ច្បាស់បានល្អ ឬយល់ខ្លឹមសារសញ្ញាចរាចរណ៍មិនបានត្រឹមត្រូវ ឬធ្វើ ឲ្យអ្នកបើកបរចាំងភ្នែក។

រូបភាពនិងខ្លឹមសារស្តីពីសញ្ញាចរាចរណ៍ផ្លូវគោក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៦ .-**

លំដាប់សិទ្ធិអាទិភាពត្រូវបានកំណត់ដូចតទៅ៖

១- ផ្លាកសញ្ញាចរាចរណ៍មានសិទ្ធិអាទិភាពលើបទប្បញ្ញត្តិចរាចរណ៍។

២- ភ្លើងសញ្ញាចរាចរណ៍មានសិទ្ធិអាទិភាពលើផ្លាកសញ្ញាចរាចរណ៍។

៣- សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍មានសិទ្ធិអាទិភាពលើភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើទ្រូងផ្លូវ ផ្លាកសញ្ញាចរាចរណ៍នៅតាមដងផ្លូវ និងបទប្បញ្ញត្តិចរាចរណ៍ទាំងឡាយ។

## ជំពូកទី៣
## អ្នកបើកបរយានជំនិះ

**មាត្រា៧ .-**

ការបើកបរយានជំនិះគ្រប់ប្រភេទក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវប្រកាន់ស្តាំជានិច្ច។ គ្រប់យានជំនិះដែលមានចលនានៅលើផ្លូវថ្នល់ ត្រូវតែមានអ្នកបើកបរ។

រថយន្តដឹកទំនិញដែលមានទម្ងន់សរុបលើសពី១៦(ដប់ប្រាំមួយ)តោន ឬរថយន្តដឹកអ្នកដំណើរដែលផ្ទុកអ្នកដំណើរចាប់ពី៣៥(សាមសិបប្រាំ)នាក់ឡើង ត្រូវមានអ្នកបើកបរ១(មួយ)នាក់និងជំនួយការបើកបរ១(មួយ)នាក់ ដែលកាន់បណ្ណបើកបរត្រឹមត្រូវតាមប្រភេទរថយន្តអមជាមួយ ស្របតាមប្រភេទផ្លូវ ចម្ងាយផ្លូវ និងពេលវេលាធ្វើដំណើរ។

**មាត្រា៨ .. ថ្មី**

គ្រប់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តនូវវិធានការដូចតទៅ៖

១- ត្រូវមានបណ្ណបើកបរចំពោះអ្នកបើកបរយានយន្តដូចខាងក្រោម៖

- រថយន្តគ្រប់ប្រភេទ
- ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត
- យានយន្តដែលមានទំហំស៊ីឡាំងលើសពី១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូបឡើងទៅ ឬមានថាមពលអគ្គិសនីលើសពី១១(ដប់មួយ)គីឡូវ៉ាត់។ ចំពោះយានយន្ត ដែលមានទំហំស៊ីឡាំងចាប់ពី១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូបចុះក្រោម ឬមានថាមពលអគ្គិសនីចាប់ពី១១(ដប់មួយ)គីឡូវ៉ាត់ចុះក្រោម អ្នកបើកបរមិនតម្រូវឲ្យមានបណ្ណបើកបរឡើយ ប៉ុន្តែត្រូវមានអាយុយ៉ាងតិច១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ ដោយមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ។

២- នៅពេលបើកបរយានជំនិះ អ្នកបើកបរត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ហើយស្ថិតក្នុងស្ថានភាពដែលអាចធ្វើសកម្មភាពបើកបរបានយ៉ាងស្រួល និងឆាប់រហ័ស ជាពិសេសលទ្ធភាពនៃការធ្វើចលនាមិនត្រូវឲ្យមានការរំខានឡើយ។

៣- ហាមធ្វើឲ្យរំខានដល់អ្នករស់នៅជាប់តាមដងផ្លូវនិងអ្នកប្រើប្រាស់ផ្លូវ។

៤- ហាមពិសាគ្រឿងស្រវឹង ដែលបណ្តាលឲ្យមានអត្រាជាតិអាល់កុលចាប់ពី០,២៥(សូន្យក្បៀសម្ភៃប្រាំ)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៥០(សូន្យក្បៀសហាសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

៥- ហាមបើកបរយានជំនិះដែលមានកង់ច្រវាក់ដែកផ្ទាល់លើទ្រូងផ្លូវ។ យានជំនិះប្រភេទនេះ ត្រូវដឹកតាមយានជំនិះដែលមានប្រភេទកង់កៅស៊ូ។

៦- ហាមប្រើទូរស័ព្ទនៅពេលកំពុងបើកបរយានជំនិះ ដោយគ្មានឧបករណ៍សំឡេងភ្ជាប់ទំនាក់ទំនង។

៧- ហាមផ្ទុកអ្នកដំណើរ ទំនិញ ឬវត្ថុផ្សេងៗដែលនាំឲ្យបាំងភ្នែកអ្នកបើកបរ។

៨- ទោចក្រយានយន្តអាចផ្ទុកមនុស្សពីរនាក់និងអាចបន្ថែមបានកុមារមួយនាក់។ អ្នកបើកបរទោចក្រយានយន្តនិងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុចាប់ពី៣(បី)ឆ្នាំឡើងទៅ ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ។ អ្នកបើកបរត្រីចក្រយានយន្តនិងអ្នកបើកបរទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ។

៩- នៅក្នុងទីប្រជុំជនអ្នកបើកបរនិងអ្នករួមដំណើរជិះកៅអីមុខនៃរថយន្ត ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព។

១០-នៅក្រៅទីប្រជុំជនអ្នកបើកបរនិងអ្នករួមដំណើរទាំងអស់តាមរថយន្ត ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៩០ថ្មី នៃច្បាប់នេះ។

១១- កុមារអាយុតិចជាង១០(ដប់)ខែ ត្រូវដាក់ក្នុងកៅអីសម្រាប់កុមារដេកនិងមានខ្សែក្រវាត់សុវត្ថិភាពចងផ្អែកកៅអីនេះឲ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត។

១២-កុមារមានអាយុចាប់ពី១០(ដប់)ខែទៅក្រោម៥(ប្រាំ)ឆ្នាំ ត្រូវអង្គុយក្នុងកៅអីសម្រាប់កុមារ ដែលមានខ្សែក្រវាត់សុវត្ថិភាពចងផ្អែកកៅអីនេះឲ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត។

១៣- ហាមកុមារអាយុក្រោម១០(ដប់)ឆ្នាំ អង្គុយនៅកៅអីមុខនៃរថយន្ត។

**មាត្រា៩ ..**

នៅលើទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរ ហើយដែលគ្មានគំនូសសញ្ញាបែងចែកទិសចរាចរណ៍ អ្នកបើកបរត្រូវប្រើប្រាស់ពាក់កណ្ដាលទ្រូងផ្លូវផ្នែកខាងស្ដាំ ដោយបើកបរកៀកទៅខាងស្ដាំ។

នៅលើទ្រូងផ្លូវឯកទិសដែលគ្មានគំនូសសញ្ញាបែងចែកគន្លងផ្លូវ អ្នកបើកបរត្រូវបើកបរកៀកទៅ ខាងស្ដាំលើកលែងតែត្រូវការបត់ឆ្វេង។ អ្នកបើកបរអាចប្រើប្រាស់ទ្រូងផ្លូវខាងឆ្វេងបាននៅពេលជែងឬ ឈប់។ ដោយឡែកនៅក្នុងទីប្រជុំជន ការប្រើប្រាស់ទ្រូងផ្លូវត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សាធារណការនិងដឹកជញ្ជូន។

**មាត្រា១០ ..**

នៅលើគន្លងផ្លូវតម្រូវសម្រាប់យានជំនិះប្រភេទណាមួយ អ្នកបើកបរយានជំនិះប្រភេទដទៃមិនត្រូវបើកបរចូលក្នុងគន្លងនេះទេ លើកលែងតែត្រូវចាកចេញឬចូលទៅក្នុងគន្លងផ្លូវរបស់ខ្លួន។

នៅលើទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរ ហើយមានគំនូសបែងចែកទ្រូងផ្លូវ អ្នកបើកបរត្រូវ ប្រកាន់យកចំណែកផ្លូវខាងស្ដាំ។

នៅលើទ្រូងផ្លូវឯកទិសដែលមានគន្លងផ្លូវពីរឬច្រើន អ្នកបើកបរត្រូវប្រកាន់យកគន្លងផ្លូវខាងស្ដាំ បំផុត។ ក្នុងករណីមានចរាចរណ៍ចង្អៀតខ្លាំង អ្នកបើកបរអាចបើកបរបានលើគ្រប់គន្លងផ្លូវ។

នៅលើទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរផ្ទុយគ្នា ហើយនៅលើចំណែកផ្លូវនៃទិសនីមួយៗដែលមានគន្លងផ្លូវពីរឬច្រើន អ្នកបើកបរត្រូវប្រកាន់យកគន្លងផ្លូវខាងស្ដាំបំផុត។ ក្នុងករណីមានចរាចរណ៍ចង្អៀត ខ្លាំងអ្នកបើកបរអាចបើកបរបានលើគ្រប់គន្លងផ្លូវតាមទិសចរាចរណ៍។

ក្នុងករណីមានចរាចរណ៍ចង្អៀតខ្លាំង ដូចមានចែងនៅកថាខណ្ឌ៣និងកថាខណ្ឌ៤ខាងលើយានជំនិះនៅក្នុងគន្លងណាមួយលឿនជាងយានជំនិះនៅក្នុងគន្លងណាមួយទៀត មិនចាត់ទុកជាការជែងឡើយ។ ចំពោះអ្នកបើកបរយានជំនិះដែលមានទម្ងន់សរុបលើសពី៣,៥(បីក្បៀសប្រាំ)តោន ត្រូវប្រកាន់យកគន្លងផ្លូវខាងស្ដាំជានិច្ច លើកលែងមានការបត់ឆ្វេងឬនៅពេលជែងអាចប្រើប្រាស់គន្លងផ្លូវផ្សេងទៀតបាន។ ដោយឡែកនៅក្នុងទីប្រជុំជន ការប្រើប្រាស់ទ្រូងផ្លូវត្រូវកំណត់

ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា១១ ..**

ភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺពណ៌លឿង ជាសញ្ញាឲ្យប្រុងប្រយ័ត្ន ត្រៀមឈប់ ពន្លឺពណ៌បៃតង ជាសញ្ញាអនុញ្ញាតឲ្យយានជំនិះចេញដំណើរ ពន្លឺពណ៌ក្រហមជាសញ្ញាឃាត់ឲ្យឈប់។

ភ្លើងសញ្ញាចរាចរណ៍បញ្ចេញពន្លឺក្រហមគឺជាសញ្ញាឃាត់ឲ្យឈប់ អ្នកបើកបរត្រូវឈប់នៅមុខខ្សែបន្ទាត់គំនូសជាប់ពណ៌សកាត់ទទឹងទ្រូងផ្លូវឬមុខគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់។ បើគ្មានឧបសគ្គ នៅខាងមុខ យានជំនិះខាងស្តាំបំផុតអាចបត់ស្តាំបានដោយប្រុងប្រយ័ត្ន លើកលែងតែមានភ្លើងសញ្ញាព្រួញក្រហមហាមបត់ស្តាំ។

**មាត្រា១២ ..**

អ្នកបើកបរត្រូវវាងតាមស្តាំដៃ នៅគ្រប់រង្វង់មូលឬខឿនបែងចែកទ្រូងផ្លូវ ដែលជាឧបសគ្គនៃចលនា ត្រង់ទៅមុខរបស់យានជំនិះ លើកលែងតែមានកំណត់ផ្ទុយ។

**មាត្រា១៣ ..**

អ្នកបើកបរមិនត្រូវបើកបរទន្ទឹមគ្នានៅលើទ្រូងផ្លូវឬគន្លងផ្លូវតែមួយទេ។ អ្នកបើកបរមិនត្រូវបើកបរ កាត់ឬដែងក្បួនយោធា ឬក្បួននគរបាល ឬក្បួនគណៈប្រតិភូ ឬក្បួនដង្ហែផ្លូវការ។

**មាត្រា១៤ ..**

បែបបទនៃការសណ្តោង ត្រូវអនុវត្តតាមបញ្ញត្តិដូចខាងក្រោម៖

- ចំពោះការថ្ពក់សណ្តោងយានជំនិះ អ្នកបើកបរត្រូវប្រើខ្សែកាប ឬដងដែក ឬឧបករណ៍សម្រាប់ថ្ពក់ ដែលធានាជាប់មាំល្អនិងងាយស្រួលក្នុងការបត់បែន
- ហាមអ្នកបើកបរប្រើខ្សែសណ្តោងចំពោះយានជំនិះដែលមានទម្ងន់សរុបលើសពី៥ (ប្រាំ) តោនឡើងទៅ
- ហាមអ្នកបើកបរសណ្តោងយានជំនិះលើសពីមួយគ្រឿង ឬសណ្តោងយានជំនិះដែលមាន សណ្តោងរ៉ឺម៉កឬសឺមីរ៉ឺម៉ក
- ហាមសណ្តោងទោចក្រយានឬទោចក្រយានយន្ត
- ហាមអ្នកបើកបរសណ្តោងរថយន្តគ្រប់ប្រភេទ ដែលមានអ្នកដំណើរនៅក្នុងនោះ ក្រៅពីអ្នកកាន់ចង្កូត
- រថយន្តដែលមានសណ្តោងរ៉ឺម៉កឬសឺមីរ៉ឺម៉ក ត្រូវមានសញ្ញាត្រីកោណសមបាតដែលមានកញ្ចក់ចាំងពន្លឺពណ៌លឿងពីរដាក់នៅកាងរថយន្តខាងមុខអមសងខាងផ្លាកលេខ។

បច្ចេកទេសនៃការថ្ពក់សណ្តោងរ៉ឺម៉កឬសឺមីរ៉ឺម៉ក និងការដោះរ៉ឺម៉កឬសឺមីរ៉ឺម៉កចេញពីរថយន្ត ឬក្បាលរថយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៥ ..**

នៅកន្លែងរថយន្តក្រុងឈប់នៅក្នុងទីប្រជុំជន អ្នកបើកបរយានជំនិះគ្រប់ប្រភេទត្រូវបន្ថយល្បឿន ហើយបើចាំបាច់ត្រូវឈប់ដើម្បីទុកឲ្យរថយន្តក្រុងចេញ ចូល ឬឈប់បានដោយងាយស្រួល។

**មាត្រា១៦ ..**

ល្បឿនបើកបរយានជំនិះត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោមនេះ៖

- ការកំណត់ល្បឿនសម្រាប់យានជំនិះត្រូវកំណត់ដោយអនុក្រឹត្យ
- អ្នកបើកបរមិនត្រូវប្រើល្បឿនយឺតខុសប្រក្រតីដោយគ្មានមូលហេតុត្រឹមត្រូវ ដែលធ្វើឲ្យរំខានដល់យានជំនិះដទៃទៀតទេ។ អ្នកបើកបរដែលប្រើល្បឿនយឺត ត្រូវបើកបរអែបទៅខាងស្តាំ ដើម្បីទុកឲ្យអ្នកបើកបរដែលប្រើល្បឿនលឿនជែងពីខាងឆ្វេងដៃបានដោយងាយស្រួល
- អ្នកបើកបរណាដែលត្រូវបង្ខំចិត្តបន្ថយល្បឿនឲ្យយឺតខុសប្រក្រតី ត្រូវឲ្យដំណឹងដល់អ្នកបើកបរ ផ្សេងទៀតដោយប្រើភ្លើងសញ្ញាអាសន្ន ហើយត្រូវបើកបរអែបទៅខាងស្តាំបំផុតនៃទ្រូងផ្លូវ
- បទប្បញ្ញត្តិកំណត់ល្បឿនមិនអនុវត្តចំពោះអ្នកបើកបរយានយន្ត ក្បួននគរបាល ក្បួនយោធា ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ និងយានយន្តខ្លះទៀតដែលបន្លឺសូរសព្ទ ភ្លើងសញ្ញាពិសេសនៅពេលកំពុងបំពេញភារកិច្ចឡើយ។

**មាត្រា១៧ ..**

ក្នុងគ្រប់ករណីអ្នកបើកបរត្រូវគ្រប់គ្រងលើល្បឿនបើកបររបស់ខ្លួនជានិច្ច ហើយត្រូវបើកបរក្នុងល្បឿនសមស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីអាចបញ្ឈប់យានជំនិះបានទាន់ពេលវេលានិងដោយ គ្មានគ្រោះថ្នាក់។

អ្នកបើកបរត្រូវបន្ថយល្បឿន ក្នុងករណីដូចខាងក្រោម៖

១- ពេលជៀសគ្នានៅលើផ្លូវចង្អៀត។

២- ពេលជៀសរថយន្តដឹកជញ្ជូនអ្នកដំណើរ ឬរថយន្តដឹកជញ្ជូនកុមារ ដែលកំពុងឈប់ដាក់ អ្នកដំណើរឬកុមារឡើងចុះ។

៣- ពេលទៅជិតដល់ស្ពានឬជិតដល់ផ្លូវរថភ្លើងឆ្លងកាត់។

៤- ពេលអាកាសធាតុមិនល្អដែលមិនអាចមើលឃើញបានឆ្ងាយនិងច្បាស់។

៥- ពេលប្តូរទិសចរាចរណ៍។

៦- កន្លែងផ្លូវបត់ ផ្លូវកោង ផ្លូវរអិល ផ្លូវប្រសព្វ ឬរង្វង់មូល។

៧- ពេលជិតដល់ទួលខ្ពស់ឬពេលចុះចំណោត។

៨- ពេលជៀសឬជែងក្បួនយានកំពុងឈប់ ឬនៅពេលជៀសឬជែងក្បួនដង្ហែផ្សេងៗ។

៩- ពេលមានវត្ថុជាឧបសគ្គឬមានផ្ទះច្រើនកៀកជាប់ទ្រូងផ្លូវ។

១០- ក្នុងគ្រប់ករណីដែលមានផ្លាកសញ្ញាឲ្យបន្ថយល្បឿនឬសញ្ញាគ្រោះថ្នាក់។

១១- កាលណាមានយានយន្តរបស់នគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ យានយន្តពន្លត់អគ្គិភ័យ យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ មានបន្លឺសូរសេព្ទ ឬភ្លើងសញ្ញា ឬយានយន្តផ្សេងទៀតដែលមានបន្លឺសូរសេព្ទ ឬភ្លើងសញ្ញា អ្នកប្រើ

ប្រាស់ផ្លូវទាំងអស់ត្រូវបន្ថយល្បឿន ហើយបើកបរអែបទៅខាងស្តាំ បើចាំបាច់ត្រូវឈប់នៅកៀនបំផុតដែលអាចធ្វើទៅបាន ដើម្បីសម្រួលផ្លូវឲ្យយានយន្តទាំងនេះធ្វើដំណើរទៅមុខដោយសុវត្ថិភាព។

១២- កន្លែងមានសាលារៀន មន្ទីរពេទ្យដែលមានទីតាំងស្ថិតនៅក្បែរផ្លូវមិនលើសពី៥០ (ហាសិប) ម៉ែត្រ។

**មាត្រា១៨ ..**

យានយន្តដែលធ្វើចរាចរណ៍នៅពីក្រោយយានយន្តមួយផ្សេងទៀត ត្រូវរក្សាទុកចន្លោះសុវត្ថិភាពគ្រប់គ្រាន់ដើម្បីជៀសវាងការប៉ះទង្គិច នៅពេលដែលយានយន្តខាងមុខបន្ថយល្បឿនឬឈប់ដោយចៃដន្យ។ ចន្លោះសុវត្ថិភាពសម្រាប់យានយន្តគ្រប់ប្រភេទដែលធ្វើចរាចរណ៍ នៅលើផ្លូវថ្នល់ ត្រូវកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៩ ..**

ក្នុងការជែង អ្នកបើកបរត្រូវអនុវត្តដូចខាងក្រោម៖

១- អ្នកបើកបរយានជំនិះគ្រប់ប្រភេទត្រូវជែងទៅខាងឆ្វេង។ ប៉ុន្តែអ្នកបើកបរអាចជែងទៅខាងស្តាំបាន ប្រសិនបើអ្នកបើកបរយានដែលត្រូវគេជែងនោះ បាននិងកំពុងធ្វើសញ្ញាប្តូរទិសខាងឆ្វេង ហើយឈប់ ឬត្រៀមដើម្បីបត់ឆ្វេង។

២- មុននឹងជែង អ្នកបើកបរត្រូវដឹងច្បាស់ថា ការជែងនេះមិនបណ្តាលឲ្យមានគ្រោះថ្នាក់អ្វីឡើយ ដោយត្រូវអនុវត្តដូចខាងក្រោម៖

ក- ឃើញច្បាស់ថា នៅខាងមុខគ្មានឧបសគ្គហើយអាចបើកបរចូលទៅក្នុងចរន្តចរាចរណ៍ប្រក្រតីវិញបាននៅពេលជែងរួច ដោយមិនរំខានដល់ការធ្វើចរាចរណ៍របស់អ្នកដទៃឡើយ។

ខ- គ្មានអ្នកបើកបរយានជំនិះណាមួយដែលនៅពីក្រោយខ្លួនចាប់ផ្តើមសុំជែងខ្លួន។

គ- គ្មានឲ្យសញ្ញាសុំជែងយានផ្សេងទៀត ពីអ្នកបើកបរយានជំនិះខាងមុខខ្លួន។

ឃ- ត្រូវដឹងច្បាស់ថាល្បឿនសមាមាត្ររវាងយានទាំងពីរ អាចឲ្យជែងក្នុងរយៈពេលខ្លីបំផុតបាន។

ង- ត្រូវធ្វើសញ្ញាសុំជែង ដោយប្រើសញ្ញាប្តូរទិសខាងឆ្វេង ហើយក្នុងករណីចាំបាច់ត្រូវប្រើបន្ថែមភ្លើងកូត ហ្វាឆ្លាស់គ្នានៅពេលយប់ ឬស៊ីផ្លេនៅពេលថ្ងៃ លើកលែងតែក្នុងទីប្រជុំជនដែលការប្រើប្រាស់ស៊ីផ្លេសុំជែង ត្រូវហាមឃាត់។

ច- ត្រូវដឹងច្បាស់ថា អ្នកបើកបរយានជំនិះខាងក្រោយនិងខាងមុខបានដឹងអំពីការសុំជែង របស់ខ្លួនហើយ។

៣- នៅពេលដឹងថាយានខាងក្រោយសុំជែង អ្នកបើកបរយានខាងមុខត្រូវពិនិត្យចំណែកផ្លូវខាងមុខខ្លួន បើគ្មានឧបសគ្គអ្វីទេ ត្រូវឲ្យសញ្ញាប្តូរទិសខាងស្តាំឬលើកដៃឆ្វេងឡើងស្រេចបត់ទៅស្តាំ និង បន្ថយល្បឿនអែបទៅខាងស្តាំ ជាសញ្ញាឲ្យអ្នកបើកបរយានខាងក្រោយដែលសុំជែងដឹងថាអាចជែងបាន។ ក្នុងករណីដែលអ្នកបើកបរខាងមុខពិនិត្យឃើញថានៅចំណែក

ផ្លូវខាងមុខខ្លួនមិនទំនេរឬមានឧបសគ្គ ត្រូវធ្វើសញ្ញាប្តូរទិសខាងឆ្វេងឬលាតដៃឆ្វេងសន្ធឹងត្រង់ទៅខាងក្រៅជាសញ្ញាឲ្យដឹងថាការជែងពុំទាន់អាចធ្វើទៅបានទេ។

៤- នៅពេលជែង ត្រូវបង្កើនល្បឿននិងទុកចន្លោះពីយានមួយទៀតយ៉ាងតិច១(មួយ) ម៉ែត្រ។

៥- នៅលើទ្រូងផ្លូវគ្មានគំនូសបង្កួត អ្នកបើកបរយានអាចជែងដោយប្រើប្រាស់ទ្រូងផ្លូវមួយចំហៀងទៀតបាន ប្រសិនបើទង្វើនេះមិនធ្វើឲ្យមានគ្រោះថ្នាក់ឬរំខានដល់យានដែលបើកបរផ្ទុយនឹងទិសរបស់ខ្លួន។

៦- នៅពេលជែងផុត អ្នកបើកបរត្រូវធ្វើសញ្ញាប្តូរទិសខាងស្តាំវិញ ដើម្បីឲ្យដំណឹងថាខ្លួនត្រូវចូល ក្នុងចរន្តចរាចរណ៍របស់ខ្លួនវិញ។

៧-ក្នុងករណីទ្រូងផ្លូវមានគន្លងផ្លូវច្រើនតាមទិសចរាចរណ៍តែមួយសម្រាប់ទិសដៅផ្សេងគ្នា យានស្ថិតនៅគន្លងណាមួយបើកបរលឿនជាងយាននៅគន្លងណាមួយទៀត មិនចាត់ទុកជាការជែងឡើយ។

ហាមជែងគ្នានៅក្នុងករណីខាងក្រោម៖

- ជែងគ្នាជាបីជួរ(ជែងលើរថយន្តដែលកំពុងជែងគ្នា)
- កន្លែងមានសញ្ញាហាមជែង
- នៅកន្លែងផ្លូវកោងឬផ្លូវឡើងទួល លើកលែងតែការជែងនេះអាចទុកឲ្យផ្នែកទ្រូងផ្លូវខាងឆ្វេងគំនូសបង្កួតកណ្តាលនៅទំនេរបាន
- នៅជិតឬកន្លែងផ្លូវបត់ ផ្លូវខ្វែង ផ្លូវរង្វិល
- នៅកន្លែងកំពូលផ្លូវចោត ផ្លូវតូចចង្អៀត ឬផ្លូវដាក់សញ្ញាបន្ថយល្បឿន
- នៅលើស្ពានឬពេលចុះចំណោត
- នៅកន្លែងការដ្ឋាន
- នៅជិតឬកន្លែងកំណាត់ផ្លូវដែលទុកសម្រាប់ថ្មើរជើងឆ្លងកាត់
- នៅផ្លូវក្រោមស្ពានឬផ្លូវរូង
- នៅពេលមើលឃើញមិនច្បាស់ ដូចជាពេលភ្លៀងខ្លាំង ចុះអ័ព្ទខ្លាំង ដីហុយខ្លាំង ឬផ្សែងខ្លាំង
- នៅជិតឬកន្លែងផ្លូវថ្នល់កាត់ផ្លូវរថភ្លើងដែលគ្មានរបាំង
- នៅលើផ្លូវដែលមានទឹកលិច។

**មាត្រា២០ ..**

ក្នុងការជៀស៖

១- អ្នកបើកបរយានជំនិះគ្រប់ប្រភេទ ត្រូវជៀសគ្នាដោយប្រកាន់ស្តាំដៃរៀងៗខ្លួន។

២- ពេលជៀសគ្នានៅលើផ្លូវចង្អៀត ឬនៅលើផ្លូវដែលអាចមានគ្រោះថ្នាក់ អ្នកបើកបរត្រូវបន្ថយល្បឿនរៀងៗខ្លួន។ ក្នុងករណីចាំបាច់ យានជំនិះទាំងពីរត្រូវឈប់ ហើយបើជាយានជំនិះប្រភេទដូចគ្នា យានជំនិះណាចង់ទៅមុនត្រូវធ្វើសញ្ញាសុំផ្លូវដោយលើកដៃឬដោយស៊ីផ្លេនៅ

ពេលថ្ងៃ ឬប្រើភ្លើងហ្វាក្លកជាសញ្ញានៅពេលយប់ ហើយរង់ចាំយានជំនិះដែលមកពីមុខបញ្ចេញសញ្ញាយល់ព្រមឲ្យទៅមុន ទើបធ្វើដំណើរទៅបាន។ ប៉ុន្តែបើជាយានជំនិះប្រភេទខុសគ្នា អ្នកបើកបរយានយន្តដែលមានទំហំធំត្រូវទុកផ្លូវឲ្យយានជំនិះដែលមានទំហំតូចជាងយានជំនិះរបស់ខ្លួនធ្វើដំណើរទៅមុន។

៣- ពេលជៀសគ្នានៅលើផ្លូវតូចដែលបរបានយានជំនិះតែមួយ ហើយមានកន្លែងមួយដែលអាចជៀសគ្នាបាន យានជំនិះណាដែលមកដល់កន្លែងនេះមុន ត្រូវឈប់រង់ចាំនៅកន្លែងនេះ ដើម្បីទុកឲ្យយានជំនិះមួយទៀតជៀសបានស្រួល។

៤- ក្នុងករណីទ្រូងផ្លូវចង្អៀត មិនអាចជៀសគ្នាបាន ហើយចាំបាច់មានយានជំនិះណាមួយត្រូវថយក្រោយ ត្រូវអនុវត្តដូចខាងក្រោម៖

ក- ចំពោះយានជំនិះប្រភេទដូចគ្នា យានជំនិះណាចង់ទៅមុន ត្រូវធ្វើសញ្ញាសុំផ្លូវ ហើយត្រូវ មានការយល់ព្រមថយក្រោយពីយានមួយទៀត។

ខ- ចំពោះយានគ្មានសណ្តោងនិងយានមានសណ្តោង យានគ្មានសណ្តោងត្រូវថយក្រោយ។

គ- ចំពោះយានធុនស្រាល និងធុនធ្ងន់ យានធុនស្រាលត្រូវថយក្រោយ។

ឃ- ចំពោះរថយន្តដឹកទំនិញនិងរថយន្តដឹកអ្នកដំណើរ រថយន្តដឹកទំនិញត្រូវថយក្រោយ។

៥- ពេលជៀសគ្នានៅលើផ្លូវចោតហើយចង្អៀត យានជំនិះចុះចំណោតត្រូវឈប់ដើម្បីទុកឲ្យ យានជំនិះឡើងចំណោតទៅមុន។

៦- ក្នុងការជៀសគ្នា យានជំនិះណាមើលឃើញនៅលើចំណែកផ្លូវរបស់ខ្លួនមានឧបសគ្គ ដូចជា ផ្លូវខូច ឬយានជំនិះឈប់ស្ងៀម យានជំនិះនោះត្រូវឈប់ដើម្បីទុកឲ្យយានជំនិះមួយទៀតទៅមុន។

៧- នៅលើស្ពានចង្អៀតដែលបើកបរបានតែរថយន្តមួយគ្រឿង យានយន្តធុនធំត្រូវទុកសិទ្ធិឲ្យ យានយន្តធុនស្រាលទៅមុន។

៨- មុនពេលជៀសគ្នានៅពេលយប់ក្រៅទីប្រជុំជន ហើយគ្មានចង្កៀងអគ្គិសនី យានជំនិះទាំងពីរត្រូវបិទភ្លើងហ្វាហើយបើកភ្លើងក្លូតវិញ។

**មាត្រា២១.-**

សិទ្ធិអាទិភាពនៅផ្លូវប្រសព្វ ត្រូវបានកំណត់ដូចខាងក្រោម៖

១- គ្រប់អ្នកបើកបរនៅពេលទៅជិតដល់ផ្លូវប្រសព្វ ត្រូវបន្ថយល្បឿននិងពិនិត្យមើលចលនាចរាចរណ៍នៅលើទ្រូងផ្លូវដែលខ្លួនត្រូវឆ្លងកាត់នោះ ហើយត្រូវធ្វើដំណើរឆ្លងកាត់ដោយប្រុងប្រយ័ត្នបំផុត បើផ្លូវខាងមុខមិនស្រលះល្អ។ ក្នុងករណីចាំបាច់ ត្រូវធ្វើសញ្ញាឲ្យដំណឹងដល់អ្នកបើកបរដែលមកពីផ្លូវផ្សេងទៀត ដោយប្រើសញ្ញាសូរសព្ទពេលថ្ងៃ និងប្រើភ្លើងសញ្ញាក្នុង ហ្វាឆ្លាស់គ្នានៅពេលយប់។ នៅលើផ្លូវផ្តល់សិទ្ធិអាទិភាពឲ្យគេ អ្នកបើកបរត្រូវបើកបរក្នុងល្បឿនមួយដែលអាចបញ្ឈប់យានខ្លួនបានដើម្បី ផ្តល់សិទ្ធិដល់យានដែលនៅលើផ្លូវមានសិទ្ធិទៅមុន។

២- ទោះបីនៅត្រង់ផ្លូវប្រសព្វ មានភ្លើងសញ្ញាចរាចរណ៍ពណ៌បៃតងដែលអនុញ្ញាតឲ្យធ្វើចរាចរណ៍ ទៅមុខបានក៏ដោយ ក៏អ្នកបើកបរមិនត្រូវបើកចូលទៅក្នុងផ្លូវប្រសព្វឡើយ ប្រសិនបើអំពើនេះ អាចតម្រូវឲ្យខ្លួនបញ្ឈប់យានជំនិះនៅក្នុងផ្លូវប្រសព្វដោយសារតែមានចរាចរណ៍ចង្អៀតខ្លាំង។ ក្នុងករណីបែបនេះ អ្នកបើកបរត្រូវឈប់នៅមុខផ្លូវប្រសព្វ ដើម្បីកុំឲ្យស្ទះចរាចរណ៍យានដែលមកពីទិសផ្សេងទៀត។

៣- នៅផ្លូវប្រសព្វដែលគ្មានសញ្ញាសិទ្ធិអាទិភាព អ្នកបើកបរត្រូវទុកសិទ្ធិឲ្យអ្នកបើកបរយានដែលមកពីស្តាំរបស់ខ្លួនទៅមុន។ ប៉ុន្តែក្នុងករណីផ្លូវប្រសព្វបែកជាបីដែលគ្មានសញ្ញាសិទ្ធិអាទិភាព អ្នកបើកបរយាននៅផ្លូវដែលចប់ត្រូវទុកសិទ្ធិឲ្យអ្នកបើកបរយាននៅលើផ្លូវបន្តទៅមុន។

៤- អ្នកបើកបរដែលទៅដល់រង្វង់មូល ទោះបីខ្លួនស្ថិតនៅលើផ្លូវប្រភេទណាក៏ដោយ ត្រូវផ្តល់ សិទ្ធិអាទិភាពឲ្យអ្នកបើកបរដែលស្ថិតនៅក្នុងទ្រូងផ្លូវឯកទិសក្រវាត់រង្វង់មូលដែលមានសញ្ញាបង្ហាញទិស ទៅមុន។

៥- នៅពេលទៅដល់ផ្លូវប្រសព្វដែលមានដាក់សញ្ញាសម្គាល់សិទ្ធិអាទិភាព អ្នកបើកបរត្រូវទុក ផ្លូវឲ្យយានជំនិះដែលស្ថិតនៅលើផ្លូវមានសិទ្ធិអាទិភាពធ្វើដំណើរទៅមុន ហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះ បានតែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

៦- នៅពេលទៅដល់ផ្លូវប្រសព្វដែលមានដាក់សញ្ញា "ឈប់" អ្នកបើកបរត្រូវឈប់ស្ងៀមនៅមុខគំនូសកាត់ទទឹងទ្រូងផ្លូវ ដើម្បីទុកឲ្យយានជំនិះនិងថ្មើរជើងដែលនៅលើផ្លូវមានសិទ្ធិធ្វើដំណើរទៅមុន ហើយអាចឆ្លងកាត់ផ្លូវប្រសព្វនោះបានតែនៅពេលណាដែលខ្លួនជឿជាក់ថាពុំមានគ្រោះថ្នាក់អ្វីឡើយ។

៧- ដោយឡែកអ្នកបើកបរត្រូវតែទុកឲ្យយានជំនិះបម្រើការរបស់នគរបាល យោធា កងរាជអាវុធហត្ថ យានពន្លត់អគ្គិភ័យ ឬយានសង្គ្រោះរបស់មន្ទីរពេទ្យដែលកំពុងបំពេញភារកិច្ចដោយឲ្យសញ្ញា សូរសព្ទនិងសញ្ញាភ្លើងពិសេសឲ្យដឹងពីការមកដល់របស់ខ្លួនទៅមុន។

៨- យានជំនិះដែលកំពុងបំពេញភារកិច្ចដូចខាងក្រោម មានសិទ្ធិអាទិភាពតាមលំដាប់ដូចតទៅៈ

- យានពន្លត់អគ្គិភ័យ
- យានសង្គ្រោះរបស់មន្ទីរពេទ្យ
- យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ។

៩- មុននឹងបើកបរចេញពីផ្លូវឯកជនដែលមិនបើកឲ្យធ្វើចរាចរណ៍ជាសាធារណៈ ដូចជាពីច្រកគេហដ្ឋាន រោងចក្រ អគារ ឬទីលានផ្សេងៗ អ្នកបើកបរត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត និងត្រូវទុកសិទ្ធិអាទិភាពឲ្យយានជំនិះឬថ្មើរជើងដែលកំពុងធ្វើចរាចរណ៍លើផ្លូវសាធារណៈទៅមុន។

១០- អ្នកបើកបរចេញមកពីផ្លូវលំ ឬផ្លូវដី ត្រូវទុកសិទ្ធិឲ្យអ្នកបើកបរលើផ្លូវផ្សេងទៀតដែលមិនមែនជាផ្លូវលំឬផ្លូវដីទៅមុន។

១១- នៅត្រង់ផ្លូវប្រសព្វ បើទ្រូងផ្លូវមួយមានចែកជាច្រើនគន្លងផ្លូវ ហើយមានគន្លងផ្លូវមួយឬ ច្រើនត្រូវបម្រុងសម្រាប់យានជំនិះប្រភេទខ្លះធ្វើចរាចរណ៍ បទប្បញ្ញត្តិស្តីពីអាទិភាពចរាចរណ៍ដែលមានចែងក្នុងមាត្រានេះ ត្រូវអនុវត្តចំពោះអ្នកបើកបរដែលធ្វើចរាចរណ៍នៅលើគន្លងផ្លូវប្រភេទនេះ លើកលែងតែយានជំនិះដែលមានចែងក្នុងចំណុចទី៧និងចំណុចទី៨ខាងលើនេះ។

**មាត្រា២២ .-**

ការបើកបរឆ្លងកាត់ផ្លូវរថភ្លើង៖

១- អ្នកបើកបរត្រូវបន្ថយល្បឿននៅពេលជិតដល់ផ្លូវរថភ្លើង។

២- នៅកន្លែងផ្លូវថ្នល់កាត់ផ្លូវរថភ្លើងដែលមានដាក់របារ ឬរបាំង អ្នកបើកបរមិនត្រូវបរចូលទៅទីនោះ នៅពេលដែលរបាំងនោះបិទ ឬកំពុងបិទ ឬកំពុងបើកឡើយ។

៣- នៅកន្លែងមានឆ្មាំនៅត្រង់ផ្លូវរថភ្លើងឆ្លងកាត់ អ្នកបើកបរត្រូវស្តាប់បញ្ជាឆ្មាំហើយមិនត្រូវបង្កឲ្យមានឧបសគ្គដល់ការបិទបើករបារ ឬរបាំងឡើយ។

៤- កាលណាមានរថភ្លើងមកជិតដល់ អ្នកប្រើប្រាស់ផ្លូវគ្រប់រូបត្រូវឈប់ជាបន្ទាន់ដើម្បីទុកផ្លូវឲ្យរថភ្លើងធ្វើចរាចរណ៍ទៅមុន។ គង្វាលសត្វទាំងអស់ត្រូវរកវិធីទប់ស្កាត់ហ្វូងសត្វពាហនៈ កុំឲ្យឆ្លងកាត់ ផ្លូវរថភ្លើងជាដាច់ខាត។

៥- កាលណារថភ្លើងបន្លឺសញ្ញាជិតមកដល់ អ្នកបើកបរគ្រប់រូបត្រូវឈប់យ៉ាងតិច២(ពីរ)ម៉ែត្រ ពីរបារឬរបាំង ហើយបើគ្មានរបារឬរបាំង ត្រូវឈប់យ៉ាងតិច៥(ប្រាំ)ម៉ែត្រពីផ្លូវរថភ្លើង។

៦- ក្នុងករណីដែលយានជំនិះតាំងដំណើរ ឬហ្វូងសត្វ ធ្វើដំណើរចូលមកជ្រុលទៅលើផ្លូវរថភ្លើង អ្នកបើកបរឬគង្វាលសត្វ ត្រូវរិះរកមធ្យោបាយកុំឲ្យមានកើតជាឧបសគ្គដល់រថភ្លើង ឬត្រូវឲ្យដំណឹងដល់ ភ្នាក់ងារទទួលខុសត្រូវផ្លូវរថភ្លើងដែលនៅជិតបំផុតអំពីគ្រោះថ្នាក់ដែលនឹងអាចកើតឡើងបាននោះប្រសិនបើខ្លួនមិនអាចបញ្ចៀសឧបសគ្គលើផ្លូវរថភ្លើងដោយខ្លួនឯងបាន។

**មាត្រា២៣ .-**

ការឈប់និងការចតនៅលើផ្លូវថ្នល់ ត្រូវអនុវត្តដូចខាងក្រោម៖

១- គ្រប់យានជំនិះដែលឈប់ឬចត មិនត្រូវបង្កឲ្យរំខានដល់យានជំនិះផ្សេងៗទៀតដែលកំពុងធ្វើចរាចរណ៍។

២- នៅក្នុងទីប្រជុំជន គ្រប់យានជំនិះត្រូវឈប់ឬចត នៅតាមទិសដែលខ្លួនកំពុងធ្វើចរាចរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម៖

- ចំពោះទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរ ត្រូវចតឬឈប់ខាងស្តាំតាមទិសចរាចរណ៍របស់ខ្លួន
- ចំពោះទ្រូងផ្លូវឯកទិស ត្រូវចតឬឈប់ខាងស្តាំឬខាងឆ្វេងតាមទិសចរាចរណ៍។

៣- នៅក្រៅទីប្រជុំជន យានជំនិះឬសត្វពាហនៈត្រូវឈប់ឬចតនៅក្រៅទ្រូងផ្លូវ។ បើគ្មានទីណាផ្សេងទៀត ដែលយានជំនិះអាចចតបានក្រៅពីទ្រូងផ្លូវទេនោះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ

ដែលមានចែងក្នុងចំណុចទី១ខាងលើនេះ។

៤- នៅក្រៅទីប្រជុំជន គ្រប់យានជំនិះដែលខូចគាំងឬត្រូវបង្ខំឲ្យឈប់ឬចតនៅលើថ្នល់ផ្លូវ ត្រូវប្រើភ្លើងសញ្ញាអាសន្នឬ/និងដាក់សញ្ញាត្រីកោណចម្ងាយយ៉ាងតិច៣០(សាមសិប)ម៉ែត្រ ដែលអាចមើលឃើញយ៉ាងតិច១០០(មួយរយ) ម៉ែត្រ។ ក្នុងករណីបញ្ហាខាងលើនេះកើតឡើងនៅកន្លែងហាមឈប់ឬចត ត្រូវជូនដំណឹងដល់សមត្ថកិច្ច ដែលនៅជិតដើម្បីមានវិធានការបន្ថែម។

៥- នៅក្នុងទីប្រជុំជន គ្រប់យានជំនិះត្រូវឈប់ឬចតដាក់ទំនិញឬមនុស្សឡើងចុះនៅចម្ងាយមិនលើសពី២៥(ម្ភៃប្រាំ)សង់ទីម៉ែត្រពីគែមចិញ្ចើមផ្លូវ និងយ៉ាងតិច៥(ប្រាំ)ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង និងចន្លោះយ៉ាងតិច១០(ដប់)ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោងនៃមហាវិថី។ នៅក្រៅទីប្រជុំជន យាន ទាំងអស់ត្រូវឈប់ឬចតយ៉ាងតិចបំផុត១០(ដប់)ម៉ែត្រពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង។

៦- ក្នុងការចត មុនពេលដើរឆ្ងាយពីយានជំនិះរបស់ខ្លួន អ្នកបើកបរត្រូវចាប់ហ្វ្រាំងដៃ ឬមានវិធាន ការផ្សេងៗ ដើម្បីការពារគ្រោះថ្នាក់ជាយថាហេតុ នៅពេលដែលខ្លួនអវត្តមាន។

៧- ហាមឈប់ឬចតយានជំនិះនៅទីកន្លែងដូចខាងក្រោម៖

- នៅលើថ្នល់ផ្លូវ ចិញ្ចើមផ្លូវដែលទុកបម្រុងឲ្យថ្មើរជើង និងក្នុងចន្លោះយ៉ាងតិច៥ (ប្រាំ)ម៉ែត្រពីមុខគំនូសឆ្នូតកាត់ទទឹងថ្នល់ផ្លូវសម្រាប់ថ្មើរជើង ឬនៅលើគំនូសនេះ
- នៅលើផ្លូវសម្រាប់ថ្មើរជើង
- លើកន្លែងបម្រុងទុកសម្រាប់ការឈប់ឬចតនៃយានប្រភេទខ្លះ
- នៅចន្លោះគែមថ្នល់ផ្លូវនិងខ្សែគំនូសបង្អួត ប្រសិនបើនៅចន្លោះខ្សែគំនូសបង្អួត និងយានចតនេះតិចជាង៣(បី)ម៉ែត្រ ដែលមិនអាចឲ្យយានមួយផ្សេងទៀតបរបានដោយឥតឆ្លងកាត់ឬជាន់លើខ្សែគំនូសបង្អួត
- នៅជិតបង្គោលភ្លើងសញ្ញាចរាចរណ៍ឬផ្លាកសញ្ញាចរាចរណ៍ ដែលធ្វើឲ្យបាំងភ្នែកអ្នកប្រើប្រាស់ផ្លូវមិនអាចមើលឃើញសញ្ញាចរាចរណ៍ទាំងនេះបាន
- នៅគ្រប់ទីកន្លែងដែលធ្វើឲ្យរាំងស្ទះដល់ច្រកចេញចូល ការចត ឬការឈប់នៃយានដទៃទៀត
- នៅលើស្ពាន លើផ្លូវក្រោមស្ពាន លើផ្លូវរូង លើផ្លូវប្រសព្វ លើផ្លូវកាត់ផ្លូវរថភ្លើង លើផ្លូវក្នុង រង្វង់មូល ផ្លូវកោងខ្លាំង ឬលើផ្លូវចោតខ្លាំង ដែលមិនអាចមើលយានផ្សេងទៀតពីចម្ងាយបាន
- នៅចន្លោះតិចជាង២០(ម្ភៃ)ម៉ែត្រពីផ្លូវរថភ្លើងឆ្លងកាត់
- នៅចន្លោះតិចជាង១០(ដប់)ម៉ែត្រពីមុខនិងពីក្រោយទីតាំងឬមទឹករបស់យានពន្លត់អគ្គិភ័យនិងនៅមុខស្ថានីយពន្លត់អគ្គិភ័យ
- លើច្រកចេញចូលនៃអគារសាធារណៈ

- នៅលើទ្រូងផ្លូវមុខច្រកចេញចូលផ្ទះឯកជន លើកលែងតែយានរបស់ម្ចាស់ផ្ទះដែលជាកម្មសិទ្ធិតែមួយ
- ជាពីរជួរទន្ទឹមគ្នា
- នៅលើតែមទ្រូងផ្លូវម្ខាងបើនៅតែមម្ខាងទៀតដែលឈមមុខគ្នាជាកន្លែងទុកសម្រាប់ឲ្យយានជំនិះចត លើកលែងតែក្នុងករណីដែលអាចចតបានទាំងសងខាង
- នៅកន្លែងដែលមានសញ្ញាហាមឈប់ឬហាមចត
- នៅលើទ្រូងផ្លូវថ្នល់លើសពី២៤ម៉ោង
- នៅចន្លោះតិចជាង១០(ដប់)ម៉ែត្រពីមុខ និងពីក្រោយផ្លាកសញ្ញាកន្លែងរបស់រថយន្តក្រុងឈប់
- នៅចន្លោះតិចជាង១(មួយ)ម៉ែត្រពីមុខឬពីក្រោយរថយន្ត ដែលឈប់ឬចតបន្តកន្ទុយគ្នា
- នៅជិតផ្លូវប្រសព្វឬផ្លូវបត់។

**មាត្រា២៤ .-**

ការបើកទ្វារយានជំនិះដើម្បីចុះឬឡើងត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសចំពោះការបើកទ្វារចុះ ឬឡើងនៅផ្នែកខាងឆ្វេងយាន។

**មាត្រា២៥ .-**

មុនពេលចេញដំណើរពីចំណត អ្នកបើកបរត្រូវឲ្យសញ្ញាយ៉ាងច្បាស់និងគ្រប់គ្រាន់ជាដំណឹងដល់អ្នកដទៃដែលកំពុងប្រើប្រាស់ផ្លូវនោះ ដោយត្រូវជឿជាក់ថាការចេញដំណើររបស់យានយន្តគ្មានបណ្តាល ឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃឡើយ។

មុនពេលផ្លាស់ប្តូរទិសដៅយានជំនិះដូចជា ការបត់ឆ្វេងឬបត់ស្តាំ ការប្តូរគន្លងផ្លូវ ការបត់ត្រឡប់ក្រោយឬថយក្រោយ ការអែបខាងដើម្បីឈប់ឬចត អ្នកបើកបរត្រូវបន្ថយល្បឿននិងឲ្យសញ្ញាយ៉ាងច្បាស់ និងគ្រប់គ្រាន់ជាដំណឹងដល់អ្នកដទៃដែលកំពុងប្រើប្រាស់ផ្លូវនោះ។

ក្នុងការបត់ឆ្វេងឬបត់ស្តាំ ការបត់ត្រឡប់ក្រោយឬថយក្រោយ អ្នកបើកបរត្រូវអនុវត្តតាមវិធានដូចខាងក្រោម៖

១- ការបត់ឆ្វេង

- មុននឹងធ្វើការបត់ឆ្វេង ត្រូវក្រឡេកមើលក្រោយតាមកញ្ចក់មើលក្រោយ ពិសេស តាមកញ្ចក់ខាងឆ្វេង ដើម្បីឲ្យដឹងទីតាំងនិងចលនាចរាចរណ៍នៅពីខាងក្រោយ
- ត្រូវធ្វើសញ្ញាប្តូរទិសទៅខាងឆ្វេងឲ្យបានចម្ងាយគ្រប់គ្រាន់ ពីកន្លែងដែលត្រូវបត់ និងបន្ថយល្បឿន ហើយបើគ្មានឧបសគ្គអ្វីទេ ត្រូវបើកអែបតំនូសបង្គតកណ្តាលទ្រូងផ្លូវ
- នៅពេលរៀបនឹងបត់ឆ្វេង ត្រូវមើលឆ្វេង ស្តាំ និងមើលឆ្វេងម្តងទៀត ពិសេសមើលចរាចរណ៍យានមកពីទិសផ្ទុយ។ បើផ្លូវទំនេរ ត្រូវបត់ដោយប្រុងប្រយ័ត្ន

ពិសេសចំពោះថ្មើរជើងដែលកំពុងឆ្លងកាត់។ បើផ្លូវមិនទំនេរ ត្រូវរង់ចាំដោយទុកឲ្យអ្នកបើកបរយានដែលមក ពីទិសផ្ទុយនិងមកពីទិសខាងស្ដាំទៅមុន

- ការបត់ឆ្វេងត្រូវធ្វើតាមបែបសៀរស្ដាំ គឺបត់ពីក្រោយយានមកពីទិសផ្ទុយ លើកលែងតែមានការណែនាំពីនគរបាលចរាចរណ៍។

២- ការបត់ស្ដាំ

- មុននឹងធ្វើការបត់ស្ដាំ ត្រូវក្រឡេកមើលតាមកញ្ចក់មើលក្រោយ ពិសេស តាមកញ្ចក់ខាងស្ដាំ ដើម្បីឲ្យដឹងទីតាំងនិងចលនាចរាចរណ៍យាននៅពីខាងក្រោយ
- បើគ្មានឧបសគ្គអ្វីទេ ត្រូវធ្វើសញ្ញាប្ដូរទិសខាងស្ដាំ ឲ្យបានចម្ងាយគ្រប់គ្រាន់ពីទីកន្លែងដែលត្រូវបត់ និងបន្ថយល្បឿន ហើយបើកអែបមកស្ដាំ
- នៅពេលរៀបនឹងបត់ស្ដាំ ត្រូវមើលឆ្វេងស្ដាំ ហើយត្រូវមើលក្រោយតាមកញ្ចក់ខាងស្ដាំម្ដងទៀត ជាពិសេសត្រូវជឿជាក់ថា គ្មានឧបសគ្គនៅខាងស្ដាំផ្នែកខាងក្រោយឡើយ។ បើទំនេរ ត្រូវបើកឲ្យកៀកស្ដាំបំផុតដែលអាចធ្វើទៅបាន និងត្រូវប្រុងប្រយ័ត្នចំពោះថ្មើរជើងដែលកំពុងឆ្លងកាត់។

៣- ការបត់ត្រឡប់ក្រោយនិងថយក្រោយ

- អ្នកបើកបរដែលមានបំណងបត់ត្រឡប់ក្រោយឬថយក្រោយ ត្រូវជឿជាក់ថាទង្វើនេះមិនធ្វើឲ្យរំខានខ្លាំង ឬបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀតឡើយ
- ចំពោះការបើកបរថយក្រោយ អ្នកបើកបរត្រូវប្រុងប្រយ័ត្ននិងក្រឡេកមើលចលនាចរាចរណ៍ ខាងក្រោយយានគ្រប់វិនាទី ពិសេស មុននឹងថយក្រោយ ត្រូវប្រុងប្រយ័ត្នមើលឲ្យបានសព្វជ្រុងជ្រោយចំពោះកុមារតូចឬសត្វតូចៗនៅខាងក្រោយ
- ហាមបត់ត្រឡប់ក្រោយ នៅក្នុងករណីដូចខាងក្រោម៖
    - នៅជិតផ្លូវប្រសព្វឬជិតផ្លូវរថភ្លើងឆ្លងកាត់
    - នៅត្រង់ផ្លូវកោងដែលអ្នកបើកបរមិនអាចមើលឃើញយានផ្សេងៗទៀតបានក្នុងចម្ងាយ១៥០(មួយរយហាសិប)ម៉ែត្រ
    - នៅជិតដល់កំពូលខ្ពស់និងនៅពេលចុះពីកំពូលខ្ពស់
    - នៅកន្លែងដែលមានសញ្ញាហាមបត់ត្រឡប់ក្រោយ
    - នៅលើទ្រូងផ្លូវឯកទិស។

វិធានខាងលើនេះ ត្រូវបានលើកលែង ពេលមានសញ្ញាបញ្ជារបស់នគរបាលចរាចរណ៍ផ្លូវគោក ឬគំនូសសញ្ញាចរាចរណ៍នៅលើទ្រូងផ្លូវ។

**មាត្រា២៦ ..**

នៅពេលមានថ្មើរជើងឆ្លងកាត់ អ្នកបើកបរត្រូវអនុវត្តដូចខាងក្រោម៖

១- គ្រប់ករណីទាំងអស់ អ្នកបើកបរត្រូវតែឈប់នៅពេលថ្មើរជើងកំពុងឆ្លងកាត់ឬរៀបនឹងឆ្លងកាត់នៅកន្លែងដែលមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

២- នៅត្រង់កន្លែងផ្លូវប្រសព្វឬនៅជិតកៀកផ្លូវប្រសព្វ អ្នកបើកបរត្រូវហាមឃាត់ក្នុង

ការធ្វើឲ្យអាក់ខានឬរាំងស្ទះដល់ថ្មើរជើងដែលកំពុងឆ្លងកាត់ទ្រូងផ្លូវ ទោះបីគ្មានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លង កាត់ក៏ដោយ។

៣- ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់នៅត្រង់ផ្លូវប្រសព្វ ដែលមានភ្លើងសញ្ញាចរាចរណ៍ ឬមានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ ទោះបីមានភ្លើងពណ៌បៃតង ឬមានបញ្ជាភ្នាក់ងារឲ្យទៅមុខក៏ដោយអ្នកបើកបរ មិនត្រូវធ្វើឲ្យរំខានឬធ្វើឲ្យរាំងស្ទះដល់ថ្មើរជើងដែលកំពុងឆ្លងកាត់នៅលើគំនូសសញ្ញាថ្មើរជើងឆ្លងកាត់ឡើយ។ ចំពោះអ្នកបើកបរដែលបត់ចូលទ្រូងផ្លូវផ្សេងទៀត ហើយនៅទ្រូង ផ្លូវនោះមានថ្មើរជើងកំពុងឆ្លងកាត់ អ្នកបើកបរត្រូវបន្ថយល្បឿន បើចាំបាច់ត្រូវឈប់ដើម្បីផ្តល់សិទ្ធិឲ្យថ្មើរជើងឆ្លងកាត់រួចរាល់សិន។

៤- ក្នុងករណីមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់នៅត្រង់ផ្លូវប្រសព្វ ដែលគ្មានភ្លើងសញ្ញាចរាចរណ៍ ឬគ្មានភ្នាក់ងារបញ្ជាចរាចរណ៍នៅទីនោះ អ្នកបើកបរត្រូវបន្ថយល្បឿន ឬត្រូវឈប់ដើម្បីផ្តល់សិទ្ធិឲ្យថ្មើរជើងដែលកំពុងឆ្លងកាត់ឬរៀបនឹងឆ្លងកាត់ទៅមុន។

## ជំពូកទី៤
## ការប្រើភ្លើងនិងសូរសព្ទយានជំនិះ

**មាត្រា២៧ ..**

នៅពេលយប់ឬពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់គ្រប់គ្រាន់ ដូចជានៅពេលភ្លៀងខ្លាំង ចុះអ័ព្ទ ឬឆ្លងកាត់ផ្លូវរូង អ្នកបើកបរយាននៅលើទ្រូងផ្លូវត្រូវប្រើប្រាស់ភ្លើងសញ្ញាតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងករណីកំពុងបើកបរយានយន្ត៖

ក- ភ្លើងហ្វា : នៅពេលយប់ នៅលើទ្រូងផ្លូវដែលគ្មានអគ្គិសនីបំភ្លឺ ជាទូទៅត្រូវប្រើភ្លើងហ្វាដើម្បី មើលទៅមុខឲ្យបានឆ្ងាយ តែត្រូវប្រុងប្រយ័ត្នកុំឲ្យរំខានដល់ចរាចរណ៍ដែលមកពីទិសផ្ទុយ។

ហាមបើកភ្លើងហ្វានៅក្នុងទីក្រុង ឬទីប្រជុំជន ដែលមានភ្លើងអគ្គិសនីបំភ្លឺគ្រប់គ្រាន់ លើកលែងតែករណីធ្វើសញ្ញាសុំជែង ឬសុំបើកផ្លូវដោយប្រើឆ្លាស់គ្នាជាមួយភ្លើងកូត។

ខ- ភ្លើងកូត : ត្រូវប្រើភ្លើងកូត ក្នុងករណីដូចខាងក្រោម៖

- នៅពេលយប់ នៅក្នុងទីប្រជុំជននិងក្រៅទីប្រជុំជនដែលមានភ្លើងអគ្គិសនីបំភ្លឺតាមផ្លូវ
- នៅពេលយប់ នៅក្រៅទីប្រជុំជនដែលគ្មានភ្លើងអគ្គិសនីបំភ្លឺតាមផ្លូវ ក្នុងករណីរៀបនឹង ជៀសយានមួយផ្សេងទៀត និងនៅពេលបើកបរពីក្រោយជិតយានជំនិះមួយទៀត
- នៅពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់គ្រប់គ្រាន់ដូចជានៅពេលភ្លៀងខ្លាំង ឬចុះអ័ព្ទ ឬឆ្លងកាត់ផ្លូវរូង

ភ្លើងកូតអាចប្រើប្រាស់ឆ្លាស់គ្នានឹងភ្លើងហ្វាធ្វើឲ្យមានពន្លឺភ្លឺបភ្លែតៗ ជាសញ្ញាជំនួសស៊ីផ្លេ នៅពេលយប់។

គ-ភ្លើងទីតាំង : នៅពេលយប់ក្នុងទីប្រជុំជន យានជំនិះទាំងឡាយដែលកំពុងបើកបរ យ៉ាងហោច ណាស់ក៏ត្រូវមានភ្លើងទីតាំងដែរ ដោយមិនបាច់ប្រើភ្លើងក្លូត ប្រសិនបើទ្រូងផ្លូវមានពន្លឺភ្លើងអគ្គិសនី គ្រប់គ្រាន់។ ភ្លើងទីតាំងនេះប្រើប្រាស់សម្រាប់ប្រាប់វត្តមានយាននិងទំហំយានដល់អ្នកប្រើប្រាស់ផ្លូវដែល មើលពីមុខ។

ឃ- ភ្លើងផ្សេងៗ : នៅពេលយប់ឬនៅពេលថ្ងៃដែលមានអាកាសធាតុមិនល្អ មិនអាចមើលទៅ មុខឃើញច្បាស់ អ្នកបើកបរត្រូវប្រើ៖

- ភ្លើងក្រហម : សម្រាប់ប្រាប់វត្តមាននៃយានជំនិះនិងទំហំទទឹងយានដល់អ្នកប្រើប្រាស់ផ្លូវ ដែលមើលពីក្រោយ
- ភ្លើងបំភ្លឺផ្លាកលេខ : សម្រាប់ឲ្យគេមើលលេខសម្គាល់យានជំនិះឃើញច្បាស់ពីខាងក្រោយ
- ភ្លើងទទឹងយាន : បង្ហាញទំហំទទឹងយានឬបន្ទុកច្រងេងច្រងាងដល់អ្នកប្រើប្រាស់ផ្លូវផ្សេង ទៀត
- ភ្លើងសញ្ញាប្តូរទិស : សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត នៅពេលប្តូរទិស ទៅឆ្វេងឬទៅស្តាំ
- ភ្លើងសញ្ញាថយក្រោយ : សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវនៅខាងក្រោយយាន នៅពេលធ្វើចលនាថយក្រោយ
- ភ្លើងស្តុប : សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវខាងក្រោយយាននៅពេលជាន់ឬ ចាប់ហ្វ្រាំង ដើម្បីបន្ថយល្បឿនឬបញ្ឈប់យាន
- ភ្លើងសញ្ញាអាសន្ន : សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀតអំពីគ្រោះថ្នាក់ ដែលអាចកើតមានឡើង ដូចជានៅពេលអ្នកបើកបរត្រូវបង្ខំចិត្តបើកបរក្នុងល្បឿនយឺត ដោយមូលហេតុអូសសណ្តោងរថយន្តខូចឬផ្ទុកវត្ថុច្រងេងច្រងាង និងនៅពេលឈប់ឬចតលើទ្រូងផ្លូវក្រៅទីប្រជុំជន ដោយមូលហេតុយានខូច ឬជាប់ទាក់ទងនឹងគ្រោះថ្នាក់ ឬធ្លាក់ទំនិញមិនអាចលើកវិញបានភ្លាមៗ
- ភ្លើងចុះអ័ព្ទ : សម្រាប់ប្រើនៅពេលចុះអ័ព្ទឬភ្លៀងខ្លាំង។ ភ្លើងចុះអ័ព្ទអាចប្រើជំនួសភ្លើងក្លូត ឬអាចប្រើបន្ថែមលើភ្លើងក្លូតបាន
- ភ្លើងពេលថ្ងៃ : សម្រាប់ប្រើប្រាស់នៅពេលថ្ងៃ។ យានយន្តគ្រប់ប្រភេទអាចប្រើប្រាស់ភ្លើង នេះបានដើម្បីឲ្យយានជំនិះផ្សេងទៀតងាយស្រួលមើលឃើញ។

២- ក្នុងករណីកំពុងបើកបរយានដែលមិនមែនជាយានយន្ត អ្នកបើកបរយានប្រភេទដូចខាងក្រោម ត្រូវអនុវត្តដូចតទៅ៖

- រទេះអូសទាញដោយមនុស្ស ត្រូវមានភ្លើងឬកញ្ចក់ចាំងពន្លឺពណ៌សឬលឿងដាក់នៅខាងមុខ និងភ្លើងឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមមួយដាក់នៅខាងក្រោយ។ ភ្លើងទាំងពីរនេះ ដាក់នៅជ្រុងរទេះឈមនឹងទ្រូងផ្លូវ
- រទេះអូសទាញដោយសត្វ ត្រូវមានភ្លើងឬកញ្ចក់ចាំងពន្លឺពណ៌សឬលឿងពីរដាក់នៅខាងមុខជ្រុងរទេះសងខាង និងត្រូវមានភ្លើង ឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមពីរ

ដាក់នៅខាងក្រោយ ជ្រុងរទេះសងខាង

- ទោចក្រយាននិងត្រីចក្រយាន ត្រូវមានភ្លើងឬកញ្ចក់ចាំងពន្លឺពណ៌សយ៉ាងតិចមួយនៅខាងមុខ និងត្រូវមានភ្លើងឬកញ្ចក់ចាំងពន្លឺពណ៌ក្រហមយ៉ាងតិចមួយនៅខាងក្រោយ
- រ៉ឺម៉កសណ្តោងដោយទោចក្រយានយន្តឬដោយកង់ ត្រូវមានកញ្ចក់ចាំងពន្លឺឬភ្លើងពណ៌ក្រហម ពីរដាក់នៅខាងក្រោយជ្រុងរ៉ឺម៉កសងខាង

៣- ក្នុងករណីឈប់ឬចត យានយន្តនៅលើទ្រូងផ្លូវដែលគ្មានភ្លើងអគ្គិសនីសាធារណៈបំភ្លឺ ត្រូវប្រើ៖

- ភ្លើងទីតាំង : សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដែលមកពីខាងមុខឲ្យដឹងពីវត្តមានយាន និងទំហំទទឹងយាន
- ភ្លើងក្រហម : សម្រាប់ប្រាប់ដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដែលមកពីខាងក្រោយឲ្យដឹងពីវត្តមានយាននិងទំហំទទឹងយាន
- ភ្លើងបំភ្លឺផ្លាកលេខ : សម្រាប់ឲ្យគេមើលលេខសម្គាល់យានជំនិះ ឃើញច្បាស់ពីខាងក្រោយ។

នៅទីប្រជុំជន ការប្រើប្រាស់ភ្លើងសញ្ញាដែលបានចែងក្នុងចំណុច៣នេះ មិនចាំបាច់ប្រើប្រាស់ទេ បើមានភ្លើងអគ្គិសនីបំភ្លឺ ហើយមានពន្លឺគ្រប់គ្រាន់អាចឲ្យអ្នកប្រើប្រាស់ផ្លូវមើលយានបានច្បាស់ពីចម្ងាយយ៉ាងតិច២០(ម្ភៃ)ម៉ែត្រ។

៤-ក្នុងករណីចតរ៉ឺម៉កឬសឺមីរ៉ឺម៉កដែលផ្តាច់ចេញពីរថយន្ត ត្រូវចតអែបចិញ្ចើមផ្លូវឬជាយផ្លូវហើយ ត្រូវប្រើភ្លើងសឬលឿងមួយនៅខាងមុខ និងភ្លើងក្រហមមួយនៅខាងក្រោយ។ ភ្លើងនីមួយៗត្រូវដាក់នៅជ្រុងនៃយាន "ជ្រុងរ៉ឺម៉ក" ដែលឈមមុខទៅនឹងទ្រូងផ្លូវ ដែលរ៉ឺម៉កឬសឺមីរ៉ឺម៉កតម្រៀបគ្នាតាមបណ្តោយនោះ។ នៅក្នុងទីប្រជុំជន ការប្រើប្រាស់ភ្លើងនេះមិនចាំបាច់ទេ ប្រសិនបើមានភ្លើងអគ្គិសនីបំភ្លឺតាមទ្រូងផ្លូវដែលមានពន្លឺគ្រប់គ្រាន់អាចឲ្យអ្នកប្រើប្រាស់ផ្លូវមើលឃើញយានជំនិះដែលចតនៅលើទ្រូងផ្លូវពីចម្ងាយយ៉ាងតិច១០០(មួយរយ)ម៉ែត្រ។

៥-ក្នុងករណីដែលយានជំនិះត្រូវបង្ខំឲ្យឈប់ ឬចតនៅលើទ្រូងផ្លូវ ដែលអាចបង្កជាឧបសគ្គឬគ្រោះថ្នាក់ចរាចរណ៍ ដូចជានៅជិតផ្លូវប្រសព្វ ផ្លូវបត់ ផ្លូវកោង ផ្លូវចុះទួល និងផ្លូវរថភ្លើងឆ្លងកាត់ ដោយមូល ហេតុយានខូចគាំងឬជាប់ទាក់ទិននឹងគ្រោះថ្នាក់ចរាចរណ៍ ហើយមិនអាចរំកិលយានចេញពីទ្រូងផ្លូវបាន នោះ អ្នកបើកបរត្រូវប្រាប់ដំណឹងអំពីឧបសគ្គដល់អ្នកបើកបរផ្សេងទៀតដោយប្រើភ្លើងសញ្ញាអាសន្ន ឬ/និងដាក់សញ្ញាត្រីកោណយ៉ាងតិចចម្ងាយ៣០(សាមសិប)ម៉ែត្រពីខាងក្រោយយាន ដែលអាចមើលឃើញក្នុងចម្ងាយយ៉ាងតិច១០០(មួយរយ)ម៉ែត្រ។ ក្នុងករណីដែលយានមានទំនិញធ្លាក់លើទ្រូងផ្លូវហើយមិនអាចលើកទំនិញបានភ្លាមៗនោះ ត្រូវធ្វើសញ្ញាប្រាប់ដំណឹងដល់អ្នកបើកបរផ្សេងទៀត ដោយប្រើសញ្ញាត្រីកោណ និងភ្លើងសញ្ញាអាសន្នព្រមគ្នា ឬយ៉ាងហោចណាស់ក៏ប្រើសញ្ញាត្រីកោណមួយនៅចម្ងាយយ៉ាងតិច៣០(សាមសិប)ម៉ែត្រពីទំនិញនោះ។

៦-ភ្លើងសញ្ញាពិសេសអាចប្រើបានគ្រប់ពេលវេលា ក្នុងពេលកំពុងបំពេញភារកិច្ចចំពោះ

យានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ។

**មាត្រា២៨ ._**

ការប្រើប្រាស់សូរសព្ទយានជំនិះ ត្រូវអនុវត្តដូចខាងក្រោម៖

១- ការប្រើប្រាស់សញ្ញាសូរសព្ទ "ស៊ីផ្លេ" ត្រូវអនុញ្ញាតឲ្យប្រើប្រាស់តែនៅពេលថ្ងៃ ដើម្បីឲ្យដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀត ជៀសវាងនូវគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុនិង ដើម្បីសុំជែងនៅក្រៅទីប្រជុំជន។

២- នៅពេលយប់សញ្ញាសូរសព្ទស៊ីផ្លេ ត្រូវជំនួសដោយសញ្ញាភ្លើងហ្វាភ្លឹតឆ្លាស់គ្នាសម្រាប់ឲ្យដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀតដើម្បីជៀសវាងនូវគ្រោះថ្នាក់និងសុំជែង។

៣- សញ្ញាសូរសព្ទពិសេសអាចប្រើបានគ្រប់ពេលវេលា ក្នុងពេលកំពុងបំពេញភារកិច្ចចំពោះ យានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ។

៤- សញ្ញាសូរសព្ទ ត្រូវប្រើក្នុងរយៈពេលខ្លី គឺមិនយូរជាងការចាំបាច់ឡើយលើកលែងតែមានការប្រកាសអាសន្ន។

៥- សញ្ញាសូរសព្ទស៊ីផ្លេខ្យល់ត្រូវហាមប្រើនៅក្នុងទីក្រុង ទីប្រជុំជន ឬនៅជិតមន្ទីរពេទ្យ។

**មាត្រា២៩ ._**

ការប្រើភ្លើងសញ្ញាពិសេសនិងសូរសព្ទពិសេសត្រូវអនុវត្តដូចខាងក្រោម៖

១- ភ្លើងសញ្ញាពិសេស គឺជាភ្លើងបន្ថែមមានជះពន្លឺផ្លេកបន្ទោរភ្លឹបភ្លែតៗវិលជុំវិញនិងមានច្រើនពណ៌ ដែលមានអត្ថន័យដូចខាងក្រោម៖

ក- ភ្លើងសញ្ញាពិសេសពណ៌ខៀវឬក្រហម ត្រូវប្រើសម្រាប់តែយានដែលមានសិទ្ធិអាទិភាព ដូចជាយានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ នៅពេលកំពុងបំពេញភារកិច្ច ដើម្បីឲ្យដំណឹងពីវត្តមានយានដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត។

ខ- ភ្លើងសញ្ញាពិសេសពណ៌លឿងទុំ ត្រូវប្រើសម្រាប់តែយានបម្រើការងារសាធារណៈ ដូចជា យានលាងសម្អាតផ្លូវ យានថែទាំជួសជុលផ្លូវ និងយានដឹកជញ្ជូនពិសេសដែលបំពាក់ភ្លើងសញ្ញាពិសេស នេះ ហើយត្រូវបើកបរក្នុងល្បឿនយឺត។

២- សញ្ញាសូរសព្ទពិសេស គឺជាសញ្ញាសូរសព្ទបន្ថែមដែលប្រើប្រាស់សម្រាប់យានមានសិទ្ធិអាទិភាព ដូចជាយានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ ដែលមានបន្ថែមសំឡេងស៊ីរ៉ែនពេទ៍។ ចំណែកឯយានសង្គ្រោះបន្ទាន់សម្រាប់មន្ទីរពេទ្យមានបន្ថែមសំឡេង ពេទ៍ពីរដងឡើងចុះៗ។

៣- នៅពេលជួបយាន ដែលបញ្ចេញភ្លើងសញ្ញាពិសេសពណ៌លឿងទុំកំពុងបំពេញភារកិច្ចអ្នកបើកបរត្រូវប្រុងប្រយ័ត្នក្នុងការជៀសនិងជែងយានទាំងនេះ។

៤- នៅពេលជួបយានមានសិទ្ធិអាទិភាព កំពុងបំពេញភារកិច្ចដោយប្រើភ្លើងសញ្ញាពិសេសនិង សញ្ញាសូរសព្ទពិសេស អ្នកប្រើប្រាស់ផ្លូវដទៃទៀត ត្រូវបន្ថយល្បឿនអែបខាងស្តាំ ឬឈប់ដើម្បីទុកឲ្យយាន ទាំងនេះជែងជៀស ឬឆ្លងកាត់ដោយងាយស្រួល។

ដោយឡែកនៅពេលកំពុងបំពេញភារកិច្ច យានមានសិទ្ធិអាទិភាពដូចជាយានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ យាននគរបាល យោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាននគរបាលចរាចរណ៍ផ្លូវគោកនាំមុខ អាចបើកបរ៖

- បញ្ច្រាសទិសនៅលើផ្លូវឯកទិស
- នៅពេលភ្លើងសញ្ញាចរាចរណ៍ បញ្ចេញពន្លឺពណ៌ក្រហម
- ក្នុងល្បឿនមិនកំណត់
- ដោយមានសិទ្ធិអាទិភាពលើផ្លូវប្រសព្វ
- កាត់ឬជាន់ខ្សែគំនូសបង្ខាតជាប់។

ទោះបីក្នុងករណីណាក៏ដោយ អ្នកបើកបរយានប្រភេទនេះត្រូវបើកបរដោយប្រុងប្រយ័ត្នជានិច្ច ដើម្បីជៀសវាងគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត និងត្រូវគោរពសញ្ញាបញ្ជាដោយភ្នាក់ងារចរាចរណ៍ ជាដាច់ខាត។

**មាត្រា៣០ ..**

ការបំពាក់សញ្ញាសូរសព្ទ ភ្លើងបំភ្លឺ ឬភ្លើងលំអផ្សេងៗទៀត ក្រៅពីការកំណត់លក្ខណៈបច្ចេកទេស របស់យានជំនិះត្រូវហាមឃាត់។

## ជំពូកទី៥
## ថ្មើរជើង និងអ្នកជិះឬអ្នកដឹកសត្វ

**មាត្រា៣១ ..**

ថ្មើរជើងនិងអ្នកអូសឬអ្នករុញរទេះដៃ ត្រូវគោរពភ្លើងសញ្ញាចរាចរណ៍ ផ្លាកសញ្ញាចរាចរណ៍ ឬសញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍។

ថ្មើរជើងនិងអ្នកអូសឬអ្នករុញរទេះដៃ ត្រូវអនុវត្តដូចខាងក្រោម៖

១- ហាមប្រើប្រាស់ទ្រូងផ្លូវ បើនៅសងខាងទ្រូងផ្លូវមានចិញ្ចើមផ្លូវឬជាយផ្លូវដែលជាកន្លែងបម្រុងទុកឲ្យថ្មើរជើងទៅមក។

២- អនុញ្ញាតឲ្យប្រើប្រាស់ទ្រូងផ្លូវ បើចិញ្ចើមផ្លូវឬជាយផ្លូវគ្មានលទ្ធភាពឲ្យថ្មើរជើងប្រើប្រាស់បាន ហើយត្រូវដើរឲ្យកៀកជិតចិញ្ចើមផ្លូវតាមទិសចរាចរណ៍។

៣- ត្រូវឆ្លងកាត់តាមគំនូសសញ្ញា ប្រសិនបើមានគំនូសសញ្ញានៅជិតនោះ។

៤- នៅកន្លែងដែលមានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់៖

- ថ្មើរជើងត្រូវគោរពតាមបញ្ជាភ្នាក់ងារចរាចរណ៍ ឬតាមសញ្ញាភ្លើងសញ្ញាចរាចរណ៍

- នៅកន្លែងដែលគ្មានភ្លើងសញ្ញាចរាចរណ៍ ឬគ្មានភ្នាក់ងារចរាចរណ៍បញ្ជាទេ ថ្មើរជើងត្រូវមានការប្រុងប្រយ័ត្នមុននឹងឆ្លងកាត់ទ្រូងផ្លូវ។

៥- នៅកន្លែងដែលគ្មានគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់៖

- ថ្មើរជើងមុននឹងឆ្លងកាត់ទ្រូងផ្លូវ ត្រូវជឿជាក់ថាទង្វើនេះអាចធ្វើទៅបានដោយគ្មានការរំខានចរាចរណ៍យាន ឬធ្វើឲ្យមានគ្រោះថ្នាក់អ្វីឡើយ
- នៅពេលឆ្លងកាត់ទ្រូងផ្លូវ ហាមថ្មើរជើងឆ្លងកាត់កន្លែងប្រសព្វនៃទ្រូងផ្លូវ តែថ្មើរជើងត្រូវឆ្លងកាត់តាមបន្ទាត់កែងនៃអ័ក្សទ្រូងផ្លូវ និងហាមបង្អែបង្អង់ ឬឈប់ នៅលើទ្រូងផ្លូវបើគ្មានការចាំបាច់។

៦- ហាមកុមារអាយុតិចជាង៦(ប្រាំមួយ)ឆ្នាំ ដើររហេតរហូតលើផ្លូវថ្នល់។

៧- ចំពោះជនងងឹតភ្នែកទាំងពីរដែលធ្វើដំណើរលើផ្លូវថ្នល់ និងឆ្លងកាត់ផ្លូវថ្នល់ ត្រូវមានមនុស្ស ឬសត្វ ឬឧបករណ៍សម្រាប់នាំផ្លូវ។

**មាត្រា៣២ ..**

ក្បួនដង្ហែផ្សេងៗនិងការប្រើប្រាស់ផ្លូវសម្រាប់គោលបំណងផ្សេងទៀត ដែលមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវគោរពតាមការណែនាំដូចខាងក្រោម៖

ក- ក្បួនដង្ហែផ្សេងៗ៖

- ត្រូវហែនៅអែបទ្រូងផ្លូវខាងស្តាំតាមទិសចរាចរណ៍ ហើយត្រូវទុកទ្រូងផ្លូវផ្នែកខាងឆ្វេងឲ្យនៅទំនេរទាំងស្រុង
- អាចដើរហែក្បួនជាពីរ បី ឬបួនជួរបាន ដោយប្រមាណដល់ទទឹងទ្រូងផ្លូវ ហើយត្រូវគោរពបទបញ្ជាចរាចរណ៍
- ត្រូវកាន់ភ្លើងពណ៌សនៅខាងមុខ និងត្រូវកាន់ភ្លើងពណ៌ក្រហមនៅខាងក្រោយនៅពេលយប់ ឬពេលថ្ងៃកាលណាមើលមិនឃើញច្បាស់គ្រប់គ្រាន់។

ខ- ការប្រើប្រាស់ផ្លូវសម្រាប់គោលបំណងផ្សេងទៀតតាមការចាំបាច់ អាចអនុញ្ញាតឲ្យបានតាមការកំណត់នៃប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

**មាត្រា៣៣ ..**

អ្នកជិះ អ្នកដឹក ឬអ្នកបរសត្វ ត្រូវអនុវត្តដូចខាងក្រោម៖

១- មិនត្រូវបង្កឲ្យមានឧបសគ្គឬគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ដោយត្រូវដាក់ ចំនួនមនុស្សដឹកឲ្យសមស្របនឹងចំនួនសត្វដែលអាចបញ្ជាសត្វឲ្យទៅឬឈប់បានគ្រប់គ្រាន់និងទាន់ពេលវេលា។

២- នៅពេលយប់ឬពេលថ្ងៃ កាលណាមើលមិនឃើញច្បាស់ ត្រូវប្រើភ្លើងពណ៌សនៅខាងមុខ និងភ្លើងពណ៌ក្រហមនៅខាងក្រោយ។

៣- នៅពេលឈប់នៅលើទ្រូងផ្លូវ មិនត្រូវបង្កឲ្យរំខានដល់យានជំនិះផ្សេងៗទៀតដែលកំពុងធ្វើចរាចរណ៍។

៤- នៅក្នុងទីប្រជុំជន អ្នកជិះ អ្នកដឹក ឬអ្នកបរសត្វនៅលើទ្រូងផ្លូវ ត្រូវឈប់នៅតាមទិសដែល ខ្លួនកំពុងធ្វើចរាចរណ៍ ដោយអនុវត្តដូចខាងក្រោម៖

- ចំពោះទ្រូងផ្លូវដែលមានទិសចរាចរណ៍ពីរ ត្រូវឈប់ខាងស្តាំតាមទិសចរាចរណ៍របស់ខ្លួន
- ចំពោះទ្រូងផ្លូវឯកទិស ត្រូវឈប់ខាងស្តាំឬខាងឆ្វេងតាមទិសចរាចរណ៍លើកលែងតែមាន ផ្លាកសញ្ញាហាមឃាត់។

៥- ហាមលែងសត្វឲ្យដើររហេតរហូតលើផ្លូវ។

## ជំពូកទី៦
## ករណីមានគ្រោះថ្នាក់ចរាចរណ៍

**មាត្រា៣៤ ._**

គ្រប់ករណីគ្រោះថ្នាក់ចរាចរណ៍ ជាសមត្ថកិច្ចរបស់នគរបាលចរាចរណ៍ផ្លូវគោក។ នៅរាល់ករណី គ្រោះថ្នាក់ចរាចរណ៍ នគរបាលចរាចរណ៍ផ្លូវគោកត្រូវខិតខំឲ្យអស់សមត្ថភាពដើម្បី៖

១- រក្សាសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងកើតហេតុ។

២- ចាត់វិធានការសង្គ្រោះជនរងគ្រោះជាបន្ទាន់។

៣- រក្សាសន្តិសុខឲ្យដល់គ្រប់ភាគីពាក់ព័ន្ធ ទប់ស្កាត់ជម្លោះដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍។

៤- ចាត់វិធានការជំនាញ ប្រមូលភស្តុតាង និងព័ត៌មានដើម្បីធ្វើកំណត់ហេតុស្តីពីគ្រោះថ្នាក់ចរាចរណ៍។

**មាត្រា៣៥ ._**

ក្នុងករណីមានគ្រោះថ្នាក់ចរាចរណ៍ ភាគីពាក់ព័ន្ធនឹងគ្រោះថ្នាក់ ត្រូវអនុវត្តដូចខាងក្រោម៖

១- បញ្ឈប់យានរបស់ខ្លួនជាបន្ទាន់ ដោយមិនធ្វើឲ្យរំខានឬបង្កឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃទៀត។

២- មិនត្រូវធ្វើឲ្យមានការប្រែប្រួលដល់ទីកន្លែងកើតហេតុ ឬឲ្យបាត់ដានឬស្នាម ដែលជាកត្តា មានប្រយោជន៍ដល់ការស្វែងរកអ្នកទទួលខុសត្រូវក្នុងរឿងគ្រោះថ្នាក់។

៣- ជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរដែនដីឬនគរបាលចរាចរណ៍ផ្លូវគោកនៅជិតបំផុត។

៤- មិនត្រូវប្រើហិង្សាឬបង្កជម្លោះរវាងភាគីពាក់ព័ន្ធ។

៥- មិនត្រូវចាកចេញពីកន្លែងកើតហេតុមុនការព្រមព្រៀងគ្នា ឬដោយគ្មានការអនុញ្ញាតពីនគរបាលចរាចរណ៍ផ្លូវគោក។

ចំពោះអ្នកឃើញហេតុការណ៍ ត្រូវជូនដំណឹងជាបន្ទាន់ទៅអាជ្ញាធរដែនដីឬនគរបាលចរាចរណ៍ ផ្លូវគោកនៅជិតបំផុត។

**មាត្រា៣៦ ._**

បើគ្រោះថ្នាក់កើតឡើងបណ្តាលឲ្យខូចខាតតែទ្រព្យសម្បត្តិ ភាគីទាំងពីរអាចសម្រួលគ្នាបានដោយមិនចាំបាច់សុំអន្តរាគមន៍ពីមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកឡើយ។

**មាត្រា៣៧ ..**

ក្នុងករណីមានមនុស្សរងរបួសឬបាត់បង់ជីវិត អ្នកបើកបរ ឬអ្នកប្រើប្រាស់ផ្លូវគ្រប់រូបដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ ឬអ្នកឃើញហេតុការណ៍នេះ ត្រូវចាត់ចែងជូនព័ត៌មានទៅអាជ្ញាធរដែនដីឬនគរបាលចរាចរណ៍ផ្លូវគោក ឬបញ្ជូនជនរងគ្រោះជាបន្ទាន់ទៅមន្ទីរពេទ្យដែលនៅជិតកន្លែងកើតហេតុបំផុត។

**មាត្រា៣៨ ..**

ចំពោះគ្រោះថ្នាក់ចរាចរណ៍ដែលភាគីម្ខាងជាភ្នាក់ងារទូតឬបេសកកម្មទូត នគរបាលចរាចរណ៍ផ្លូវគោក ត្រូវចម្លងកំណត់ហេតុ និងធ្វើរបាយការណ៍ស្តីពីគ្រោះថ្នាក់នេះ ផ្ញើទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់ចែងឲ្យអ្នកតំណាងមកចូលរួមសហការជាមួយនគរបាលចរាចរណ៍ ផ្លូវគោកដើម្បីពិនិត្យនិងលើកវិធានការសមស្រប។

## ជំពូកទី៧
## ការគ្រប់គ្រងយាននិងការដឹកជញ្ជូន

**មាត្រា៣៩ ..**

បណ្ណបើកបរជាតិនិងបណ្ណបើកបរអន្តរជាតិ សម្រាប់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន លើកលែងតែបណ្ណបើកបរសម្រាប់អ្នកបើកបរយានយន្តយោធា និងនគរបាលគ្រប់ប្រភេទ ជាពិសេស សម្រាប់បម្រើជំនាញដូចជា រថក្រោះ រថពាសដែក រថយន្តបំពាក់យុទ្ធោបករណ៍ យានយន្តប្រដេញ ម៉ូតូកង់បី ម៉ូតូហែហម ដែលជាទ្រព្យសម្បត្តិរដ្ឋ ក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃឬក្រសួងការពារជាតិ ដែលត្រូវចេញដោយក្រសួងសាមី។

នីតិវិធីនៃការចេញបណ្ណបើកបរអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវផ្តល់បញ្ជីស្ថិតិអ្នកមានបណ្ណបើកបរមកក្រសួងមហាផ្ទៃមួយ ខែម្តង។

**មាត្រា៤០ .. ថ្មី**

បណ្ណបើកបរជាតិសម្រាប់បើកបរយានយន្តក្នុងព្រះរាជាណាចក្រកម្ពុជា មាន៥(ប្រាំ) ប្រភេទ ដូចខាងក្រោម៖

**ប្រភេទក** : ទោចក្រយានយន្ត ដែលមានទំហំស៊ីឡាំងលើសពី១២៥(មួយរយម្ភៃប្រាំ)សង់ទីម៉ែត្រគូប ឬមានថាមពលអគ្គិសនីលើសពី១១(ដប់មួយ)គីឡូវ៉ាត់ ទោចក្រយានយន្តសណ្តោងរ៉ឺម៉កនិងត្រីចក្រយានយន្ត។

**ប្រភេទខ** : រថយន្តដឹកអ្នកដំណើរមិនលើសពី៩(ប្រាំបួន)នាក់ ដោយគិតទាំងអ្នកបើកបរ
- រថយន្តដឹកទំនិញ ដែលមានទម្ងន់សរុបអតិបរមាមិនលើសពី៣,៥(បីក្បៀសប្រាំ)តោន

- រថយន្តក្នុងប្រភេទ**ខ**នេះ អាចសណ្តោងរ៉ឺម៉ឺកដែលមានទម្ងន់សរុបអតិបរមាមិនលើសពី០,៧៥(សូន្យក្បៀសចិតសិបប្រាំ)តោន។

**ប្រភេទគ** : រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី៣,៥(បីក្បៀសប្រាំ)តោន និងអាចសណ្តោងរ៉ឺម៉ឺកដែលមានទម្ងន់សរុបអតិបរមាមិនលើសពី០,៧៥(សូន្យក្បៀសចិតសិបប្រាំ)តោន។

**ប្រភេទឃ** : រថយន្តដឹកអ្នកដំណើរ៖

**ឃ១**: រថយន្តដឹកអ្នកដំណើរចាប់ពី១០(ដប់)នាក់ ដល់២០(ម្ភៃ)នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉ឺកដែលមានទម្ងន់សរុបអតិបរមាមិនលើសពី០,៧៥(សូន្យក្បៀសចិតសិបប្រាំ)តោន។

**ឃ២**: រថយន្តដឹកអ្នកដំណើរលើសពី២០(ម្ភៃ)នាក់ ដោយគិតទាំងអ្នកបើកបរនិងអាចមានសណ្តោងរ៉ឺម៉ឺក ដែលមានទម្ងន់សរុបអតិបរមាមិនលើសពី០,៧៥(សូន្យក្បៀសចិតសិបប្រាំ)តោន។

**ប្រភេទង** : រថយន្តប្រភេទ**ខ គ** និង**ឃ** មានសណ្តោងរ៉ឺម៉ឺកដែលមានទម្ងន់សរុបអតិបរមាលើសពី០,៧៥(សូន្យក្បៀសចិតសិបប្រាំ)តោន ត្រូវចែកជាបីប្រភេទ គឺប្រភេទ**ង**(**ខ**) ប្រភេទ**ង**(**គ**) និងប្រភេទ**ង**(**ឃ**)។

**មាត្រា៤១ .. ថ្មី**

លក្ខខណ្ឌផ្សេងៗទាក់ទងនឹងបណ្ណបើកបរ ត្រូវកំណត់ដូចខាងក្រោម៖

១- អ្នកបើកបរម្នាក់មានសិទ្ធិកាន់បណ្ណបើកបរតែមួយគត់។ បែបបទ នីតិវិធី សិទ្ធិ នៃការចេញបណ្ណបើកបរនិងបណ្ណពិន្ទុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

២- ជនពិការមានសិទ្ធិបើកបរយានយន្តពិសេសសម្រាប់តែជនពិការ និងលក្ខខណ្ឌនៃការចេញបណ្ណបើកបរសម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងពាក់ព័ន្ធ។

៣- អាយុអ្នកបើកបរត្រូវកំណត់តាមប្រភេទបណ្ណបើកបរ ដូចខាងក្រោម៖

- អាយុ១៨(ដប់ប្រាំបី)ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ**ក**និង**ខ**
- អាយុ២២(ម្ភៃពីរ)ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ**គ**និង**ឃ១**
- អាយុ២៤(ម្ភៃបួន)ឆ្នាំ យ៉ាងតិច ចំពោះប្រភេទ**ឃ២**និង**ង**។

៤- អ្នកមានបណ្ណបើកបរប្រភេទ**ខ**អាចបើកបរយានយន្តកសិកម្ម ឬយានយន្តបករណ៍ដែលមានល្បឿនអតិបរមាមិនលើសពី៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង តែមិនអាចបើកបរយានយន្តប្រភេទផ្សេងទៀតបានទេ។

៥- ចំពោះអ្នកបើកបរយានយន្តបករណ៍ ដែលមានល្បឿនអតិបរមាលើសពី៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង ត្រូវមានបណ្ណបើកបរប្រភេទ**គ**។

៦- ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ**គ** ត្រូវមានបណ្ណបើកបរប្រភេទ**ខ**ឬ**ឃ១**សិន។

៧- អ្នកបើកបរយានយន្តប្រភេទ**គ**ឬ**ឃ** អាចបើកបរយានយន្តប្រភេទ**ខ**បាន។

៨- អ្នកមានបណ្ណបើកបរប្រភេទ**គ**អាចបើកបរយានយន្តប្រភេទ**ឃ១**បាន ក្នុងករណីបានឆ្លងកាត់ការប្រឡងយកបណ្ណបើកបរយានយន្តប្រភេទ**គ** តាមរយៈបណ្ណបើកបរយានយន្តប្រភេទ**ឃ១**ប៉ុន្តែអ្នកមានបណ្ណបើកបរប្រភេទ**ឃ២** អាចបើកបរយានយន្តប្រភេទ**ខ** ឬ**គ** ឬ**ឃ១**បាន។

៩- ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ**ឃ១** ត្រូវមានបណ្ណបើកបរប្រភេទ**ខ**សិន។

១០-ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ**ឃ២** ត្រូវមានបណ្ណបើកបរប្រភេទ**ខ** ឬ**គ** ឬ**ឃ១** សិន។

១១-ដើម្បីមានសិទ្ធិប្រឡងយកបណ្ណបើកបរប្រភេទ**ង** ត្រូវមានបណ្ណបើកបរប្រភេទ**ខ**ឬ**គ**ឬ**ឃ**សិន។

១២-អ្នកមានបណ្ណបើកបរប្រភេទ**ង** អាចមានសិទ្ធិបើកបររថយន្តសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមា លើសពី០,៧៥(សូន្យក្បៀសចិតសិបប្រាំ)តោនបាន ទៅតាមប្រភេទបណ្ណបើកបរ ដូចជា **ង**(**ខ**) ឬ**ង**(**គ**) ឬ**ង**(**ឃ**)។

**មាត្រា៤២ ..**

អ្នកកាន់បណ្ណបើកបរគ្រប់ប្រភេទមានសិទ្ធិបើកបរយានយន្តបានរហូតដល់អាយុ៦៥(ហុកសិបប្រាំ)ឆ្នាំ។ ចាប់ពីអាយុ៦៥(ហុកសិបប្រាំ)ឆ្នាំឡើងទៅ អ្នកកាន់បណ្ណបើកបរអាចអនុញ្ញាតឲ្យបើកបរបាន ប៉ុន្តែត្រូវ ពិនិត្យសុខភាព និងប្តូរបណ្ណបើកបរដែលមានសុពលភាពរយៈពេល២(ពីរ)ឆ្នាំម្តង។

សុពលភាពនៃប្រភេទបណ្ណបើកបរ**ក ខ គ ឃ** និង**ង**មានរយៈពេល ដូចខាងក្រោម៖

១- បណ្ណបើកបរប្រភេទ**ក** និងប្រភេទ**ខ** មានសុពលភាពរយៈពេល១០(ដប់)ឆ្នាំ។

២- បណ្ណបើកបរប្រភេទ**គ ឃ** និង**ង** មានសុពលភាពរយៈពេល៥(ប្រាំ)ឆ្នាំ។

៣- អ្នកកាន់បណ្ណបើកបរ ត្រូវសុំប្តូរបណ្ណបើកបរមុនអស់សុពលភាពដោយភ្ជាប់មកជាមួយនូវលិខិតពិនិត្យសុខភាពដែលបញ្ជាក់ថាអាចបើកបរបាន។ ការមិនបានមកប្តូរបណ្ណបើកបរថ្មី ត្រូវទទួលការពិន័យ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ការពិនិត្យសុខភាពត្រូវមានលិខិតបញ្ជាក់ថាអាចបើកបរបានពីគ្រូពេទ្យនៅតាមមន្ទីរពេទ្យ ឬមណ្ឌល សុខភាពដែលត្រូវកំណត់ដោយក្រសួងសុខាភិបាល។

**មាត្រា៤៣ ..**

គ្រប់បណ្ណបើកបរត្រូវមានបណ្ណពិន្ទុដែលមានពិន្ទុសរុបចំនួន១២(ដប់ពីរ)ពិន្ទុ ហើយចំនួនពិន្ទុនេះ ត្រូវកាត់បន្ថយនៅពេលប្រព្រឹត្តបទល្មើសចរាចរណ៍ ដែលមានដូចខាងក្រោម៖

ក- ត្រូវកាត់បន្ថយ១(មួយ)ពិន្ទុ៖

- មិនពាក់ខ្សែក្រវាត់ឬមួកសុវត្ថិភាព
- ប្រើភ្លើងហ្វានៅពេលជួបនឹងយានមកពីទិសផ្ទុយ
- បើកបរជាន់តាមខ្សែគំនូសបង្ហូតកណ្តាលទ្រូងផ្លូវ

- បើកបរលើសល្បឿនកំណត់ចាប់ពី១(មួយ) ទៅ១៩(ដប់ប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង
- បើកបរនៅពេលយប់ដោយគ្មានភ្លើងគ្រប់គ្រាន់តាមប្រភេទយានយន្ត
- ផ្ទុកមនុស្សលើសកំណត់។

ខ- ត្រូវកាត់បន្ថយ២(ពីរ)ពិន្ទុ៖

- បើកបរលើសល្បឿនកំណត់ចាប់ពី២០(ម្ភៃ) ទៅ២៩(ម្ភៃប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង
- បើកបរបង្កើនល្បឿននៅពេលគេកំពុងជែងខ្លួន
- បត់ឆ្វេង ស្តាំ មិនបានត្រឹមត្រូវ
- បត់ត្រឡប់ក្រោយនៅកន្លែងហាមឃាត់
- មិនគោរពលក្ខខណ្ឌនៃបណ្ណបើកបរ
- បត់ឆ្វេង ស្តាំ ឬឈប់មិនបានឲ្យសញ្ញាជាដំណឹង
- ជែងឬជៀសមិនបានត្រឹមត្រូវ
- បើកបរដោយគ្មានទុកចន្លោះសុវត្ថិភាពគ្រប់គ្រាន់ដែលបង្កឲ្យមានគ្រោះថ្នាក់
- បើកបរដោយធ្វេសប្រហែស ធ្វើឲ្យរំខានដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀត
- មិនបានឲ្យសញ្ញាជាដំណឹងត្រឹមត្រូវនៅពេលចេញដំណើរ
- យានមានលក្ខណៈបច្ចេកទេសមិនត្រឹមត្រូវ
- ផ្ទុកទំនិញមិនបានត្រឹមត្រូវ
- ចតយាននៅលើគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់
- ឈប់ឬចតនៅលើគំនូសតម្រឹមទ្រូងផ្លូវ
- ដាក់កុមារអាយុក្រោម១០(ដប់)ឆ្នាំ ឲ្យអង្គុយនៅកៅអីផ្នែកខាងមុខនៃរថយន្ត
- មិនបានដាក់កុមារអាយុក្រោម៥(ប្រាំ)ឆ្នាំ ឲ្យអង្គុយក្នុងកៅអីសម្រាប់កុមារអង្គុយឬដេកក្នុង រថយន្ត
- គេចពីមន្ត្រីនគរបាលចរាចរណ៍ដែលធ្វើការត្រួតពិនិត្យ។

គ- ត្រូវកាត់បន្ថយ៣(បី)ពិន្ទុ៖

- ឈប់ឬចតនៅកន្លែងដែលគ្រោះថ្នាក់
- ជែងដែលប្រកបដោយគ្រោះថ្នាក់
- បើកបរជែងគ្នានៅកន្លែងហាមឃាត់
- ប្តូរទិសគ្មានឲ្យសញ្ញាជាដំណឹង
- បើកបរឆ្លងកាត់គំនូសបន្ទាត់ជាប់កណ្តាលទ្រូងផ្លូវ
- បើកបរលើសល្បឿនកំណត់ចាប់ពី៣០(សាមសិប)ទៅ៣៩(សាមសិបប្រាំបួន)គីឡូម៉ែត្រក្នុង មួយម៉ោង
- បើកបរក្នុងពេលមានអត្រាជាតិស្រវឹងចាប់ពី០,២៥(សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩(សូន្យ ក្បៀសសាមសិបប្រាំបួន)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី

០,៥០(សូន្យក្បៀសហា សិប) ទៅ០,៧៩(សូន្យក្បៀសចិតសិបប្រាំបួន)ក្រាមក្នុងមួយលីត្រឈាម

- បើកបរប្រណាំងគ្នាតាមផ្លូវដោយគ្មានច្បាប់អនុញ្ញាត
- កំហុសនៃការឈប់ឬការមិនផ្តល់សិទ្ធិអាទិភាពនៅកន្លែងថ្មើរជើងឆ្លងកាត់
- មិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម
- មិនគោរពផ្លាកសញ្ញាឈប់ឬសញ្ញាសិទ្ធិអាទិភាព
- មិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់នគរបាលចរាចរណ៍។

ឃ- ត្រូវកាត់បន្ថយ៤(បួន)ពិន្ទុ៖

- បើកបរលើសល្បឿនកំណត់ចាប់ពី៤០(សែសិប) ទៅ៤៩(សែសិបប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង
- បើកបរមិនគោរពសិទ្ធិអាទិភាពនៅត្រង់ផ្លូវប្រសព្វ
- បើកបរទន្ទឹមគ្នា
- ធ្វើឲ្យស្ទះចរន្តចរាចរណ៍
- មិនបានផ្តល់សិទ្ធិអាទិភាពឲ្យយានយន្តមានសិទ្ធិអាទិភាព
- ទំនិញធ្លាក់ពីលើយានពេលកំពុងបើកបរ
- បើកបរបញ្ច្រាសទិសចរាចរណ៍
- បើកបរបង្ហោះ រេចុះឡើង ឆាប ឬគៀរ។

ង- ត្រូវកាត់បន្ថយ៦(ប្រាំមួយ)ពិន្ទុ៖

- បើកបរលើសល្បឿនកំណត់ចាប់ពី៥០(ហាសិប)គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅ
- បើកបរក្នុងពេលមានអត្រាជាតិស្រវឹងចាប់ពី០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ឬ មានឥទ្ធិពលគ្រឿងញៀន
- រត់គេចខ្លួនពេលមានគ្រោះថ្នាក់ចរាចរណ៍
- ប្រើប្រាស់ផ្លាកលេខនិងបណ្ណសម្គាល់យានយន្តក្លែងក្លាយ
- បើកបរល្មើសច្បាប់ចរាចរណ៍ ហើយបង្កឲ្យមានរបួសដល់អ្នកដទៃដោយអចេតនា ហើយបណ្តាលឲ្យអ្នករងគ្រោះ មានអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុឬស្លាប់
- កំហុសមិនរាងចាលនៃការប្រើប្រាស់បណ្ណបើកបរហួសសុពលភាព ឬមិនត្រឹមត្រូវតាមប្រភេទយាន
- បដិសេធមិនឲ្យធ្វើតេស្តជាតិអាល់កុលឬសារធាតុញៀន
- ផ្ទុកមនុស្សលើទំនិញ។

ក្នុងការប្រព្រឹត្តបទល្មើសម្តង ការកាត់ពិន្ទុមិនត្រូវឲ្យលើសពី៨(ប្រាំបី)ពិន្ទុឡើយ។

**មាត្រា៨៤.-**

ករណីដែលពាក់ព័ន្ធនឹងបណ្ណពិន្ទុ៖

- ក្នុងករណីអស់ពិន្ទុ បណ្ណបើកបរត្រូវទុកជាមោឃៈ។ បើអ្នកបើកបរមានបំណងចង់បានបណ្ណបើកបរថ្មី ត្រូវរៀននិងប្រឡងយកបណ្ណបើកបរឡើងវិញក្នុងរយៈពេលយ៉ាងតិច៦(ប្រាំមួយ)ខែ ចាប់ពីថ្ងៃដែលបណ្ណបើកបរត្រូវទុកជាមោឃៈ លើកលែងតែអ្នកបើកបរបង្កឲ្យមានរបួសដល់អ្នកដទៃដោយអចេតនា ហើយបណ្តាលឲ្យអ្នករងគ្រោះមានអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុឬស្លាប់ អ្នកបើកបរអាចរៀននិងប្រឡងយកបណ្ណបើកបរ ជាថ្មីឡើងវិញក្នុងរយៈពេលយ៉ាងតិច៥(ប្រាំ)ឆ្នាំ ចាប់ពីថ្ងៃដែលបណ្ណបើកបរត្រូវទុកជាមោឃៈ
- ក្នុងករណីដែលពិន្ទុត្រូវបានកាត់បន្ថយមួយចំនួនហើយ ប៉ុន្តែក្នុងរយៈពេល៣(បី)ឆ្នាំបន្ទាប់ពីការដកពិន្ទុចុងក្រោយ អ្នកបើកបរមិនបានធ្វើឲ្យមានកំហុសអ្វីមួយថែមទៀតដើម្បីឲ្យកាត់ បន្ថយពិន្ទុនោះ អ្នកបើកបរត្រូវទទួលបណ្ណពិន្ទុថ្មីដែលមានចំនួន១២(ដប់ពីរ)ពិន្ទុដោយស្វ័យ ប្រវត្តិ
- ក្នុងករណីដែលពិន្ទុត្រូវបានកាត់បន្ថយមួយចំនួនហើយ ប៉ុន្តែអ្នកបើកបរចង់បង្កើនពិន្ទុឡើងវិញ ត្រូវធ្វើការរៀនបំប៉នរយៈពេល២(ពីរ)ថ្ងៃ ដែលរៀបចំឡើងដោយក្រសួងសាធារណការ និងដឹកជញ្ជូន។ ក្នុងការរៀននេះ ពិន្ទុអាចកើនឡើង៥(បួន) ពិន្ទុ ប៉ុន្តែមិនអនុញ្ញាតឲ្យមានចំនួន សរុបលើសពី១១(ដប់មួយ)ពិន្ទុឡើយ។ អ្នកបើកបរអាចរៀនបានច្រើនដង ដើម្បីបង្កើនក្នុង រយៈពេល២(ពីរ)ឆ្នាំយ៉ាងយូរ។

នីតិវិធីនៃការដកនិងបំពេញពិន្ទុឡើងវិញសម្រាប់បណ្ណបើកបរ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា៤៥ ..**

លើកលែងតែមានកិច្ចព្រមព្រៀង ឬអនុសញ្ញាអន្តរជាតិទទួលស្គាល់បណ្ណបើកបរទៅវិញទៅមកជាទ្វេភាគីឬពហុភាគីជាមួយព្រះរាជាណាចក្រកម្ពុជា ជនបរទេសដែលចូលមកស្នាក់នៅស្របច្បាប់ហើយមានបំណងបើកបរលើផ្លូវថ្នល់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានបណ្ណបើកបរកម្ពុជាតាមមធ្យោបាយពីរយ៉ាង៖

១- ត្រូវប្រឡងយកបណ្ណបើកបរដូចប្រជាពលរដ្ឋខ្មែរដែរ។

២- ត្រូវយកបណ្ណបើកបររបស់ប្រទេសខ្លួន មកប្តូរយកបណ្ណបើកបរកម្ពុជាដោយដាក់ពាក្យសុំនៅក្រសួងសាធារណការនិងដឹកជញ្ជូន និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក- ត្រូវមានលិខិតឆ្លងដែននិងទិដ្ឋាការមានសុពលភាព។

ខ- ត្រូវមានបណ្ណបើកបរមានសុពលភាព។

គ- មានអាសយដ្ឋានច្បាស់លាស់ដោយមានសេចក្តីបញ្ជាក់របស់មេឃុំឬចៅសង្កាត់។

ឃ- មានលិខិតបញ្ជាក់កាយសម្បទា។

ង- ក្នុងករណីដែលបណ្ណបើកបរមិនសរសេរជាភាសាអង់គ្លេសឬភាសាបារាំង ត្រូវតែបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស ឬភាសាបារាំងដោយមានការបញ្ជាក់ទទួលស្គាល់ពីស្ថានទូត ឬទីស្ថានកុងស៊ុល ឬទីស្ថានរបស់បេសកកម្មរបស់ខ្លួន។

សុពលភាពបណ្ណបើកបររបស់ជនបរទេស ដែលត្រូវបានប្តូរយកបណ្ណបើកបរកម្ពុជាមានរយៈពេល១(មួយ)ឆ្នាំ។ សុពលភាពបណ្ណបើកបររបស់ជនបរទេស ដែលបានប្រឡងជាប់ មានរយៈពេលដូចគ្នានឹងពលរដ្ឋខ្មែរដែរ។

ជនបរទេសដែលមានបណ្ណបើកបរប្រភេទ**គ ឃ** និង**ខ** មិនអាចប្តូរយកបណ្ណបើកបរកម្ពុជាប្រភេទ**គ ឃ** និង**ខ** បានឡើយ ប៉ុន្តែអាចប្តូរយកបណ្ណបើកបរប្រភេទ**ក**និង**ខ**បាន។

**មាត្រា៤៦ ..**

គ្រប់សាលាបង្រៀនបើកបរយានយន្ត ត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត ត្រូវមានកម្មវិធីសិក្សានិងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

គ្រប់គ្រូបង្រៀននៅសាលាបង្រៀនបើកបរយានយន្ត ត្រូវមានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពគ្រូបង្រៀនបើកបរយានយន្ត ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

លក្ខខណ្ឌនិងនីតិវិធី នៃការចេញលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្តនិង ការប្រឡងយកវិញ្ញាបនបត្របញ្ជាក់សមត្ថភាពគ្រូបង្រៀនបើកបរយានយន្ត ព្រមទាំងកម្មវិធីសិក្សានៅសាលា បង្រៀនបើកបរយានយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃមានសិទ្ធិត្រួតពិនិត្យគ្រប់សាលាបង្រៀនបើកបរយានយន្តទាំងអស់។

**មាត្រា៤៧ ..ថ្មី**

គ្រប់យានយន្តនៅពេលដាក់ឲ្យធ្វើចរាចរណ៍នៅលើផ្លូវថ្នល់ ត្រូវមានបណ្ណសម្គាល់យានយន្តនិងមានពាក់ផ្លាកលេខសម្គាល់យានយន្ត។

គ្រប់យានយន្ត ត្រូវចុះបញ្ជីផ្តល់បណ្ណសម្គាល់យានយន្តនិងបំពាក់ផ្លាកលេខសម្គាល់យានយន្ត។ ចំពោះរ៉ឺម៉ក ឬសឺមីរ៉ឺម៉កមានទម្ងន់សរុបលើសពី៧៥០(ប្រាំពីររយហាសិប)គីឡូក្រាម ត្រូវចុះបញ្ជីផ្តល់បណ្ណសម្គាល់ និងបំពាក់ផ្លាកលេខដូចយានយន្តដែរ។

ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវផ្តល់បញ្ជីស្ថិតិយានយន្តគ្រប់ប្រភេទដែលបានចុះបញ្ជីរួចជូនក្រសួងមហាផ្ទៃមួយខែម្តង។

ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវផ្តល់ព័ត៌មានអំពីចំនួនរថយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬគ្រឿងចក្រដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជូនក្រសួងសាធារណការ និងដឹកជញ្ជូន ៣ (បី) ខែម្តង លើកលែងព័ត៌មានសម្ងាត់ ដែលពាក់ព័ន្ធនឹងសន្តិសុខជាតិ។

ការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះ និងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៨ ..ថ្មី**

គ្រប់ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទ មានកាតព្វកិច្ចបំពេញបែបបទចុះបញ្ជីយាន

យន្តសុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឲ្យបានចប់សព្វគ្រប់មុននិង ប្រគល់ឲ្យអ្នកទិញ។

ការលក់ទិញ ការធ្វើអំណោយ និងរាល់ទម្រង់ផ្សេងៗទៀត ដែលនាំឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃយានយន្ត ត្រូវបំពេញសំណុំបែបបទដើម្បីផ្ទេរកម្មសិទ្ធិយានយន្ត។ បែបបទ និងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានយន្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ម្ចាស់យានយន្តគ្រប់ប្រភេទ មានកាតព្វកិច្ចបំពេញបែបបទលុបចេញពីបញ្ជីយានយន្តនូវយានយន្តទាំងឡាយដែលឈប់ប្រើប្រាស់។

បែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្ត ការផ្តល់ផ្លាកលេខសម្គាល់យានយន្ត និងការលុបចេញពីបញ្ជីយានយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា៤៩ ..**

គ្រប់រថយន្ត រ៉ឺម៉ក និងសឺមីរ៉ឺម៉កដែលធ្វើចរាចរណ៍លើផ្លូវថ្នល់ ត្រូវមានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូនឬក្រុមហ៊ុនដែលមានការ អនុញ្ញាតពីក្រសួងសាធារណការនិងដឹកជញ្ជូន។

សុពលភាពនៃវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ត្រូវកំណត់ដូចខាងក្រោម៖

១-រថយន្តថ្មីជាប្រភេទរថយន្តគ្រួសារដែលមិនទាន់ប្រើប្រាស់ ត្រូវសុំវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តលើកទី១ ដែលមានសុពលភាព៤(បួន)ឆ្នាំ។ បន្ទាប់មកត្រូវធ្វើការត្រួតពិនិត្យ លក្ខណៈបច្ចេកទេសរៀងរាល់២(ពីរ)ឆ្នាំម្តង។

២-រថយន្តចាស់ជាប្រភេទរថយន្តគ្រួសារដែលបានប្រើប្រាស់រួចហើយ ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់០២(ពីរ)ឆ្នាំម្តង។

៣-រថយន្តថ្មីធ្វើអាជីវកម្មដឹកអ្នកដំណើរ ដឹកទំនិញ និងរថយន្តឧបករណ៍ថ្មី ដែលមិនទាន់ប្រើប្រាស់ ត្រូវសុំវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តលើកទី១ ដែលមានសុពលភាព២(ពីរ)ឆ្នាំ។ បន្ទាប់មកត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់១(មួយ)ឆ្នាំម្តង។

៤-រថយន្តចាស់ធ្វើអាជីវកម្មដឹកអ្នកដំណើរ ដឹកទំនិញ និងរថយន្តឧបករណ៍ចាស់ដែលបានប្រើប្រាស់ រួចហើយ ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់១(មួយ)ឆ្នាំម្តង។

៥-រ៉ឺម៉កថ្មីនិងសឺមីរ៉ឺម៉កថ្មីដែលមិនទាន់ប្រើប្រាស់ ត្រូវសុំវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តដែលមានសុពលភាព២(ពីរ)ឆ្នាំ។ បន្ទាប់មកត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេស រៀងរាល់១(មួយ)ឆ្នាំម្តង។

៦-រ៉ឺម៉កចាស់និងសឺមីរ៉ឺម៉កចាស់ដែលបានប្រើប្រាស់រួចហើយ ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈ បច្ចេកទេសរៀងរាល់១(មួយ)ឆ្នាំម្តង។

៧-ត្រីចក្រយានយន្តនិងទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់១(មួយ)ឆ្នាំម្តង។

៨- គ្រប់រថយន្ត រ៉ឺម៉ក និងសឺមីរ៉ឺម៉កដែលទើបបានកែច្នៃក្នុងប្រទេសរួច មុននឹងចុះបញ្ជីសុំបណ្ណ សម្គាល់និងសុំផ្លាកលេខ ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុនសិន។ បន្ទាប់មកត្រូវធ្វើការ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសរៀងរាល់១(មួយ)ឆ្នាំម្តង។

ការកំណត់លក្ខណៈបច្ចេកទេសយានជំនិះ និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះគ្រប់ ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៥០ .-**

គ្រប់មជ្ឈមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៥១ .-**

ម្ចាស់យានយន្តដែលតម្រូវឲ្យមានការធានារ៉ាប់រងជាកាតព្វកិច្ច ត្រូវបំពេញកាតព្វកិច្ចធានារ៉ាប់រង ស្របតាមច្បាប់ស្តីពីការធានារ៉ាប់រងនិងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងការធានារ៉ាប់រងនៅពេលដែលយានយន្តត្រូវបានយកទៅធ្វើចរាចរណ៍នៅលើផ្លូវថ្នល់។

**មាត្រា៥២ .-**

គ្រប់យានដ្ឋានផ្គុំសជុលយានយន្តនិងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម និងក្នុងករណីចាំបាច់ត្រូវមានការត្រួតពិនិត្យពីក្រសួងមហាផ្ទៃ។

ការគ្រប់គ្រងយានដ្ឋានផ្គុំសជុលនិងយានដ្ឋានកែច្នៃដំឡើងយានយន្ត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៣ .-**

នីតិបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញនិងអ្នកដំណើរនៅក្នុងប្រទេស ឬឆ្លងដែនត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យនីតិបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសឬឆ្លងដែន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៥៤ .-**

គ្រប់យានយន្ត រ៉ឺម៉ក ដែលយកទៅប្រើប្រាស់ក្នុងការធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឬអ្នកដំណើរ ត្រូវ មានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មដឹកជញ្ជូនចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន។

លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្មដឹកជញ្ជូនផ្លូវគោកក្នុងប្រទេសឬឆ្លងដែន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៥៥ .-**

គ្រប់យានយន្តឬរ៉ឺម៉កដែលកំពុងធ្វើសកម្មភាពអាជីវកម្មដឹកជញ្ជូន ត្រូវមាន៖

ក- បណ្ណសម្គាល់យានយន្តឬបណ្ណសម្គាល់រ៉ឺម៉កនិងផ្លាកលេខ

ខ- បណ្ណបើកបរត្រឹមត្រូវតាមប្រភេទយានយន្ត

គ- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត

ឃ- លិខិតអនុញ្ញាតឲ្យយានយន្តឬរ៉ឺម៉កធ្វើអាជីវកម្មដឹកជញ្ជូន

ង- វិញ្ញាបនបត្រធានារ៉ាប់រងចេញដោយក្រុមហ៊ុនធានារ៉ាប់រង

ច- លិខិតអនុញ្ញាតផ្សេងទៀតចេញដោយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា៥៦ .-**

ការរៀបចំផ្ទុកទំនិញនិងមនុស្ស ត្រូវអនុវត្តដូចខាងក្រោម៖

១- ការផ្ទុកទំនិញលើយានជំនិះ ត្រូវរៀបចំឲ្យត្រឹមត្រូវដើម្បីការពារនឹង៖

- ការបង្កគ្រោះថ្នាក់ដល់មនុស្សឬការធ្វើឲ្យខូចទ្រព្យសម្បត្តិសាធារណៈ ឬឯកជន ដោយការអូសឬធ្លាក់តាមផ្លូវ
- ការបាំងភ្នែកអ្នកបើកបរឬការធ្វើឲ្យអន់ថយដល់លំនឹងយាន និងការបើកបរយាន
- ការបង្កឲ្យមានសំឡេង ឬការបង្កើនធូលី ឬការធ្វើឲ្យរំខានផ្សេងៗទៀតដែលអាចជៀសវាងបាន
- ការធ្វើឲ្យបាំងភ្លើងស្តុប ភ្លើងសញ្ញាប្តូរទិស កញ្ចក់ចាំងពន្លឺ និងផ្លាកលេខយានយន្ត។

២- គ្រប់ឧបករណ៍ការពារបន្ថែមដូចជាខ្សែនីឡុង ខ្សែកាបច្រវាក់ និងកម្រាលសំពត់តង់ដែលប្រើប្រាស់សម្រាប់សុវត្ថិភាព ឬការពារទំនិញ ត្រូវគ្របនិងចងឲ្យបានជាប់ល្អ។

៣- ក្នុងគ្រប់ករណីនៃការផ្ទុកវត្ថុផ្សេងៗដែលមានបណ្តោយវែង បន្ទុកនោះមិនត្រូវឲ្យលូតហួសពីគែមខាងមុខនៃយាន និងមិនត្រូវឲ្យហួសពីគែមខាងក្រោយនៃយានប្រវែង៣(បី)ម៉ែត្រ ឬធ្លាក់អូសដីឡើយ។

៤- ប្រសិនបើបន្ទុកត្រូវលូតហួស១(មួយ)ម៉ែត្រពីគែមខាងក្រោយនៃយាន ពេលថ្ងៃត្រូវចង ក្រណាត់ពណ៌ក្រហម ពេលយប់ត្រូវដាក់កញ្ចក់ចាំងពន្លឺពណ៌ក្រហមនៅចុងបន្ទុក។ ទទឹងបន្ទុកមិនត្រូវឲ្យលើសហួសពីគែមទទឹងយាន ហើយកម្ពស់មិនត្រូវឲ្យហួសលើសពីដំបូលយានឡើយ លើកលែងតែរថយន្តផ្ទុកមនុស្សចំនួនអតិបរមាត្រឹម២០(ម្ភៃ)នាក់ ដែលអាចផ្ទុកទំនិញកម្ពស់អតិបរមាត្រឹម០,៥០(សូន្យក្បៀសហាសិប)ម៉ែត្រពីលើដំបូល និងត្រូវមានជើងទម្រឬរនាំងចាប់ភ្ជាប់ដំបូលយ៉ាងរឹងមាំ។

៥- ក្នុងករណីផ្ទុកទំនិញគ្រោះថ្នាក់ ត្រូវរៀបចំទុកដាក់ឬវេចខ្ចប់ឲ្យមានសុវត្ថិភាពល្អ ហើយត្រូវសរសេរឈ្មោះប្រភេទនិងបិទផ្លាកសញ្ញាសម្គាល់វត្ថុគ្រោះថ្នាក់នោះ។

៦- ការដឹកជញ្ជូនមនុស្សត្រូវមានកៅអីអង្គុយ ឬមានបង្កាន់ដៃឬប្រដាប់តោងឈររឹងមាំ ហើយត្រូវឲ្យមានផាសុកភាពល្អ។

ការផ្ទុកមនុស្សត្រូវហាមឃាត់ ដូចខាងក្រោម៖

- ហាមផ្ទុកមនុស្សលើសពីចំនួនកន្លែងអង្គុយ ដែលកំណត់ដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- ហាមផ្ទុកមនុស្សនៅលើដំបូលកាប៊ីនឬដំបូលរថយន្ត
- ហាមតោងពីមុខ ពីក្រោយ ឬពីចំហៀងរថយន្ត
- ហាមផ្ទុកមនុស្សនៅលើរ៉ឺម៉កឬសឺមីរ៉ឺម៉ក
- ហាមផ្ទុកវត្ថុដែលមានក្លិនអាក្រក់ឬមានជាតិពុលក្នុងរថយន្តដឹកមនុស្ស។

៧- បច្ចេកទេសផ្ទុក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៥៧.-**

ការផ្ទុកទំនិញលើរថយន្ត រ៉ឺម៉ក ឬសឺមីរ៉ឺម៉ក មិនត្រូវឲ្យលើសទម្ងន់សរុបអតិបរមារបស់យាន ដែលកំណត់ដោយរោងចក្រផលិតយាននិងមិនត្រូវឲ្យលើសទម្ងន់អតិបរមាសង្កត់លើភ្លៅ និងទម្ងន់សរុបអតិបរមា របស់យានដែលបានអនុញ្ញាតដូចមានចែងក្នុងច្បាប់ស្តីពីផ្លូវថ្នល់។

នៅពេលឆ្លងកាត់ស្ពាន គ្រប់អ្នកបើកបររថយន្ត រថយន្តសណ្តោងរ៉ឺម៉កឬសឺមីរ៉ឺម៉ក ត្រូវគោរពតាមទម្ងន់សរុបអនុញ្ញាតអតិបរមាដែលកំណត់ក្នុងស្លាកសញ្ញាដាក់តាំងនៅពីមុខស្ពាន។

ទំហំរថយន្ត និងរថយន្តសណ្តោងរ៉ឺម៉កឬសឺមីរ៉ឺម៉ក ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងអតិបរមាមិនត្រូវឲ្យលើសពី២,៥០(ពីរក្បៀសហាសិប)ម៉ែត្រ លើកលែងតែយានយន្តបករណ៍ដែលមិនត្រូវឲ្យលើសពី៣(បី)ម៉ែត្រ
- ប្រវែងកម្ពស់អតិបរមាមិនត្រូវឲ្យលើសពី៤,២០(បួនក្បៀសម្ភៃ)ម៉ែត្រ
- ប្រវែងបណ្តោយអតិបរមានៃរថយន្តនីមួយៗមិនត្រូវឲ្យលើសពី១២,២០(ដប់ពីរក្បៀសម្ភៃ)ម៉ែត្រ
- ប្រវែងបណ្តោយអតិបរមានៃរថយន្តនីមួយៗដែលមានសណ្តោងសឺមីរ៉ឺម៉ក មិនត្រូវឲ្យលើស ពី១៦(ដប់ប្រាំមួយ)ម៉ែត្រ
- ប្រវែងបណ្តោយអតិបរមានៃរថយន្តនីមួយៗដែលមានសណ្តោងរ៉ឺម៉ក មិនត្រូវឲ្យលើសពី១៨(ដប់ប្រាំបី)ម៉ែត្រ

ទំហំអតិបរមារថយន្តនិងរថយន្តសណ្តោងរ៉ឺម៉កឬសឺមីរ៉ឺមក ដែលគ្មានចែងនៅក្នុងចំណុចខាងលើ នេះត្រូវសុំលិខិតអនុញ្ញាតពិសេសពីរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

បទដ្ឋានបច្ចេកទេសលម្អិតស្តីពីទំហំនិងទម្ងន់យានជំនិះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៥៨.-**

ការបង់ប្រាក់សម្រាប់ថ្លៃសេវាចេញបណ្ណបើកបរ បណ្ណសម្គាល់ ផ្លាកលេខ វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស និងលិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្ម ប្រាក់ពិន័យក្នុងការឃើតឃាំងផ្សេងៗ និងសេវាផ្សេងៗ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ជំពូកទី៨
## យន្តការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

**មាត្រា៥៩ .-**

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក មានតួនាទីរៀបចំគោលនយោបាយស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងដឹកនាំត្រួតពិនិត្យការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ពាក់ព័ន្ធនឹងសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូនជាអនុប្រធានអចិន្ត្រៃយ៍ និងសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយក្រសួងសាធារណការនិងដឹកជញ្ជូន និងអនុគណៈកម្មការមួយចំនួនជាជំនួយការ។

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៩
## សមត្ថកិច្ចនិងសិទ្ធិអំណាចរបស់មន្ត្រីអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

**មាត្រា៦០ .-**

មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោករួមមាន៖

១- មន្ត្រីមកពីក្រសួងសាធារណការនិងដឹកជញ្ជូន

២- អង្គភាពនគរបាលឬកងរាជអាវុធហត្ថដែលទទួលបន្ទុករៀបចំសណ្តាប់ធ្នាប់ សុវត្ថិភាពចរាចរណ៍ មានភារកិច្ច៖

- ចាត់ចែងចរាចរណ៍ឲ្យមានសណ្តាប់ធ្នាប់ល្អ
- តាមដាន ល្បាត និងពិនិត្យអំពើល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍ដោយផ្ទាល់ឬដោយឧបករណ៍បច្ចេកទេស
- ធ្វើរបាយការណ៍ស្តីពីសភាពការណ៍សណ្តាប់ធ្នាប់ចរាចរណ៍បទល្មើសចរាចរណ៍ និង គ្រោះថ្នាក់ចរាចរណ៍ដែលកើតមានឡើង។

ដោយឡែក អង្គភាពនគរបាលដែលទទួលបន្ទុករៀបចំសណ្តាប់ធ្នាប់សុវត្ថិភាពចរាចរណ៍ មានភារកិច្ចបន្ថែម៖

- ពិន័យជាប្រាក់ចំពោះអំពើល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍
- សម្រុះសម្រួលក្នុងករណីគ្រោះថ្នាក់ចរាចរណ៍ដូចមានចែងក្នុងមាត្រា៦៥ នៃច្បាប់នេះ
- ត្រួតពិនិត្យនិងកត់ត្រាដំណើរហេតុនៅពេលមានគ្រោះថ្នាក់ចរាចរណ៍ ក្នុងករណី

ចាំបាច់ ធ្វើការដកហូតជាបណ្ដោះអាសន្ននូវបណ្ណបើកបរ និងឃាត់យានជំនិះតាម មាត្រា៦២ មាត្រា៦៦ និងមាត្រា៦៧នៃច្បាប់នេះ។

- រៀបចំនិងបញ្ជូនកំណត់ហេតុព្រមទាំងវត្ថុតាងទៅអយ្យការអមសាលាដំបូង ក្នុងករណីកំណត់ដោយច្បាប់នេះ។

**មាត្រា៦១ .-**

ក្នុងការឃាត់យានជំនិះដើម្បីត្រួតពិនិត្យ នគរបាលចរាចរណ៍ផ្លូវគោកត្រូវអនុវត្តដោយជៀសវាងការធ្វើឲ្យស្ទះចរាចរណ៍ឬការបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍។

**មាត្រា៦២ .-**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក មានសិទ្ធិដកបណ្ណបើកបរព្យួរទុកក្នុងរយៈពេលមិនលើសពី៧ (ប្រាំពីរ)ថ្ងៃ និងដកពិន្ទុដូចមានចែងក្នុងមាត្រា៨៣នៃច្បាប់នេះចំពោះបទល្មើសណាមួយដូចខាងក្រោម៖

១- បើកបរខុសទិសចរាចរណ៍ ឬបើកបរតាមទិសចរាចរណ៍ដែលមានដាក់សញ្ញាហាមឃាត់។

២- បើកបរដោយល្បឿនលើសចាប់ពី៥០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោងឡើងទៅពីល្បឿន ដែលបានកំណត់ក្នុងច្បាប់នេះ។

៣- មិនគោរពសិទ្ធិអាទិភាព។

៤- មិនគោរពស្លាកសញ្ញាឈប់ ឬភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហមឬពណ៌ក្រហមភ្លឹបភ្លែតៗ។

៥- បើកបរយានដែលមានកង់ច្រវាក់ដែកផ្ទាល់នៅលើផ្លូវថ្នល់ក្រាលកៅស៊ូ។

មន្ត្រីនគរបាលចរាចរណ៍ មិនត្រូវដកហូតបណ្ណបើកបរនិងឯកសារផ្សេងៗរបស់យានយន្តក្នុងករណី ពុំមានចែងក្នុងច្បាប់នេះ។

**មាត្រា៦៣ .-**

ក្នុងករណីមានគ្រោះថ្នាក់ចរាចរណ៍អាស្រ័យទៅតាមករណីនីមួយៗនោះ ការឃាត់យានជំនិះការឃាត់ខ្លួនអ្នកបើកបរដើម្បីសាកសួរព័ត៌មាន និងការធ្វើកំណត់ហេតុជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកនៅកន្លែងកើតហេតុ។ ក្នុងករណីដែលអ្នកបើកបរស្ថិតនៅក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀន មន្ត្រីនគរបាលយុត្តិធម៌ផ្នែកចរាចរណ៍ ឬមន្ទីរពេទ្យត្រូវត្រួតពិនិត្យនិងចេញលិខិតបញ្ជាក់អត្រាជាតិអាល់កុល ឬសារធាតុញៀន ដើម្បីភ្ជាប់ជាមួយកំណត់ហេតុគ្រោះថ្នាក់ចរាចរណ៍ទៅអយ្យការអមសាលាដំបូង។

**មាត្រា៦៤ .-**

បទល្មើសចរាចរណ៍ផ្លូវគោកដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ និងត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ ជាសមត្ថកិច្ចរបស់តុលាការ។ ក្នុងករណីនេះ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកដែលមានសមត្ថកិច្ចត្រួតពិនិត្យបទល្មើសចរាចរណ៍ផ្លូវគោក ត្រូវបញ្ជូនកំណត់ហេតុស្ដីពីបទល្មើសចរាចរណ៍ផ្លូវគោកទៅអយ្យការអមសាលាដំបូង។

**មាត្រា៦៥ ..**

បទល្មើសចរាចរណ៍ដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍ ផ្លូវគោក។ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក អាចសម្រុះសម្រួលក្នុងករណីមានគ្រោះថ្នាក់ដែលបណ្តាល ឲ្យសងតែសំណងខូចខាត។ ប្រសិនបើការសម្រុះសម្រួល មិនបានសម្រេច មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកត្រូវធ្វើកំណត់ហេតុកត់ត្រាស្លាកស្នាមផ្សេងៗ ហើយក្នុងករណីចាំបាច់ដើម្បីធានាការពារផលប្រយោជន៍តាមផ្លូវច្បាប់របស់ភាគី មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកអាចរក្សាទុកយានយន្តជាបណ្តោះអាសន្នមិនឲ្យលើសពីមួយសប្តាហ៍។

**មាត្រា៦៦ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវឃាត់យានជំនិះមិនឲ្យធ្វើចរាចរណ៍ឬឃាំងទុកយានជំនិះរយៈពេលមិនលើសពី៣(បី)ថ្ងៃ ដើម្បីធ្វើការពិន័យនិងកែតម្រូវលក្ខណៈបច្ចេកទេសទៅតាមករណីដែលអ្នកបើកបរបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍ ដូចខាងក្រោម៖

១- យានជំនិះដែលអ្នកបើកបរកំពុងស្ថិតនៅក្នុងភាពស្រវឹង ដោយមានអត្រាជាតិអាល់កុលចាប់ពី០,២៥(សូន្យក្បៀសម្ភៃប្រាំ)ដល់០,៣៩(សូន្យក្បៀសសាមសិបប្រាំបួន)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៥០(សូន្យក្បៀសហាសិប)ដល់០,៧៩(សូន្យក្បៀសចិតសិបប្រាំបួន)ក្រាមក្នុងមួយលីត្រឈាម ឬស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀន។

២- យានជំនិះដែលអ្នកបើកបរមិនព្រមឲ្យសមត្ថកិច្ចត្រួតពិនិត្យអត្រាជាតិអាល់កុលឬសារធាតុញៀន។

៣-យានជំនិះដែលមានលក្ខណៈបច្ចេកទេសមិនគ្រប់គ្រាន់ អាចបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍។

៤- យានជំនិះដែលបញ្ចេញផ្សែងខ្លាំង ឬសំឡេងម៉ាស៊ីនខ្លាំងលើសបទដ្ឋានបច្ចេកទេស ឬបំពាក់ ប្រព័ន្ធភ្លើងបំភ្លឺខុសស្តង់ដាកំណត់ធ្វើឲ្យរំខានដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀត ឬអ្នកដែលរស់នៅជាប់ដងផ្លូវថ្នល់។

៥- យានជំនិះផ្ទុកទំនិញឬអ្នកដំណើរនាំឲ្យបាំងឬទើសទែងដល់អ្នកបើកបរ ឬហួសកម្រិតកំណត់។

៦- យានជំនិះដែលចតចោលនៅលើទ្រូងផ្លូវក្នុងទីប្រជុំជនលើសពី២៤ម៉ោង។

៧-យានយន្តដែលបើកបរហួសពេលកំណត់ត្រួតពិនិត្យលក្ខណៈបច្ចេកទេស។

៨-យានយន្ត ដែលបើកបរលើសល្បឿនកំណត់ចាប់ពី៤០(សែសិប)គីឡូម៉ែត្រក្នុងមួយម៉ោង ឡើងទៅ។

**មាត្រា៦៧ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក មានសិទ្ធិស្ទូចយានជំនិះដែលចតធ្វើឲ្យរំខានឬអាចនាំឲ្យមាន គ្រោះថ្នាក់ដល់យានដទៃ យកទៅរក្សាទុកនៅអង្គភាពនគរបាលចរាចរណ៍ផ្លូវគោកក្នុងករណីដែលម្ចាស់ យានជំនិះមិនព្រមទទួលការពិន័យ ឬគ្មានវត្តមាន។

ការស្ទូចយានជំនិះយកទៅរក្សាទុកនៅអង្គភាពនគរបាលចរាចរណ៍ផ្លូវគោក ក៏ត្រូវអនុវត្តផងដែរ ចំពោះយានជំនិះពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍ដែលពុំអាចដោះស្រាយបាន។

ម្ចាស់យានជំនិះត្រូវទទួលខុសត្រូវបង់សោហ៊ុយថ្លៃស្ទូច និងថ្លៃរក្សាទុកបន្ថែមលើប្រាក់ពិន័យ។

សោហ៊ុយថ្លៃស្ទូចនិងថ្លៃរក្សាទុក ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៨ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ដែលមានសមត្ថកិច្ចត្រួតពិនិត្យបទល្មើសចរាចរណ៍ ត្រូវពិនិត្យ អង្កេត កត់ត្រាបទល្មើសស្របតាមបែបបទនៃការពិនិត្យ ការអង្កេត ការកត់ត្រាបទល្មើស និងការធ្វើកំណត់ ហេតុគ្រោះថ្នាក់ចរាចរណ៍ដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា៦៩ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ដែលមានសមត្ថកិច្ចផាកពិន័យបទល្មើសចរាចរណ៍ ត្រូវចេញ បង្កាន់ដៃផាកពិន័យដែលមានគល់បញ្ជីត្រឹមត្រូវ។ ទម្រង់បែបបទនៃបង្កាន់ដៃផាកពិន័យនិងការគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការផាកពិន័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា៧០ ..**

បុគ្គល ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីអនុវត្តច្បាប់ដូចមានចែងក្នុងមាត្រា៦០នៃច្បាប់នេះ មានសិទ្ធិប្តឹងតវ៉ាទៅប្រធានអង្គភាពដែលគ្រប់គ្រងផ្ទាល់លើមន្ត្រីនោះ។ ប្រធានអង្គភាពត្រូវ សម្រេចលើបណ្តឹងតវ៉ា១៥(ដប់ប្រាំ)ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹង។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តី សម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធី។

## ជំពូកទី១០
## ទោសប្បញ្ញត្តិ

**មាត្រា៧១ ..**

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧២ ..**

អ្នកបើកបរ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងការបើកបរយានជំនិះ។

អ្នកគ្រប់គ្រងឬកម្មសិទ្ធិករ ត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងករណីយានជំនិះរបស់ខ្លួនបានបង្កឲ្យមានគ្រោះថ្នាក់ដល់អ្នកដទៃ។

**មាត្រា៧៣ ..**

ការរំលោភលើរាងកាយ កិត្តិយស សេចក្តីថ្លៃថ្នូរ របស់មន្ត្រីអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

ដែលកំពុងបំពេញភារកិច្ច ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌជាធរមាន។

**មាត្រា៧៤ ..**

មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកណា ដែលនៅក្នុងក្របខ័ណ្ឌមុខងារ ឬក្នុងឱកាសបំពេញមុខងាររបស់ខ្លួន ដែលបានដកហូតយកបណ្ណបើកបរ ផ្លាកលេខ បណ្ណសម្គាល់យានជំនិះ ឬឃាត់ទុកយានជំនិះដោយបំពានច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី ១០០ ០០០(មួយសែន)រៀលទៅ៨០០ ០០០(ប្រាំបីសែន)រៀល។

ក្នុងករណីដែលមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ធ្វើឲ្យមានការខូចខាតឬបាត់បង់ផ្នែកណាមួយនៃ យានជំនិះដែលបានឃាត់ទុក អង្គភាពសាមីត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតឬបាត់បង់នោះ។

**មាត្រា៧៥ .. ថ្មី**

ជនណាបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី៨០០ ០០០(ប្រាំបីសែន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងកំលុងពេល៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន។

បទប្បញ្ញត្តិកថាខណ្ឌទី២ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកបើកបរទោចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត។

**មាត្រា៧៦ ..**

ជនណាបើកបរយានយន្ត មិនព្រមបញ្ឈប់យានយន្តតាមការបញ្ជារបស់មន្ត្រីនគរបាលចរាចរណ៍ ផ្លូវគោកដើម្បីធ្វើតេស្តពិនិត្យជាតិអាល់កុលឬសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ) ថ្ងៃទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០(មួយសែន)រៀលទៅ ៨០០ ០០០(ប្រាំបីសែន)រៀល។

ត្រូវផ្តន្ទាទោសដូចកថាខណ្ឌទី១ខាងលើ ចំពោះអ្នកបើកបរណាដែលមិនព្រមឲ្យធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់យាន ឬធ្វើតេស្តពិនិត្យជាតិអាល់កុលឬសារធាតុញៀន។

**មាត្រា៧៧ .. ថ្មី**

ជនណាបើកបរយានយន្តនៅពេលដែលខ្លួន ស្ថិតនៅក្នុងភាពស្រវឹង ដោយមានជាតិអាល់កុលចាប់ពី០,៥០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី០,៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី៨០០ ០០០(ប្រាំបីសែន)រៀលទៅ៤ ០០០ ០០០(បួនលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀត ក្នុងកំលុងពេល៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៧៨ ..**

ជនណាដែលចរាចរយានជំនិះ ដោយប្រើប្រាស់បណ្ណបើកបរ បណ្ណសម្គាល់យានជំនិះ ផ្លាកលេខសម្គាល់យានជំនិះ ឬលិខិតអនុញ្ញាតផ្សេងៗដោយដឹងថាជាឯកសារឬវត្ថុក្លែងក្លាយ ត្រូវផ្តន្ទាទោសតាម បញ្ញត្តិមាត្រា៦៣០(បទប្រើប្រាស់ឯកសារសាធារណៈក្លែង)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៧៩ ..**

ជនណាក្លែងបណ្ណបើកបរ បណ្ណសម្គាល់យានជំនិះ ផ្លាកលេខសម្គាល់យានជំនិះឬលិខិតអនុញ្ញាត ផ្សេងៗ ដែលចេញដោយអ្នករាជការសាធារណៈ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២៩ (បទក្លែងបន្លំឯកសារ សាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨០ ..**

ជនណារារាំងឬប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីជាឧបសគ្គដល់ចរាចរណ៍សាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី៨០០ ០០០(ប្រាំបីសែន)រៀល ទៅ៨ ០០០ ០០០(ប្រាំបីលាន)រៀល។

**មាត្រា៨១ ..**

ជនណាបើកបរ មិនគោរពសញ្ញាបញ្ជារបស់មន្ត្រីមានសមត្ថកិច្ចការពារក្បួនដំណើរគណៈប្រតិភូឬថ្នាក់ដឹកនាំជាន់ខ្ពស់បង្កការខូចខាតដល់យានយន្តរបស់ក្បួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ ពី៨០០ ០០០(ប្រាំបីសែន)រៀល ទៅ៤ ០០០ ០០០(បួនលាន)រៀល។

**មាត្រា៨២ .. ថ្មី**

ជនណាប្រើប្រាស់យានយន្តដោយគ្មានបណ្ណសម្គាល់រថយន្ត ឬគ្មានផ្លាកលេខសម្គាល់រថយន្ត ត្រូវពិន័យអន្តរការណ៍តាមការកំណត់នៃអនុក្រឹត្យ។

អំពើល្មើសខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ថ្ងៃទៅ១(មួយ)ខែ និងពិន័យជាប្រាក់ពី៤០០ ០០០(បួនសែន)រៀលទៅ១ ០០០ ០០០(មួយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តល្មើសទៀតក្នុងកំលុងពេល៦ (ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន។

បទប្បញ្ញត្តិកថាខណ្ឌទី២ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអ្នកបើកបរទោចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉កឬត្រីចក្រយានយន្ត។

**មាត្រា៨៣ ..**

ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឲ្យមានរបួសដល់អ្នកដទៃ ហើយបណ្តាលឲ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើឬលើសពី៨(ប្រាំបី)ថ្ងៃ គិតពីថ្ងៃកើតហេតុ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី២ ០០០ ០០០(ពីរលាន)រៀលទៅ១០ ០០០ ០០០(ដប់ លាន)រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា៥៣(ប្រភេទនៃទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

អំពើល្មើសខាងលើនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន)រៀល ទៅ១៥ ០០០ ០០០(ដប់ប្រាំលាន)រៀល កាលបើអំពើនេះបានប្រព្រឹត្ត ក្នុងករណីណាមួយ ដូចខាងក្រោម៖

ក- បើកបរដោយគ្មានបណ្ណបើកបរឬមានបណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ខ- ស្ថិតក្នុងស្ថានភាពស្រវឹងដោយមានអត្រាជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ឬចាប់ពី០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

គ- បណ្តាលឲ្យមានរបួសមនុស្សច្រើននាក់។

ឃ- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះទោសបន្ថែម ដូចតទៅនេះអាចត្រូវបានប្រកាស៖

១- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

២- ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន។

៣- ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល២(ពីរ)ខែយ៉ាងច្រើន។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់ រយៈពេល៨(ប្រាំបី)ថ្ងៃយ៉ាងច្រើន។

**មាត្រា៨៤ ..**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមាន ចែងក្នុងមាត្រា៨៣នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចតទៅនេះ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសតាមបែបបទកំណត់ដោយមាត្រា១៧៦(ការបិទគ្រឹះស្ថាន)នៃក្រមព្រហ្មទណ្ឌ។

៥- ការហាមឃាត់ចំពោះការធ្វើអាជីវកម្ម លើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែល ប្រើប្រាស់ដល់សាធារណជន តាមបែបបទកំណត់ដោយមាត្រា១៧៧(ការហាមឃាត់ចំពោះការធ្វើអាជីវកម្ម លើគ្រឹះស្ថាន)នៃក្រមព្រហ្មទណ្ឌ។

៦- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយ សេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៧- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨៥ .-**

ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវបណ្តាលឲ្យស្លាប់អ្នកដទៃ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១៥ ០០០ ០០០(ដប់ប្រាំលាន)រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។

អំពើល្មើសខាងលើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២៥ ០០០ ០០០(ម្ភៃប្រាំលាន)រៀល កាលបើអំពើនេះបានប្រព្រឹត្តក្នុង ករណីណាមួយ ដូចក្រោម៖

ក- បើកបរដោយគ្មានបណ្ណបើកបរឬមានបណ្ណបើកបរតែមិនត្រឹមត្រូវតាមប្រភេទយានយន្ត។

ខ- ស្ថិតក្នុងស្ថានភាពស្រវឹងដោយមានអត្រាជាតិអាល់កុលចាប់ពី០,៤០(សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ឬចាប់ពី០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ។

គ- បណ្តាលឲ្យមានស្លាប់មនុស្សច្រើននាក់។

ឃ- រត់គេចខ្លួនពីកន្លែងកើតហេតុក្នុងគោលបំណងគេចវេសពីការទទួលខុសត្រូវ។

ចំពោះបទល្មើសដែលមានចែងក្នុងមាត្រានេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស៖

១- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

២- ការហាមឃាត់ចំពោះការបើកបរយានយន្ត ទោះបីជាប្រភេទណាក៏ដោយសម្រាប់រយៈពេល៥ (ប្រាំ)ឆ្នាំយ៉ាងច្រើន។

៣- ការព្យួរលិខិតបើកបរ សម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំយ៉ាងច្រើន។

៤- ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស សម្រាប់រយៈពេល២(ពីរ)ខែយ៉ាងច្រើន។

៥- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោសនៅក្នុងសារព័ត៌មាន។

៦- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល៨(ប្រាំបី)ថ្ងៃយ៉ាងច្រើន។

**មាត្រា៨៦ .-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌ ដែលមាន ចែងក្នុង មាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមាន ចែងក្នុងមាត្រា៨៥នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើនដូចតទៅនេះ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយនិងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

២-ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤-ការបិទគ្រឹះស្ថាន ដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសតាមបែបបទកំណត់ដោយមាត្រា ១៧៦(ការបិទគ្រឹះស្ថាន)នៃក្រមព្រហ្មទណ្ឌ។

៥- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដល់សាធារណជន តាមបែបបទកំណត់ដោយមាត្រា១៧៧(ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន)នៃក្រមព្រហ្មទណ្ឌ។

៦-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយ សេចក្ដីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៧- ការផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស នៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្ដីសម្រេច តាមមធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨៧ .-**

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឲ្យរំលត់បណ្ដឹងអាជ្ញា។

អំពើល្មើសដែលត្រូវទទួលរងពិន័យអន្តរការណ៍ ហើយជនពាក់ព័ន្ធមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍តាមកាលកំណត់ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវបញ្ជូនកំណត់ហេតុព្រមទាំងវត្ថុតាងទៅ អយ្យការអមសាលាដំបូង។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា៨៨ ..**

រាល់លិខិតបទដ្ឋានគតិយុត្ត ដែលបានបង្កើតឡើងដើម្បីអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែល បានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ត្រូវនៅមានអានុភាពអនុវត្តតទៅទៀតរហូតមានអត្ថបទថ្មីមកកែប្រែឬលុបចោល លើកលែងតែបទប្បញ្ញត្តិ ដែលផ្ទុយនឹងស្មារតីនៃច្បាប់នេះ។

**មាត្រា៨៩ ..**

អ្នកកាន់បណ្ណបើកបរដែលត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ អាចបន្តប្រើប្រាស់រហូតអស់សុពលភាព។

អ្នកកាន់បណ្ណបើកបរ ដែលមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ត្រូវ បំពេញបែបបទសុំប្តូរបណ្ណបើកបរឲ្យបានចប់សព្វគ្រប់ក្នុងរយៈពេល១(មួយ)ឆ្នាំ បន្ទាប់ពីច្បាប់នេះចូល ជាធរមាននៅទូទាំងប្រទេស។

**មាត្រា៩០ .. ថ្មី**

កាតព្វកិច្ចពាក់ខ្សែក្រវាត់សុវត្ថិភាព សម្រាប់អ្នករួមដំណើរទាំងអស់ជិះកៅអីខាងក្រោយនៃរថយន្តនៅក្រៅទីប្រជុំជននិងបទប្បញ្ញត្តិ ដែលមានចែងក្នុងកថាខណ្ឌទី២ មាត្រា៧ ព្រមទាំងចំណុចទី១១និងទី១២ មាត្រា៨ថ្មី នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាននៅទូទាំងប្រទេស។

**មាត្រា៩១ ..**

បទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា៨៣និងមាត្រា៨៤ ជំពូកទី៧នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាននៅទូទាំងប្រទេស។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា៩២ ..**

ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៧ /០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី **១៦** ខែ **មករា** ឆ្នាំ ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល. ១៥០១. ០៣៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ត្រាំ អ៊ីវតឹក**

លេខ: ៥៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១ស.១៧០១.០៧០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**
**ហត្ថលេខា**
**ស៊ុន ចាន់ថុល**

លេខ:៧៥ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ឧបសម្ព័ន្ធទី២ ៖ អនុក្រឹត្យលេខ៣៩ ស្តីពីការកែសម្រួលលេខ៤៤ អនក្រ.បក, ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៣៩...អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការកែសម្រួលអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើ ក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា ៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រាមួយ._**

មាត្រា៦ មាត្រា៧ មាត្រា៨ មាត្រា៩ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៃជំពូកទី៣ អំពើល្មើស និងចំនួនទឹកប្រាក់ត្រូវពិន័យអន្តរការណ៍នៃអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ចរាចរណ៍ផ្លូវគោក ត្រូវបានកែសម្រួលដូចខាងក្រោម៖

## ជំពូកទី៣
## អំពើល្មើស និងចំនួនទឹកប្រាក់ត្រូវពិន័យអន្តរការណ៍

**មាត្រា៦ ថ្មី._**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបររទេះរុញយានយន្ត ឬរទេះរុញយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន ចំពោះអំពើល្មើសដូចខាងក្រោម៖

១. ត្រូវពិន័យទឹកប្រាក់ចំនួន ៦០ ០០០(ប្រាំមួយម៉ឺន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

ក- អ្នកបើកបរ និងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុពី ០៣(បី)ឆ្នាំឡើងទៅមិនពាក់មួកសុវត្ថិភាព ឬពាក់មួកសុវត្ថិភាពមិនត្រឹមត្រូវតាមស្តង់ដារជាតិ ឬពាក់មួកសុវត្ថិភាពដោយមិនដាក់គន្លឹះខ្សែសុវត្ថិភាព។ ការពិន័យអន្តរការណ៍ករណីល្មើសនេះ ត្រូវគិតតាមចំនួនជនប្រព្រឹត្តិល្មើសលើកលែងតែត្រីចក្រយានយន្ត ដែលមានដំបូលរឹងមាំបិទជិត។

ខ- បើកបររទេះរុញយានយន្តមានទំហំស៊ីឡាំងលើសពី ១២៥(មួយរយម្ភៃប្រាំ)សង្ទីម៉ែត្រគូប ឬមាន

ថាមពលអគ្គិសនីលើសពី ១១(ដប់មួយ)គីឡូវ៉ាត់ ឬទោចក្រយានយន្តសណ្ដោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួនដែលមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមនៃបណ្ណបើកបរយានយន្ត។

គ- ឈប់ ឬចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

ឃ- បើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ង- បើកបរលើសល្បឿនកំណត់ចាប់ពី ១(មួយ) ទៅ ១៩(ដប់ប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ច- បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ នៃមាត្រា៨ថ្មី នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក លើកលែងករណីដឹកអ្នកជម្ងឺ។

ឆ- បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍។

ជ- បើកបរដោយគ្មានកញ្ចក់មើលក្រោយ។

២. ត្រូវពិន័យទឹកប្រាក់ចំនួន ៨០ ០០០(ប្រាំបីម៉ឺន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

ក- ប្រើទូរស័ព្ទនៅពេលបើកបរដោយគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង។

ខ- បើកបរប្រើសញ្ញាសូរសព្ទមិនត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

គ- បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយានមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ- បើកបរលើសល្បឿនកំណត់ចាប់ពី ២០(ម្ភៃ) ទៅ២៩(ម្ភៃប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

៣. ត្រូវពិន័យទឹកប្រាក់ចំនួន ១០០ ០០០(មួយសែន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

ក- បើកបរបង្ហោះ រេចុះរេឡើង ឆាបឬគៀរ។

ខ- បើកបរអូសជន្ទល់លើផ្លូវថ្នល់ ឬព្រលែងដៃចង្កូត ឬលើកជើងដាក់លើដៃចង្កូត។

គ- បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើន ខុសពីបទដ្ឋានបច្ចេកទេស។

ឃ- បើកបរមិនគោរពលក្ខខណ្ឌសុខភាពតម្រូវឱ្យពាក់វ៉ែនតាដែលមានកំណត់ក្នុងបណ្ណបើកបរ។

ង- បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្កួតកណ្ដាលទ្រូងផ្លូវ។

ច- បើកបរលើសល្បឿនកំណត់ចាប់ពី ៣០(សាមសិប)ទៅ ៣៩(សាមសិបប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ- បើកបរល្មើសនឹងការជៀស ការបត់ និងការជែង។

ជ- បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ។

ឈ- ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្ដូរទិសនៃយានមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស។

ញ- បើកបរដោយគ្មាន ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងបំភ្លឺផ្លាកលេខ ភ្លើងសញ្ញាប្ដូរទិស ភ្លើងហ្វ្រាំង។

ដ- បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែតៗ។

ឋ- បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ឌ- បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១ ទី២ ទី៥ នៃមាត្រា៥៦ នៃច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។

៤. ត្រូវពិន័យទឹកប្រាក់ចំនួន ១២០ ០០០(មួយសែនពីរម៉ឺន)រៀល ចំពោះអ្នកបើកបរដែលបានប្រព្រឹត្តអំពើល្មើសដូចខាងក្រោម៖

ក- បើកបរដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ឬហួសសុពលភាព។

ខ- បើកបរដោយគ្មានបណ្ណសម្គាល់ និង/ឬផ្លាកលេខ។

គ- បើកបរដោយមិនបានត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានតាមច្បាប់កំណត់។

ឃ- ប្តូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត។

ង- ប្រើបណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន។

ច- ប្រើផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាក បាត់លេខ ឬដាក់សម្ភារៈ ឬវត្ថុផ្សេងៗបាំងផ្លាកលេខ។

៥. ត្រូវពិន័យទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ចំពោះអ្នកបើកបរដែលប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

៦. ត្រូវពិន័យអន្តការណ៍ចំនួនទឹកប្រាក់ ២៥០ ០០០(ពីរសែនប្រាំម៉ឺន)រៀល ចំពោះអ្នកបើកបរដែលស្ថិតក្នុងភាពស្រវឹងដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥(សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩(សូន្យក្បៀសសាមសិបប្រាំបួន)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥(សូន្យក្បៀសប្រាំ) ទៅ ០,៧៩(សូន្យក្បៀសចិតសិបប្រាំបួន)ក្រាមក្នុងមួយលីត្រឈាម។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបើកបរបន្តដំណើរទៅមុខទៀត។

**មាត្រា៧ ថ្មី.**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តធុនស្រាល និងអ្នកបើកបរយានយន្តធុនធ្ងន់ដែលប្រព្រឹត្តិអំពើល្មើសដូចខាងក្រោម៖

១. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៧៥ ០០០(ប្រាំពីរម៉ឺនប្រាំពាន់)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរមិនបានយកភ្ជាប់តាមខ្លួននូវឯកសារដើមរួមមាន បណ្ណបើកបរយានយន្ត និងលិខិតអនុញ្ញាតធ្វើអាជីវកម្មចំពោះរថយន្តដែលប្រកបអាជីវកម្មដឹកជញ្ជូន។

ខ- បើកបរដោយមិនពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព។

គ- ឈប់ ឬចតល្មើសនឹងមាត្រា២៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឃ- បើកបរដោយកុងទ័រល្បឿនមិនដំណើរការ។

ង- បើកបរដឹកអ្នកដំណើរលើសចំណុះល្មើសនឹងចំណុចទី៨ មាត្រា៨ថ្មី និងចំណុចទី៦ នៃមាត្រា៦៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ច- អ្នកបើកបរយានយន្តធុនធ្ងន់ យានយន្តបករណ៍ យានយន្តសណ្តោងរ៉ឺម៉ក ឬសឺមីរ៉ឺម៉កបិទស្លាកសញ្ញាចាំងពន្លឺខុសបទដ្ឋានកំណត់ ឬមិនមានបិទស្លាកសញ្ញាចាំងពន្លឺ។

២. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១២០ ០០០(មួយសែនពីរម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ២២៥ ០០០(ពីរសែនពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរប្រើទូរស័ព្ទគ្មានឧបករណ៍សម្លេងភ្ជាប់ទំនាក់ទំនង។

ខ- បើកបរប្រើសញ្ញាសូរស័ព្ទមិនត្រឹមត្រូវតាមប្បញ្ញត្តិច្បាប់។

គ- បើកបរដោយដាក់តាំងភ្លើង និងភ្លើងសញ្ញានៃយាន មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ឃ- បើកបរដោយគ្មានផ្លិតទឹកជូតកញ្ចក់មុខ ឬផ្លិតទឹកជូតកញ្ចក់មុខមិនដំណើរការ ឬកញ្ចក់មុខ ឬកញ្ចក់ក្រោយ មានប្រេះស្រាំដែលលំបាកមើលផ្លូវ ឬគ្មានកញ្ចក់មើលក្រោយ។

ង- បើកបរមានប៊ូឡុងកង់ ឬអេគ្រូកង់មិនគ្រប់តាមចំនួនកំណត់នៃប្រភេទរថយន្តនីមួយៗ។

ច- បើកបរលើសល្បឿនកំណត់ចាប់ពី ១(មួយ) ទៅ ១៩(ដប់ប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ- បើកបររថយន្តធ្វើអាជីវកម្មផ្ទាល់ខ្លួនដឹកអ្នកដំណើរ ឬដឹកទំនិញ គ្មានសញ្ញាសម្គាល់បញ្ជាក់អំពីទំហំទម្ងន់រថយន្ត ទម្ងន់ផ្ទុក ចំណុះផ្ទុក ចំនួនភ្លៅ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

ជ- បើកបរល្មើសនឹងបែបបទនៃការសណ្តោងយានដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ឈ- បើកបរដោយមិនបានប្រើភ្លើងសញ្ញាអាសន្ន ឬមិនបានដាក់សញ្ញាត្រីកោណជាដំណឹងក្នុងករណីដែលយានយន្តខូចមិនអាចរំកិលចេញពីទ្រូងផ្លូវបាន។

ញ- បើកបររថយន្តដឹកទំនិញមានគ្រោះថ្នាក់គ្មានសញ្ញាសម្គាល់ ឬប្រើសញ្ញាសម្គាល់មិនត្រឹមត្រូវ។

៣. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៣០០ ០០០(បីសែន)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរបង្ហោះ រេចុះរេឡើង ឆាបឬគៀរ។

ខ- បើកបរបញ្ចេញសម្លេងម៉ាស៊ីនខ្លាំង ឬផ្សែងច្រើន ខុសពីបទដ្ឋានបច្ចេកទេស។

គ- បើកបរយានយន្តផ្ទាល់ខ្លួនដោយគ្មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម ឬប្រើលិខិតធ្វើអាជីវកម្មហួសសុពលភាព។

ឃ- បើកបរមិនគោរពលក្ខខណ្ឌសុខភាព ដែលតម្រូវឱ្យពាក់វ៉ែនតា។

ង- បើកបរខុសទិសចរាចរណ៍ ឬបើកបរជាន់គំនូសបង្គួតកណ្តាលទ្រូងផ្លូវ។

ច- បើកបរលើសល្បឿនកំណត់ចាប់ពី ២០(ម្ភៃ) ទៅ២៩(ម្ភៃប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

ឆ- បើកបរល្មើសនឹងការជៀស ការបត់ និងការជែង។

ជ- បើកបរល្មើសនឹងសិទ្ធិអាទិភាពផ្លូវប្រសព្វ។

ឈ- ប្រើភ្លើងហ្វាកូត ឬភ្លើងសញ្ញាប្តូរទិសនៃយានមិនត្រឹមត្រូវ ឬកែច្នៃភ្លើងខុសបទដ្ឋានបច្ចេកទេស។

ញ- បើកបរដោយគ្មាន ឬមិនដំណើរការភ្លើងហ្វាកូត ភ្លើងសញ្ញាប្តូរទិស ភ្លើងហ្វ្រាំង ភ្លើងទីតាំងខាងមុខរថយន្ត និងភ្លើងក្រហមខាងក្រោយរថយន្ត។

ដ- បើកបរមិនគោរពភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម ឬក្រហមភ្លឹបភ្លែតៗ។

ឋ- បើកបរមិនគោរពផ្លាកសញ្ញាហាមឃាត់ ឬផ្លាកសញ្ញាបញ្ជា ឬផ្លាកសញ្ញាសិទ្ធិអាទិភាព ឬគំនូសសញ្ញាសម្រាប់ថ្មើរជើងឆ្លងកាត់។

ឌ- បើកបរប្រើប្រាស់សំបកកង់សឹកលើសកម្រិតកំណត់ ឬរហែក ឬប្រេះ ឬប៉ោង។

ឍ- បើកបរមិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់មន្ត្រីនគរបាលចរាចរណ៍។

ណ- បើកបរផ្ទុកទំនិញល្មើសនឹងចំណុចទី១ ទី២ ទី៣ ទី៤ ទី៥ មាត្រា៥៦ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

ត- បើកបររថយន្តធុនធ្ងន់ដែលគ្មានរនាំងសុវត្ថិភាព ឬមានរនាំងសុវត្ថិភាពមិនត្រឹមត្រូវតាមតួរថយន្តខាងក្រោម ឬគ្មានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតៃន័រ ឬមានគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតៃន័រមិនគ្រប់គ្រាន់ ឬគន្លឹះសុវត្ថិភាពសម្រាប់ភ្ជាប់កុងតៃន័រមិនដំណើរការ។

៤. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ១៨០ ០០០(មួយសែនប្រាំបីម៉ឺន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៣៧៥ ០០០(បីសែនប្រាំពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរដោយគ្មានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយាន ឬប្រើវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសហួសសុពលភាព។

ខ- ប្ដូរពណ៌យានយន្តដោយគ្មានការអនុញ្ញាត ឬបិទពណ៌មិនត្រឹមត្រូវតាមបណ្ណសម្គាល់យានយន្ត។

គ- ប្រើប្រាស់បណ្ណបើកបរមិនត្រឹមត្រូវតាមប្រភេទយាន។

ឃ- ប្រើបណ្ណបើកបរយានយន្តហួសសុពលភាព។

ង- បើកបរយានយន្តដែលមានកង់ច្រវ៉ាក់ដែកផ្ទាល់នៅលើទ្រូងផ្លូវថ្នល់ក្រាលកៅស៊ូ។

ច- ប្រើប្រាស់ផ្លាកលេខសម្គាល់យានដែលរចនាខុសពីលក្ខណៈដើម ឬលុបលេខ ឬបាក់ផ្លាក បាត់លេខ ឬដាក់សម្ភារៈ ឬវត្ថុផ្សេងៗបាំងផ្លាកលេខ។

ឆ- បើកបរលើសល្បឿនកំណត់ចាប់ពី ៣០(សាមសិប) ទៅ ៣៩(សាមសិបប្រាំបួន)គីឡូម៉ែត្រក្នុងមួយម៉ោង។

៥. ត្រូវពិន័យអ្នកបើកបរយានយន្តធុនស្រាលទឹកប្រាក់ចំនួន ៣០០ ០០០(បីសែន)រៀល និងអ្នកបើកបរយានយន្តធុនធ្ងន់ទឹកប្រាក់ចំនួន ៦២៥ ០០០(ប្រាំមួយសែនពីរម៉ឺនប្រាំពាន់)រៀល ចំពោះអំពើល្មើសដូចខាងក្រោម៖

ក- បើកបរយានយន្តដែលកែច្នៃដំឡើងខុសបទដ្ឋានបច្ចេកទេស។

ខ- បើកបរប្រណាំងគ្នាដោយគ្មានការអនុញ្ញាតលើផ្លូវសម្រាប់ធ្វើចរាចរណ៍ជាសាធារណៈ។

គ- បើកបរលើសល្បឿនកំណត់ចាប់ពី ៤០(សែសិប)គីឡូម៉ែត្រក្នុងម៉ោងឡើងទៅ។

៦. ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរស្ថិតក្នុងភាពស្រវឹង ដែលមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ (សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩(សូន្យក្បៀសសាមសិបប្រាំបួន)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥ (សូន្យក្បៀសប្រាំ) ទៅ ០,៧៩(សូន្យក្បៀសចិតសិបប្រាំបួន)ក្រាមក្នុងមួយលីត្រឈាម ដូចតទៅ៖

- ទឹកប្រាក់ចំនួន ៤០០ ០០០(បួនសែន)រៀល សម្រាប់រថយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៨០០ ០០០(ប្រាំបីសែន)រៀល សម្រាប់រថយន្តធុនធ្ងន់។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបើកបរបន្តដំណើរទៅមុខទៀត។

**មាត្រា៨ ថ្មី.**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណបើកបរ ឬក្នុងរយៈពេលដែលបណ្ណបើកបរត្រូវបានដកហូត ព្យួរទុក ឬទុកជាមោឃៈ ដូចតទៅ៖

- ទឹកប្រាក់ចំនួន ១ ២០០ ០០០(មួយលានពីរសែន)រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ២ ៤០០ ០០០(ពីរលានបួនសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្ដងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុនត្រូវផ្ដន្ទាទោសតាមច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា៩ ថ្មី.-**

ត្រូវពិន័យអន្តរការណ៍ចំពោះអ្នកបើកបរយានយន្តដោយគ្មានបណ្ណសម្គាល់យានជំនិះ និង/ឬគ្មានផ្លាកលេខ ដូចតទៅ៖

- ទឹកប្រាក់ចំនួន ១ ២០០ ០០០(មួយលានពីរសែន)រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ២ ៤០០ ០០០(ពីរលានបួនសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះ មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោកត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា១០ថ្មី.-**

ត្រូវពិន័យអន្តការណ៍ចំពោះអ្នកបើកបរយានយន្តស្ថិតក្នុងភាពស្រវឹង ដែលមានអត្រាជាតិអាល់កុលចាប់ពី ០,៤០(សូន្យក្បៀសសែសិប)មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៨០(សូន្យក្បៀសប៉ែតសិប)ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ដូចតទៅ៖

- ទឹកប្រាក់ចំនួន ១ ០០០ ០០០(មួយលាន)រៀល សម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន
- ទឹកប្រាក់ចំនួន ២ ០០០ ០០០(ពីរលាន)រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៤ ០០០ ០០០(បួនលាន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ក្នុងករណីនេះ ត្រូវបញ្ឈប់មិនឱ្យបើកបរបន្តដំណើរទៅមុខទៀត។

ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ម្តងរួចហើយ តែនៅបន្តប្រព្រឹត្តបទល្មើសនេះទៀតក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់គិតពីការពិន័យអន្តរការណ៍លើកមុន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ក្នុងករណីនេះមន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

**មាត្រា១១ថ្មី.-**

ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទដែលមិនបានបំពេញបែបបទចុះបញ្ជីយានយន្ត សុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឱ្យបានចប់សព្វគ្រប់មុនប្រគល់ឱ្យអ្នកទិញ ត្រូវទទួលរងពិន័យអន្តរការណ៍ដូចតទៅ៖

- ទឹកប្រាក់ចំនួន ១២០ ០០០(មួយសែនពីរម៉ឺន)រៀល សម្រាប់ទោចក្រយានយន្ត ឬទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ឬត្រីចក្រយានយន្ត ឬម៉ូតូកង់បួន
- ទឹកប្រាក់ចំនួន ១ ២០០ ០០០(មួយលានពីរសែន)រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ២ ៤០០ ០០០(ពីរលានបួនសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

ត្រូវពិន័យអន្តរការណ៍ចំពោះនីតិបុគ្គលដែលមិនបានស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន ដូចតទៅ៖

- ទឹកប្រាក់ចំនួន ១៥០ ០០០(មួយសែនប្រាំម៉ឺន)រៀល សម្រាប់យានយន្តធុនស្រាល
- ទឹកប្រាក់ចំនួន ៣០០ ០០០(បីសែន)រៀល សម្រាប់យានយន្តធុនធ្ងន់។

**មាត្រា១២ថ្មី.**

ជនណាដែលស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន មិនអនុញ្ញាតឱ្យបើកបរយានយន្តឡើយ។ អ្នកបើកបរយានយន្តស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន ត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**មាត្រា១៣ថ្មី.**

ឪពុកម្តាយឬអាណាព្យាបាលត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងអនុក្រឹត្យនេះ ដែលប្រព្រឹត្តដោយអនីតិជនមានអាយុចាប់ពី១៥(ដប់ប្រាំ)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ។

**មាត្រា១៤ថ្មី.**

ជនដែលបានប្រព្រឹត្តល្មើសនឹងមាត្រាមួយ មាត្រា៦ថ្មី មាត្រា៧ថ្មី មាត្រា៨ថ្មី មាត្រា៩ថ្មី និងមាត្រា១០ថ្មី ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍។

ក្នុងករណីមិនបានបង់ប្រាក់ពិន័យអន្តរការណ៍លើសរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ ចំនួនទឹកប្រាក់ពិន័យនេះត្រូវដំឡើងជាពីរដង។

ក្នុងករណីមិនបានបង់ប្រាក់ពិន័យអន្តរការណ៍លើសរយៈពេល ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ ចំនួនទឹកប្រាក់ពិន័យនេះត្រូវដំឡើងជាបីដង។

ក្នុងករណីមិនបានបង់ប្រាក់ពិន័យអន្តរការណ៍លើសរយៈពេល ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ មន្ត្រីមានសមត្ថកិច្ចត្រូវរៀបចំកំណត់ហេតុបញ្ជូនទៅអយ្យការអមសាលាដំបូង ដើម្បីចាត់វិធានការតាមច្បាប់ជាធរមាន។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១៥ថ្មី.**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យលេខ៤៤ អនក្រ.បក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក មានសិទ្ធិប្តឹងតវ៉ារយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលបង្កាន់ដៃពិន័យអន្តរការណ៍ទៅប្រធានអង្គភាពដែលគ្រប់គ្រងលើមន្ត្រីអនុវត្តផ្ទាល់គឺ៖

- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្តឹងតវ៉ាទៅអធិការនគរបាលក្រុង ស្រុក ខណ្ឌ
- នៅថ្នាក់រាជធានី ខេត្ត ត្រូវប្តឹងតវ៉ាទៅស្នងការនគរបាលរាជធានី ខេត្ត
- នៅថ្នាក់ក្រសួង ត្រូវប្តឹងតវ៉ាទៅប្រធាននាយកដ្ឋាននគរបាលចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។ ប្រធានអង្គភាពត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលបណ្តឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ប្រធានអង្គភាពខាងលើ មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីច្បាប់។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ..អង្គារ..៨..រោច..ខែ..ផល្គុន....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី..១៧.....ខែ..មីនា......ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា។
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ